No. 3

ខេត្តសៀមរាប អាជ្ញាធរអប្សរា រាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការ
អន្តរជាតិនៃប្រទេសជប៉ុន

# ការសិក្សាស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

## ក្រុងសៀមរាប/អង្គរនៃព្រះរាជាណាចក្រកម្ពុជា

## របាយការណ៍ចុងក្រោយ

## ភាគទី ១ : សេចក្តីសង្ខេបសម្រាំង

ខែមីនា ឆ្នាំ២០០៦

JICA LIBRARY
1182587 [4]

មជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន
Nippon Koei Co., Ltd
Kokusai Kogyo Co., Ltd

C M O
JR
06-006

ខេត្តសៀមរាប អាជ្ញាធរអប្សរា រាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការ
អន្តរជាតិនៃប្រទេសជប៉ុន

# ការសិក្សាស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

# ក្រុងសៀមរាប/អង្គរនៃព្រះរាជាណាចក្រកម្ពុជា

## របាយការណ៍ចុងក្រោយ

## ភាគទី ១ : សេចក្តីសង្ខេបសម្រាំង

ខែមីនា ឆ្នាំ២០០៦

មជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន
Nippon Koei Co., Ltd
Kokusai Kogyo Co., Ltd

1182587 [4]

សមមូលរូបិយវត្ថុ

(អត្រាផ្លូវប្រាក់ផ្លូវការ ឆ្នាំ២០០៤)

១ ដុល្លារអាមេរិក = ៤.០១៦ រៀល

បើគ្មានការផ្តល់ព័ត៌មានជាពិសេសទេ

# កថាមុខ

ដើម្បីឆ្លើយតបទៅនឹងសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលនៃប្រទេសជប៉ុនបានសំរេចធ្វើ "ការសិក្សាអំពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយនិរន្តរភាព" ហើយបានប្រគល់ការសិក្សានេះទៅឱ្យទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ។

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនបានបញ្ជូនក្រុមសិក្សាមួយក្រុមទៅប្រទេសកម្ពុជាពីខែវិច្ឆិកា ឆ្នាំ២០០៤ ដល់ខែមីនា ឆ្នាំ២០០៦ ដែលដឹកនាំដោយលោកបណ្ឌិត Jinichiro Yabuta នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន ។

ក្រុមសិក្សានេះបានធ្វើការពិភាក្សាជាច្រើន ជាមួយនឹងមន្ត្រីពាក់ព័ន្ធនៃរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងបានធ្វើការអង្កេតផ្ទាល់ក្នុងតំបន់សិក្សា ។ ក្រុមសិក្សាបានធ្វើការសិក្សាបន្ថែមជាច្រើនទៀត និងបានរៀបចំរបាយការណ៍ចុងក្រោយនេះឡើង បន្ទាប់ពីបានវិលត្រឡប់ទៅកាន់ប្រទេសជប៉ុនវិញ ។

ខ្ញុំមានជំនឿថា របាយការណ៍នេះនឹងចូលរួមដល់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព និងដល់ការពង្រឹងទំនាក់ទំនងមិត្តភាពរវាងប្រទេសទាំងពីរ ។

ជាចុងក្រោយ ខ្ញុំសូមកោតសរសើរអស់ពីដួងចិត្តដល់មន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងប្រទេសកម្ពុជា ដែលបានចូលរួមសហការយ៉ាងជិតស្និទ្ធក្នុងការសិក្សានេះ ។

ខែមីនា ឆ្នាំ២០០៦

Takashi Kaneko
អនុប្រធាន
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

*ការសិក្សាអំពីផែនការមេសម្រាប់ការអភិវឌ្ឍន៍សៀមរាប/អង្គរប្រកបដោយនិរន្តរភាព*

ខែមីនា ២០០៦

**គោរពជូន :** លោក Takashi Kaneko

អនុប្រធាន

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

តូក្យូ ជប៉ុន

**លិខិតផ្ញើរ**

**លោក** Kaneko **ជាទីគោរព :**

ខ្ញុំមានក្តីរីករាយបញ្ជូនឱ្យលោកនូវរបាយការណ៍ចុងក្រោយនៃការសិក្សា ស្តីពីផែនការមេសម្រាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាពក្នុងព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍ចុងក្រោយនេះមានបីភាគ - ភាគ ទី ១ : សេចក្តីសង្ខេបសម្រាំង ភាគទី ២ : របាយការណ៍គោល និងភាគទី ៣ : របាយការណ៍តាមវិស័យ ។

វត្ថុបុរាណប្រវត្តិសាស្ត្រក្នុងក្រុងសៀមរាប/អង្គរមិនត្រឹមតែជាបេតិកភណ្ឌវប្បធម៌ពិភពលោកប៉ុណ្ណោះទេ តែថែមទាំងជានិមិត្តរូបនៃប្រទេសកម្ពុជា ពោលគឺជាអត្តសញ្ញាណជាតិខ្មែរ។ ជាងនេះ បេតិកភណ្ឌវប្បធម៌ពិភពលោកនេះគឺជាប្រភពដ៏សំខាន់នៃរូបិយវត្ថុបរទេស ។ ដូចនេះ ការខិតខំកែប្រែក្រុងទៅជាក្រុងគំរូលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពខ្ពស់គឺជាការចាំបាច់ ។ ទោះជាយ៉ាងនេះក៏ដោយ ក្រុងមិនត្រឹមតែមាននិរន្តរភាពសំរាប់តែការទាក់ទាញភ្ញៀវទេសចរមកកំសាន្តបេតិកភណ្ឌប្រវត្តិសាស្ត្រប៉ុណ្ណោះទេ តែផ្ទុយទៅវិញគឺជាក្រុងគំរូ ដែលជានិមិត្តរូបដ៏ល្អនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងសតវត្សរ៍ទី២១។ ការកែសំរួល និងកែលំអជាញឹកញាប់ក្នុងដំណើរការរៀបចំក្រុងគឺជាការចាំបាច់ ប៉ុន្តែត្រូវធ្វើការឆ្លុះបញ្ចាំងពីគតិបណ្ឌិតលើការអភិវឌ្ឍន៍នៃសម័យអង្គរ ហើយការខិតខំនានាដើម្បីបង្កើតបរិយាកាសដែលយកចិត្តទុកដាក់ខ្ពស់ដល់បរិស្ថានអាចជួយក្រុងឱ្យសំរេចគោលដៅក្នុងការបង្កើតក្រុងគំរូ ដែលមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពខ្ពស់ ។

ដើម្បីធ្វើឱ្យសំរេចគោលដៅនេះ វិស័យទេសចរណ៍ដែលកំពុងមានកំណើននៅពេលបច្ចុប្បន្នគួរត្រូវបានកែប្រែឱ្យទៅជាទេសចរណ៍ប្រកបដោយគុណភាព និងមានតុល្យភាពជាងមុន ដោយកាត់បន្ថយបន្ទុកបរិស្ថានធម្មជាតិ។ មានការផ្តល់យោបល់ថា រដ្ឋាបាលកម្ពុជាត្រូវយកចិត្តទុកដាក់ខ្ពស់លើការគ្រប់គ្រងបរិស្ថាន/ក្រុង រួមទាំងការគ្រប់គ្រងការប្រើប្រាស់ទឹក និងការប្រើប្រាស់ដី ដែលជាការងារចាំបាច់ ដើម្បីធ្វើឱ្យសំរេចក្រុងគំរូមួយដែលមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពពិតប្រាកដ ។

ផែនការមេរយៈពេលវែងដែលបានលើកឡើងក្នុងរបាយការណ៍ចុងក្រោយនេះមិនមែនជាផែនការដែលមិនអាចកែប្រែ និងត្រឹមត្រូវគ្រប់ពេលវេលានោះទេ។ ដូចនេះ ការពិនិត្យឡើងវិញ និងការកែសំរួលនឹងត្រូវធ្វើឡើងឱ្យស្របទៅតាមកាលៈ-ទេសៈប្រែប្រួល។ ចំណែក គំរោងអាទិភាពដែលបានស្នើឡើងគួរតែត្រូវបានពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយ និងជាប្រចាំដើម្បី ធ្វើការរៀបចំ និងការអនុវត្តន៍ឱ្យទាន់ពេលវេលា។ ផ្ទុយទៅវិញ មានការផ្តល់យោបល់ថា អាជ្ញាធរខេត្តត្រូវពង្រឹងសមត្ថភាព របស់ខ្លួនដើម្បីត្រួតពិនិត្យតាមដាន ធ្វើផែនការ និងអនុវត្តគំរោងនានា ដោយមានការជួយឧបត្ថម្ភពីស្ថាប័នជំនាញថ្នាក់ជាតិ ដូចជា អាជ្ញាធរអប្សរា និងក្រសួងពាក់ព័ន្ធផ្សេងៗទៀត។

ឆ្លៀតក្នុងឱកាសនេះ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ទីភ្នាក់ងាររបស់លោក ខេត្តសៀមរាប អជ្ញាធរអប្សរា ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា និងអាជ្ញាធរសំខាន់ៗផ្សេងៗទៀតក្នុងរាជរដ្ឋាភិបាលកម្ពុជាចំពោះកិច្ចសហការ និងជំនួយឧបត្ថម្ភ ដែលមិនអាចកាត់ថ្លៃបានដល់ការសិក្សានេះ។

យើងសង្ឃឹមថា របាយការណ៍នេះនឹងចូលរួមដល់ការអភិវឌ្ឍន៏ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព។

ដោយក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

Jinichiro Yabuta
ប្រធានក្រុមសិក្សា
ក្រុមសិក្សា JICA និងចង្កោមក្រុមហ៊ុន
នៃមជ្ឈមណ្ឌលអភិវឌ្ឍន៏អន្តរជាតិនៃប្រទេសជប៉ុន
Nippon Koei Co., Ltd និង
Kokusai Kogyo Co., Ltd

## ទីតាំងខេត្ត និងស្រុកសៀមរាប



ផែនទីស្រុកសៀមរាប និងតំបន់កណ្តាលនៃស្រុកសៀមរាប

ស្រុកសៀមរាប




តំបន់ទីប្រជុំជននៃស្រុកសៀមរាប



## មាតិកា

# ភាគទី ១ : សេចក្តីសង្ខេបសម្រាំង


ទីតាំងខេត្ត និងស្រុកសៀមរាប------------------------------------------------------------ i

ផែនទីស្រុកសៀមរាប និងតំបន់កណ្តាលនៃស្រុកសៀមរាប---------------------------------------- ii

មាតិកា ------------------------------------------------------------------------------ iii

១. សារំតា--------------------------------------------------------------------------- ១

២. ស្ថានភាព ភាពខ្លាំង និងបញ្ហា ------------------------------------------------------ ៧

៣. ចក្ខុវិស័យជាយុទ្ធសាស្ត្រ------------------------------------------------------------ ៩

៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ ------------------------------------------------------- ១៩

៥. ផែនការអភិវឌ្ឍន៍តាមវិស័យ--------------------------------------------------------- ២០

៦. គំរោង និងកម្មវិធី ---------------------------------------------------------------- ៤១

៧. ការរៀបចំហិរញ្ញវត្ថុ និងស្ថាប័ន ---------------------------------------------------- ៤៧

៨. ការគិតគូរពីសង្គម និងបរិស្ថាន ----------------------------------------------------- ៥១

៩. អនុសាសន៍ ------------------------------------------------------------------------ ៥៦

## បញ្ជីរូប និងតារាង

### រូប


រូបទី ១ : ក្របខ័ណ្ឌពេលវេលានៃការសិក្សាផែនការមេ ---------- ២

រូបទី ២ : រចនាសម្ព័ន្ធរបាយការណ៍ (១) ---------- ៤

រូបទី ៣ : រចនាសម្ព័ន្ធរបាយការណ៍ (២) ---------- ៥

រូបទី ៤ : រចនាសម្ព័ន្ធបញ្ហានៅសៀមរាប ---------- ៩

រូបទី ៥ : យុទ្ធសាស្ត្រសំរាប់សៀមរាប/អង្គរ ឆ្នាំ២០២០ ---------- ១៤

រូបទី ៦ : តំបន់ទាំងបីនៃសៀមរាប ---------- ១៨

រូបទី ៧ : ឌីជ្យាក្រាមលំហូរអំពីការអភិវឌ្ឍន៍ ---------- ២៧

រូបទី ៨ : ផែនការរួមសំរាប់គំរោង U-1 ---------- ២៩

រូបទី ៩ : លំដាប់នៃកម្មវិធី ---------- ៣០

រូបទី ១០ : តំបន់រមណីយដ្ឋានឆ្ងាយពីអង្គរ និងបណ្តាញផ្លូវថ្នល់ទៅកាន់តំបន់ទាំងនោះ ---------- ៣១

រូបទី ១១ : រចនាសម្ព័ន្ធផែនការតាមវិស័យ ---------- ៣៣

រូបទី ១២ : បណ្តាញផ្លូវសំខាន់ៗ (២០១២) ---------- ៣៤

រូបទី ១៣ : ក្របខ័ណ្ឌពេលវេលា និងការអភិវឌ្ឍន៍តាមដំណាក់កាលដែលស្នើឡើង ---------- ៣៥

រូបទី ១៤ : ផែនការរួមសំរាប់ប្រព័ន្ធបង្ហូរសំណល់រាវ ---------- ៣៨

រូបទី ១៥ : ផែនការបែងចែកភ្លើង ឆ្នាំ ២០២០ ---------- ៤០


### តារាង


តារាង ១ : ទំរង់រួមនៃផែនការមេ ---------- ៦

តារាង ២ : កន្លែងទេសចរណ៍នៅតាមតំបន់ប្រវត្តិសាស្ត្រនៅអាស៊ីអាគ្នេយ៍ និងនៅសៀមរាប ---------- ១០

តារាង ៣ : ការប្រៀបធៀបសេណារីយូទាំងពីរ ---------- ១១

តារាង ៤ : ការវាយតម្លៃសេណារីយូពីរ ---------- ១១

តារាង ៥ : យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមវិស័យ : ខ្លឹមសាររួម ---------- ២៤

តារាង ៦ : គំរោង និងកម្មវិធីដែលបានស្នើឡើង (១/២) ---------- ៤១

តារាង ៧ : គំរោង និងកម្មវិធីដែលបានស្នើឡើង (២/២) ---------- ៤២

តារាង ៨ : គំរោង និងកម្មវិធីអាទិភាព (១/២) ---------- ៤៤

តារាង ៩ : គំរោងអាទិភាព (២/២) ---------- ៤៤

តារាង ១០ : ការប៉ាន់ស្មានតំលៃគំរោង ---------- ៤៥

តារាង ១១ : កម្មវិធីកសាងសមត្ថភាពសំរាប់អាជ្ញាធរខេត្ត ---------- ៤៩

តារាង ១២ : សេចក្តីសង្ខេបនៃផលប៉ះពាល់នៃគំរោងទាំងអស់ ---------- ៥១

# សេចក្ដីសង្ខេបសម្រាំង

## ១. សាវតារ

រាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានទទួលស្គាល់ពីតម្រូវការដ៏ចាំបាច់ក្នុងការធ្វើផែនការមេរួមមួយ ដើម្បីអភិវឌ្ឍវិស័យសេដ្ឋកិច្ច សាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ និងរក្សាគុណភាពបរិស្ថាន និងធនធានទេសចរណ៍នៅក្នុងក្រុងសៀមរាប/អង្គរតាមចក្ខុវិស័យយូរអង្វែង។

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា និង JICA បានយល់ព្រមលើវិសាលភាពនៃការសិក្សាផែនការមេរួមសំរាប់អភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរនៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយនិរន្តរភាព។

JICA បានប្រគល់ការសិក្សានេះដល់ក្រុមសិក្សាមួយដែលរៀបចំដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន (IDCJ) ក្រុមហ៊ុន Nippon Koei Co. Ltd. (NK) និងក្រុមហ៊ុន Kukusai Kogyo Co. Ltd. (KKC)។

ក្រុមសិក្សាបានចាប់ផ្ដើមសិក្សានៅខែវិច្ឆិកា ឆ្នាំ២០០៤ និងបញ្ចប់នៅខែមីនា ឆ្នាំ២០០៦ ដោយបែងចែកជា ៤ ដំណាក់កាល។ ពង្រាងរបាយការណ៍ចុងក្រោយនេះគឺជាលទ្ធផលនៃដំណាក់កាលទី៤ ដែលត្រូវប្រើសំរាប់បង្កើតផែនការមេនៅខែកុម្ភៈ ឆ្នាំ២០០៦។ បន្ទាប់ពីបានទទួលគំនិត និងទស្សនៈកែលំអលើពង្រាងរបាយការណ៍ចុងក្រោយនេះ ក្រុមសិក្សានឹងដាក់បញ្ចូលគំនិត និងទស្សនៈទាំងនោះទៅក្នុងរបាយការណ៍ចុងក្រោយ ដែលនឹងត្រូវបញ្ជូនចេញនៅខែមីនាឆ្នាំ២០០៦។

## ១.១ គោលបំណងនៃការសិក្សា

ការសិក្សានេះមានគោលបំណងដើម្បី :

(១) រៀបចំផែនការមេរួមមួយសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរ រយៈពេលវែងប្រកបដោយនិរន្តរភាព ដើម្បីធ្វើឱ្យសំរេចនូវតុល្យភាពសមស្របមួយរវាងឧស្សាហកម្មទេសចរណ៍ បរិស្ថានក្រុង និងសមត្ថភាពស្ថាប័ន

(២) ស្នើឱ្យមានវិធានការមួយចំនួនក្នុងគោលដៅជំរុញ និងពង្រីកសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការអភិវឌ្ឍន៍ទេសចរណ៍ដែលជាផ្នែកមួយនៃផែនការមេរួមនេះ និង

(៣) លើកកំពស់ការផ្ទេរបច្ចេកទេសឱ្យសមភាគីកម្ពុជា ក្នុងគោលដៅពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន និងសហគមន៍។

## ១.២ តំបន់សិក្សា

តំបន់សិក្សាគ្របដណ្ដប់ស្រុកសៀមរាប ដោយយកចិត្តទុកដាក់លើតំបន់ក្រុង និងពង្រីកទៅកាន់តំបន់ពាក់ព័ន្ធផ្សេងទៀតនៃស្រុកសៀមរាប ក្នុងគោលបំណងសិក្សាពីសេដ្ឋកិច្ចមូលដ្ឋាន។

## ១.៣ ដំណើរការនៃការសិក្សា

(១) <u>គ្របខ័ណ្ឌពេលវេលានៃការសិក្សា</u>

ក្រុមសិក្សាធ្វើការសិក្សានៅក្នុងអំឡុងពេលពីខែវិច្ឆិកា ឆ្នាំ២០០៤ ដល់ខែមីនា ឆ្នាំ២០០៦។ ការសិក្សានេះបានបែងចែកជាបួនដំណាក់កាល ដូចមានបង្ហាញនៅក្នុងរូបខាងក្រោម។




កំណត់ចំណាំ : DICR: ពង្រាងរបាយការណ៍ដំបូង ICR: របាយការណ៍ដំបូង PR1: របាយការណ៍រីកចំរើនទី ១ PR2: របាយការណ៍រីកចំរើនទី ២ ITR: របាយការណ៍បណ្ដោះអាសន្ន DFR: សេចក្ដីពង្រាងរបាយការណ៍ចុងក្រោយ FR: របាយការណ៍ចុងក្រោយ ។

រូបទី ១ : ក្របខ័ណ្ឌពេលវេលានៃការសិក្សាផែនការមេ

(២) រចនាសម្ព័ន្ធស្ថាប័ន

អាជ្ញាធរខេត្តសៀមរាប និងអាជ្ញាធរអប្សរាគឺជាទីភ្នាក់ងារអនុវត្តការងារជាមួយក្រុមសិក្សារបស់JICA ។ សមភាគីចំនួន១៣នាក់ពីអាជ្ញាធរខេត្តសៀមរាប និងអាជ្ញាធរអប្សរាត្រូវជ្រើសតាំងឱ្យចូលរួមសហការការងារជាមួយសមាជិកក្រុមសិក្សា JICA ។

(៣) យន្តការសំរបសំរួលសំរាប់ការសិក្សា

កិច្ចប្រជុំអន្តរក្រសួងថ្នាក់ជាតិត្រូវបានរៀបចំឡើងដើម្បីចែករំលែកព័ត៌មាន និងសំរាប់ពង្រឹងការងារសំរបសំរួលរវាងក្រសួងពាក់ព័ន្ធ ។ គណៈកម្មការដឹកនាំការសិក្សានៅថ្នាក់ខេត្តត្រូវបានបង្កើតឡើង ដើម្បីពិគ្រោះយោបល់ជាមួយក្រុមសិក្សាដើម្បីធានាឱ្យមានភាពរលូនក្នុងការអនុវត្តន៏ការសិក្សា និងប្រើប្រាស់លទ្ធផលនៃការសិក្សាឱ្យមានប្រសិទ្ធភាពខ្ពស់ ។

(៤)ដំណើរការនៃការចូលរួមរបស់ប្រជាជន

ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រដោយមានការចូលរួមពីប្រជាជនតាំងពីពេលចាប់ផ្តើមរហូតដល់ទីបញ្ចប់ ។ ការចូលរួមទាំងនេះធ្វើឡើងតាមរយៈកិច្ចប្រជុំភាគីពាក់ព័ន្ធចំនួន៤ដង ។ នៅក្នុងកិច្ចប្រជុំនីមួយៗ ក្រុមសិក្សា JICA បានធ្វើបទ

បង្ហាញពីគំនិត និងខ្លឹមសារនៃរបាយការណ៍នីមួយៗ និងស្នើឱ្យមានការពិភាក្សាទូលំទូលាយដើម្បីកែលំអរបាយការណ៍ទាំងនោះ ។ ខាងក្រោមនេះគឺជាតារាងសង្ខេបនៃកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ។

តារាងសង្ខេបនៃកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ

| | កាលបរិច្ឆេទ | របាយការណ៍សំរាប់ការពិភាក្សា | ចំនួនអ្នកចូលរួម | អ្នកចូលរួម |
|---|---|---|---|---|
| ទីមួយ | ៣ កុម្ភៈ ២០០៥ | របាយការណ៍ចាប់ផ្តើម | ១៥៤ | មន្ត្រី អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនឯកជន ភ្នាក់ងារទេសចរណ៍ អ្នកផ្តល់ជំនួយ និងអ្នកដឹកនាំសហគមន៍ |
| ទីពីរ | ១០ មីនា ២០០៥ | របាយការណ៍រីកចំរើន | ៦៧ | |
| ទីបី | ២២ វិច្ឆិកា ២០០៥ | របាយការណ៍បណ្តោះអាសន្ន | ១០០ | |
| ទីបួន | ៣១ មករា ២០០៦ | ពង្រាងរបាយការណ៍ចុងក្រោយ | ២០០ | |



រូបថតនៃកិច្ចប្រជុំភាគីពាក់ព័ន្ធលើកទី១



រូបថតនៃកិច្ចពិភាក្សាតាមក្រុមក្នុងកិច្ចប្រជុំភាគីពាក់ព័ន្ធលើកទី២

ក្រៅពីកិច្ចប្រជុំជាមួយនឹងភាគីពាក់ព័ន្ធ ក្រុមសិក្សាបានរៀបចំឱ្យមានសិក្ខាសាលាជាច្រើននៅថ្នាក់ភូមិ និងឃុំជាញឹកញាប់ ដើម្បីផ្លាស់ប្តូរគំនិតយោបល់ជាមួយប្រជាជននៅមូលដ្ឋាន ។

(៥) គំរោងសាកល្បង

ក្នុងអំឡុងពេលនៃការសិក្សា ក្រុមសិក្សា និងមន្ត្រីសមភាគីបានរៀបចំគំរោងសាកល្បងពីរ ដែលជាកិច្ចខិតខំរួមគ្នាដើម្បីលើកកំពស់ការយល់ដឹង និងសមត្ថភាពរបស់ភាគីពាក់ព័ន្ធ ព្រមទាំងដាក់បញ្ចូលមេរៀន និងលទ្ធផលផ្សេងៗពីបទពិសោធន៍ក្នុងគំរោងសាកល្បងទៅក្នុងផែនការមេ ។

- ធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង : ការលើកកំពស់ការយល់ដឹងបរិស្ថាន
- ការតាំងពិព័រណ៍ផលិតផលអង្គរ ឆ្នាំ២០០៥ : ការផ្សព្វផ្សាយផលិតផលមូលដ្ឋាន

## ១.៤ រចនាសម្ព័ន្ធរបាយការណ៍ចុងក្រោយ

នៅក្នុងដំណាក់កាលទី៤ នេះ ក្រុមសិក្សាបានរៀបចំផែនការមេ ដោយផ្អែកលើពង្រាងរបាយការណ៍ចុងក្រោយ ។ ពង្រាងរបាយការណ៍ចុងក្រោយនេះបែងចែកជាបីភាគ ដែលមានខ្លឹមសារដូចខាងក្រោម ។




រូបទី ២ : រចនាសម្ព័ន្ធរបាយការណ៍ (១)




រូបទី ៣ : រចនាសម្ព័ន្ធរបាយការណ៍ (២)

ទំរង់រួមនៃផែនការមេមានបង្ហាញនៅក្នុងតារាងខាងក្រោម។

តារាង ១ : ទំរង់រួមនៃផែនការមេ

| ស្ថានភាព និង បញ្ហា | ចក្ខុវិស័យជាយុទ្ធសាស្ត្រ | | ផែនការអភិវឌ្ឍន៍តាមវិស័យ | |
|---|---|---|---|---|
| | ក្រុងសៀមរាប/អង្គរ ២០២០ | យុទ្ធសាស្ត្រ | វិស័យ : គោលបំណងតាមវិស័យ | គំរោង/កម្មវិធី |
| ការពឹងផ្អែកខ្លាំងលើទេសចរណ៍បរិមាណ | *ក្រុងស្អាត និងមានតែមួយដោយផ្អែកលើប្រវត្តិសាស្ត្រ វប្បធម៌ និងលក្ខណៈខ្មែរ* | ១. ការលើកកំពស់ទេសចរណ៍សំដៅលើភ្ញៀវចំណាយខ្ពស់ | ទេសចរណ៍ : កន្លែងទេសចរណ៍គុណភាពដោយផ្អែកលើប្រវត្តិសាស្ត្រអង្គរ និងវប្បធម៌ | បណ្ដាញទេសចរណ៍បេតិកភ័ណ្ឌខ្មែរ (TO-1)<br>ទីផ្សារពេលយប់ (TO-2)<br>គណៈដឹកនាំទីផ្សារទេសចរណ៍ខេត្ត (TO-3)<br>ទេសចរណ៍ជនបទ/ធម្មជាតិដោយស.គ (TO-4)<br>ការកែលំអប្រព័ន្ធនាំភ្ញៀវ (TO-5)<br>សមត្ថភាពអនុវត្ត និងការគ្រប់គ្រងតំបន់ (TO-6) |
| ផលប្រយោជន៍តិចតួចដល់សេដ្ឋកិច្ចមូលដ្ឋាន | | ២. ពង្រីកជាអតិបរមានូវផលប្រយោជន៍មូលដ្ឋានពីទេ.ចរណ៍ | ការពង្រីកកសិកម្ម និងការផ្សព្វផ្សាយផលិតផលក្នុងស្រុក: និមិត្តសញ្ញាអង្គរដើម្បីពង្រីកការផ្គត់ផ្គង់ | APPC (A-1)<br>OVOP (A-2)<br>ភូមិផលិតកម្ម (A-3)<br>ការតាំងពិព័រណ៍ផលិតផលអង្គរ (A-4) |
| | | | ការអភិវឌ្ឍន៍ក្រុង : ធ្វើឱ្យក្រុងកាន់តែមានភាពទាក់ទាញ | ការគ្រប់គ្រងមណ្ឌលក្រុង (U-1)<br>សមត្ថភាពធ្វើផែនការ (U-2)<br>បញ្ជីសារពើភណ្ឌសំណង់ប្រវត្តិសាស្ត្រ (U-3)<br>ការអភិវឌ្ឍន៍តំបន់លំនៅដ្ឋាន (U-4)<br>តំបន់ទេសចរណ៍ និងតំបន់វប្បធម៌ (U-5) |
| បរិស្ថាន និងទេសភាពក្រុងមិនល្អ | | ៣. ធ្វើឱ្យក្រុងកាន់តែមានការទាក់ទាញដល់ភ្ញៀវទេសចរ | ការគ្រប់គ្រងបរិស្ថាន : សន្សំធនធាន និងកាត់បន្ថយបន្ទុកបរិស្ថាន | សមត្ថភាពគ្រប់គ្រងបរិស្ថាន (E-1)<br>ការលើកកំពស់ចំណេះដឹងបរិស្ថាន (E-2)<br>ប្រមូលកំរៃរួម (E-3) |
| ភាពមិនច្បាស់លាស់នៃនិរន្តរភាពបរិស្ថាន | | ៤. ធ្វើឱ្យបរិស្ថានក្រុងកាន់តែមាននិរន្តរភាព | មធ្យោបាយដឹកជញ្ជូន : បណ្ដាញផ្លូវផ្ដល់គ្រប់គ្រាន់ | ស្ពានបាភាង (TR-1)<br>បណ្ដាញផ្លូវរណប (ដំណាក់ 1) (TR-1)<br>បណ្ដាញផ្លូវរណប (TR-2~5)<br>សុវត្ថិភាពផ្លូវ (TR-6)<br>បណ្ដាញផ្លូវតាមតំបន់បេតិកភ័ណ្ឌ/ជនបទ (TR-7)<br>ការដឹកជញ្ជូនតាមតំបន់រមណីយដ្ឋានអង្គរ (TR-8, 9)<br>ការថែទាំផ្លូវ (TR-10) |
| ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ | | | ធនធានទឹក និងការផ្គត់ផ្គង់ទឹក : អភិវឌ្ឍធនធានទឹក បង្កើនការគ្របដណ្ដប់ផ្គត់ផ្គង់ និងគ្រប់គ្រងទឹកក្រោមដី | ការគ្រប់គ្រងទឹកក្រោមដី (W-1, 2)<br>កែលំអបំពង់ទុយោ (W-3)<br>ការសិក្សាលើការគ្រប់គ្រងទឹក (W-4)<br>ការផ្គត់ផ្គង់ទឹក (W-5, 6) |
| | | ៥. ពង្រីកហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវ និងប្រជាជន | ការគ្រប់គ្រងសំណល់រឹង : ធ្វើក្រុងស្អាត | ការគ្រប់គ្រងសំណល់រឹង (SW-1, 2)<br>កន្លែងចាក់សំរាមអនាម័យ (SW-3) |
| | | | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ : ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវចិរភាព | គំរោងអភិវឌ្ឍន៍ក្រុង (SD-2)<br>កែលំអប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ (SD-1, 3~9) |
| សមត្ថភាពមូលដ្ឋានមានកំរិតលើការគ្រប់គ្រងការអភិវឌ្ឍន៍ | | | អគ្គិសនី : ផ្គត់ផ្គង់អគ្គិសនីដែលគួរឱ្យទុកចិត្ត ដែលមានបន្ទុកបរិស្ថានតិច | បិតាក់ម៉ាស៊ីនភ្លើងប្រើម៉ាស៊ូតជាបន្ទាន់ (P-1)<br>កែលំអប្រព័ន្ធផ្គត់ផ្គង់ភ្លើង (P-2~10) |
| | | ៦. ពង្រឹងរដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋាន | រដ្ឋបាលមូលដ្ឋាន ; ពង្រីកប្រកបដោយតម្លាភាព និងការទទួលខុសត្រូវ<br>ហិរញ្ញវត្ថុមូលដ្ឋាន : មូលដ្ឋានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់<br>ការផ្ដល់សិទ្ធិអំណាចដល់សហគមន៍ : ដៃគូរដ្ឋ-ប្រជាជន | (អនុសាសន៍)<br>គណៈកម្មការអភិវឌ្ឍន៍ខេត្ត<br>ការអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ខេត្ត<br>កំណែទំរង់ការគ្រប់គ្រង<br>ពង្រឹងច្បាប់<br>មូលនិធិអភិវឌ្ឍន៍ |

## ២. ស្ថានភាព ភាពខ្លាំង និងបញ្ហា

### ២.១ ស្ថានភាព

សៀមរាបគឺជាទីក្រុងបុរាណនៃរជ្ជសម័យអង្គរអស់រយៈពេលប្រមាណជា៦៥០ ឆ្នាំ ចាប់តាំងពីដើមសតវត្សរ៍ទី៩។ រជ្ជសម័យនោះសម្បូររុងរឿង ដែលមានប្រព័ន្ធធារាសាស្ត្រទំនើបសម័យបុរាណ ដែលប្រព័ន្ធទាំងនោះបានប្រើប្រាស់របបទឹកឡើងនៃបឹងទន្លេសាប ។ អាស្រ័យហេតុនេះ សៀមរាបតំណាងប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែររហូតដល់ពេលបច្ចុប្បន្ន ។

បន្ទាប់ពីប្រទេសមានសន្តិភាព ចំនួនភ្ញៀវទេសចរបរទេសកាន់តែច្រើនឡើងៗមកទស្សនាសៀមរាប។ ចំនួនភ្ញៀវទេសចរកើនឡើងដល់៧៥០.០០០ នាក់នៅឆ្នាំ២០០៤។ ចំនួនប្រជាជនក្នុងស្រុកសៀមរាបគឺ១៣៩.០០០ នាក់នៅឆ្នាំ២០០៤។ នៅសៀមរាប វិស័យទេសចរណ៍ត្រូវបានគេប៉ាន់ស្មានថាបានបង្កើតការងារចំនួន៥៥.០០០ នៅពេលធ្វើការពិនិត្យលើឥទ្ធិពលប្រយោលច្រើនយ៉ាងពីវិស័យទេសចរណ៍។ វិស័យទេសចរណ៍នៅសៀមរាបគឺជាវិស័យដ៏សំខាន់សំរាប់ប្រទេសកម្ពុជាផងដែរ ពីព្រោះវិស័យនេះចូលរួមវិភាគប្រមាណស្មើរតែ៤០ % នៃចំនួនរូបិយវត្ថុបរទេស ដែលចាំបាច់សំរាប់ការនាំប្រេងចូលក្នុងប្រទេស នៅឆ្នាំ២០០៣។

### ២.២ ភាពខ្លាំង

បើប្រៀបធៀបជាមួយនឹងតំបន់ដទៃទៀតនៅក្នុងប្រទេស ស្រុកសៀមរាបមានចំណុចខ្លាំងបីដូចខាងក្រោម :

ទី ១ : ប្រាសាទអង្គរគឺជាបេតិកភណ្ឌវប្បធម៌សំខាន់បំផុតរបស់ប្រទេស និងជាបេតិកភណ្ឌពិភពលោក។

ទី ២ : លទ្ធភាពងាយស្រួលក្នុងការធ្វើដំណើរតាមផ្លូវអាកាស ផ្លូវទឹក និងផ្លូវដី ។

ទី ៣ : ដោយសារភាពខ្លាំងខាងលើ ស្រុកសៀមរាបបានទទួលការគាំទ្រខាងគោលនយោបាយពីរដ្ឋាភិបាលថ្នាក់ជាតិ។ ជាឧទាហរណ៍ អាជ្ញាធរអប្សរាគឺជាសេនាធិការដ៏ខ្លាំងរបស់រដ្ឋាភិបាលថ្នាក់ជាតិដែលមានតួនាទីការពារប្រាសាទអង្គរ និងផ្តល់ការគាំទ្រខាងបច្ចេកទេសសំរាប់ការអភិវឌ្ឍទីក្រុង និងតំបន់។ គ្មានស្រុក ឬខេត្តណាផ្សេងទៀតអាចប្រើប្រាស់អាជ្ញាធរថ្នាក់ជាតិក្នុងតំបន់ជាក់លាក់មួយ ដូចជា អាជ្ញាធរអប្សរានេះឡើយ។

### ២.៣ បញ្ហា

ក្រៅពីភាពខ្លាំងទាំងឡាយខាងលើ ស្រុកសៀមរាបបានប្រឈមមុខទៅនឹងបញ្ហា ៦ ផ្សេងៗគ្នាដូចខាងក្រោម :

**បញ្ហាទី ១ : ការពឹងផ្អែកហួសហេតុលើទេសចរណ៍ប្រមូលផ្តុំ/ទេសចរណ៍បរិមាណ**

លក្ខណៈទេសចរណ៍នៅសៀមរាបគឺជាប្រភេទទេសចរណ៍ដែលមានការស្នាក់នៅរយៈពេលខ្លី។ ភ្ញៀវទេសចរជាច្រើនទស្សនាសៀមរាបជាក្រុម ដែលចំណាយពេលស្នាក់នៅសៀមរាបតែពីរ ឬបីថ្ងៃប៉ុណ្ណោះ។ ភ្ញៀវទេសចរទាំងនោះទស្សនាសៀមរាបក្នុងរយៈពេលមួយកំណត់នៅរដូវប្រាំង ដែលមានគោលបំណងទស្សនារមណីយដ្ឋានអង្គរមួយគត់។ ភ្ញៀវទេសចរភាគច្រើនមិនមកទស្សនាសៀមរាបម្តងទៀតឡើយ។ នេះគឺជាប្រភេទទេសចរណ៍ប្រមូលផ្តុំ។ ប្រភេទទេសចរណ៍ដូចនេះនាំមកនូវកំណើនបន្ទុកបរិស្ថាន ផ្តល់ផលប្រយោជន៍តិចតួចដល់មូលដ្ឋាន និងមានទំនាក់ទំនងស្តួចស្តើងជាមួយនឹងវប្បធម៌ក្នុងស្រុក។ មូលហេតុមួយនៃមូលហេតុធំៗទាំងឡាយដែលនាំឱ្យមានប្រភេទទេសចរណ៍បែបនេះគឺបណ្តាលមកពីគ្មានកន្លែង និងសកម្មភាពទាក់ទាញច្រើន ក្រៅតែពីរមណីយដ្ឋានអង្គរ។ ដូចនេះ ចាំបាច់បង្កើតឱ្យមានកន្លែងទាក់ទាញផ្សេងៗទៀតដើម្បីពង្រីកប្រភេទភ្ញៀវទេសចរ និងកែប្រែអាកប្បកិរិយានៃការស្នាក់នៅរយៈពេលខ្លីរបស់គេ។

### បញ្ហាទី ២ : ផលប្រយោជន៍តិចតួចដល់សេដ្ឋកិច្ចមូលដ្ឋាន

លក្ខណៈនៃទេសចរណ៍បរិមាណដែលបានរៀបរាប់ខាងលើហាក់បីជាផ្តល់ផលប្រយោជន៍តិចតួចដល់សេដ្ឋកិច្ចមូលដ្ឋាន។ ការចំណាយរបស់ភ្ញៀវអន្តរជាតិមានចំនួន៩៧ លានដុល្លារនៅឆ្នាំ ២០០៤ ដែលក្នុងនោះ ចំនួន៧០% ត្រូវបានគេប៉ាន់ស្មានថាបានរក្សាទុកក្នុងខេត្ត និងមានការប្រើប្រាស់ទំនិញ និងសេវាកម្មបន្ថែមនៅមូលដ្ឋានដោយគិតជាទឹកប្រាក់ចំនួន៣៨លានដុល្លារ។ មានសក្តានុពលផ្សេងៗទៀតដើម្បីបន្ថែមផលប្រយោជន៍ដល់មូលដ្ឋានតាមរយៈពង្រីកការចំណាយរបស់ភ្ញៀវទេសចរដោយផ្អែកលើការពង្រីកទេសចរណ៍ និងតាមរយៈការរក្សាទុកប្រាក់ចំណាយបានពីទេសចរណ៍នៅមូលដ្ឋាន។

### បញ្ហាទី ៣ : បរិស្ថាន និងសោភ័ណភាពក្រុងមិនល្អ

កំណើនទេសចរណ៍នាំមកនូវបញ្ហាដីធ្លី និងការអភិវឌ្ឍន៍សណ្ឋាគារ និងផ្ទះសំណាក់យ៉ាងរាលដាល និងគ្មានសណ្តាប់ធ្នាប់ ដែលការនេះអាចនាំឱ្យរំខានដល់បរិយាកាសអង្គរ។ ភ្ញៀវបុគ្គលសាមញ្ញម្នាក់ៗយល់ឃើញថា វិថីសំខាន់ៗក្នុងក្រុងពុំមានសុវត្ថិភាពគ្រប់គ្រាន់សំរាប់ដើរកំសាន្ត។ ជាងនេះទៀត តាមការសិក្សាអង្កេតរបស់ក្រុមសិក្សាឱ្យដឹងថា ភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់មិនពេញចិត្តនឹងសុវត្ថិភាព និងភាពស្រស់ស្អាតរបស់ក្រុងទេ។ ប្រការនេះគឺជាគំលាតដ៏ធំរវាងរមណីយដ្ឋានអង្គរដ៏អស្ចារ្យ និងក្រុង ដែលមិនគួរឱ្យចង់ទស្សនា និងស្នាក់នៅ។ ភ្ញៀវទេសចរជាច្រើននិយមត្រឡប់ចូលសណ្ឋាគារវិញ បន្ទាប់ពីទស្សនារមណីយដ្ឋានអង្គរ។ ទេសចរណ៍គុណភាពមិនអាចមាននិរន្តរភាពឡើយ ប្រសិនបើគ្មានបរិយាកាសក្រុងប្រកបដោយគុណភាពខ្ពស់។ ភ្ញៀវទេសចរដែលមកទស្សនាសៀមរាបរំពឹងថានឹងបានឃើញរមណីយដ្ឋានអង្គរដ៏អស្ចារ្យក្នុងព្រៃជ្រៅ ស្វែងយល់វប្បធម៌ និងប្រជាជនខ្មែរ ព្រមទាំងបានកំដរអារម្មណ៍ជាមួយនឹងបរិយាកាសអង្គរដ៏អស្ចារ្យ បន្ទាប់ពីបានទស្សនារួច។

### បញ្ហាទី ៤ : ភាពមិនច្បាស់លាស់នៃនិរន្តរភាពបរិស្ថាន

ទី ១ : តំបន់កណ្តាលក្រុង ដែលជាតំបន់សណ្ឋាគារមានបញ្ហាជំនន់រាំរ៉ៃ សំរាមនៅតាមទីសាធារណៈ និងសំណល់រាវ។ ទី ២ : និរន្តរភាពនៃធនធានធម្មជាតិមានលក្ខណៈមិនច្បាស់លាស់ ជាពិសេស ការពឹងផ្អែកយ៉ាងខ្លាំងលើទឹកស្អាតក្រោមដី អាចបង្កលទ្ធភាពគ្រោះថ្នាក់នៃការបាក់ស្រុតដី។ ទាំងនេះគឺជាគ្រោះគំរាមកំហែងដល់និរន្តរភាពនៃទេសចរណ៍។

### បញ្ហាទី ៥ : កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ

កំណើនយ៉ាងលឿននៃភ្ញៀវទេសចរបានបង្កើតជាបន្ទុកធ្ងន់ធ្ងរដល់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលមានស្រាប់។ ភ្ញៀវទេសចរប្រើប្រាស់ និងបញ្ចេញចោលទឹក និងទំនិញផ្សេងៗច្រើនជាងប្រជាជនក្នុងស្រុកធម្មតាយ៉ាងលើសលប់។ ជាពិសេស នៅរដូវដែលមានភ្ញៀវទេសចរច្រើន តំរូវការរបស់ភ្ញៀវទេសចរបានបង្កើតជាសំពាធយ៉ាងខ្លាំងមកលើសមត្ថភាពនៃហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន ដូចជា ការផ្គត់ផ្គង់ទឹក មធ្យោបាយដឹកជញ្ជូន និងអគ្គិសនី។

### បញ្ហាទី ៦ : សមត្ថភាពគ្រប់គ្រងការអភិវឌ្ឍន៍របស់មូលដ្ឋាននៅមានកំរិត

សមត្ថភាពកំណត់លើការងារអភិវឌ្ឍន៍កើតមាន ដោយសារកង្វះខាតនៃការសំរបសំរួល និងអភិបាលកិច្ចរបស់មូលដ្ឋាន។ មូលដ្ឋានហិរញ្ញវត្ថុនៅមូលដ្ឋានមានភាពទន់ខ្សោយ។ ក្រៅពីនេះ មូលដ្ឋានធនធានមនុស្សនៅថ្នាក់ខេត្ត និងស្រុកក៏មានភាពទន់ខ្សោយផងដែរ ជាពិសេស ការគ្រប់គ្រង និងត្រួតពិនិត្យតាមដានការងារសាធារណការ ការគ្រប់គ្រងដីធ្លី ប្រព័ន្ធព័ត៌មាន និងការគ្រប់គ្រងថវិកា។

ដោយផ្អែកលើការរៀបរាប់ខាងលើ ខាងក្រោមនេះគឺជារចនាសម្ព័ន្ធបញ្ហាទាំង ៦ ។



រូបទី ៤ : រចនាសម្ព័ន្ធបញ្ហានៅសៀមរាប

## ៣. ចក្ខុវិស័យជាយុទ្ធសាស្ត្រ

"ចក្ខុវិស័យជាយុទ្ធសាស្ត្រ" គឺជារបៀបវារៈសាមញ្ញមួយសំរាប់ចែករំលែករវាងភាគីពាក់ព័ន្ធទាំងអស់ ។ ចក្ខុវិស័យជាយុទ្ធសាស្ត្រនេះគឺជាតំណាងក្រុងសៀមរាប/អង្គរតាមឆ្នាំគោលដៅ និងជាមាគ៌ាសំរាប់នាំទៅសំរេចទិសដៅរបស់ក្រុង។ ចក្ខុវិស័យជាយុទ្ធសាស្ត្រនេះមានលើកឡើងអំពីគោលបំណង សេណារីយូ ក្រុងសៀមរាប/អង្គរនៅឆ្នាំ២០២០ និងយុទ្ធសាស្ត្រសំខាន់ទាំង៦។

### ៣.១ គោលបំណងនៃផែនការមេ

គោលបំណងផែនការមេនេះគឺ ដើម្បីធ្វើឱ្យសំរេចការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាពរហូតដល់ឆ្នាំ២០២០ តាមរយៈវិធានការទាំងឡាយដូចខាងក្រោម :

- លើកកំពស់វិស័យទេសចរណ៍តាមវិធីមួយដែលមាននិរន្តរភាព
- លើកកំពស់ និងពង្រីកសេដ្ឋកិច្ចមូលដ្ឋាន ដោយផ្អែកលើវិស័យទេសចរណ៍
- អភិរក្ស និងកែលំអបរិស្ថាន និង
- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងរដ្ឋបាល ។

## ៣.២ សេណារីយូ

ដោយមានការគិតឃើញថា កំណើនទេសចរណ៍បែបគ្មាននិរន្តរភាពបច្ចុប្បន្ននឹងត្រូវកែសំរួល ដើម្បីឱ្យមានតុល្យភាព និងនិរន្តរភាពច្រើនឡើង សេណារីយូពីរខាងក្រោមត្រូវបានរៀបចំឡើងដោយធ្វើការយកចិត្តទុកដាក់ជាពិសេសទៅលើទំហំ និងទំរង់ទេសចរណ៍សមស្រប។ ផ្អែកលើសេណារីយូទាំងពីរ ក្រុមសិក្សាបានព្យាយាមធ្វើការប៉ាន់ស្មានពីចំនួនភ្ញៀវទេសចរ និងចំនួនប្រជាជនក្នុងឆ្នាំ២០១២ និង២០២០។

- សេណារីយូ ក : សេណារីយូកំណើនតាមនិន្នាការ
- សេណារីយូ ខ : សេណារីយូកំណើនសមស្រប

**ចំនួនភ្ញៀវទេសចរ**

ចំនួនភ្ញៀវទេសចរត្រូវបានប៉ាន់ស្មានថានឹងកើនឡើងតាមការគិតទុករបស់ UNESCO-APSARA-AFD រហូតដល់ឆ្នាំ២០១២ សំរាប់សេណារីយូទាំងពីរ។ តាមការប៉ាន់ស្មានសំរាប់សេណារីយូទាំងពីរ ក្រុមសិក្សាធ្វើការប៉ាន់ស្មានពីចំនួនភ្ញៀវទេសចរពីរប្រភេទក្រោយពីឆ្នាំ២០១២ ថា ចំនួនភ្ញៀវទេសចរនឹងប្រហែលជាមាននិន្នាការតាមអត្រាកំណើនទេសចរណ៍ដូចគ្នានឹងការសង្កេតនៅតាមតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនានាក្នុងតំបន់អាស៊ីអាគ្នេយ៍។ កំណើននេះអាចគណនាដោយប្រើអត្រាកំណើនជាភាគរយចំនួនលេខមួយខ្ទង់ ក្រោយពីមានអត្រាកំណើនជាភាគរយចំនួនលេខពីរខ្ទង់នៅពេលដំបូង។

តារាង ២ : កន្លែងទេសចរណ៍នៅតាមតំបន់ប្រវត្តិសាស្ត្រនៅអាស៊ីអាគ្នេយ៍ និងនៅសៀមរាប

| តំបន់ប្រវត្តិសាស្ត្រសំខាន់ៗនៅអាស៊ីអាគ្នេយ៍ | ចំនួនប្រជាជន (១000) | ទេសចរអន្តរជាតិ (១000) | អត្រាធៀបនៃទេសចរ/ប្រ.ជ | អត្រាកំណើន | |
|---|---|---|---|---|---|
| | | | | ១៥ ឆ្នាំមុន | ៥ ឆ្នាំមុន |
| ឈៀងម៉ៃ ប្រទេសថៃ | 400 | 1.800 | 4,5 | 8,4% | 7,8% |
| សុខូតៃ ប្រទេសថៃ | 590 | 208 | 0,4 | 0,7% | -8,2% |
| អាយុធ្យា ប្រទេសថៃ | 150 | 988 | 6,6 | 8,0% | 3,0% |
| បុរបឌួរ ប្រទេសឥណ្ឌូនេស៊ី | 400 | 241 | 0,6 | 10,7% | -1,7% |
| មធ្យមភាគ | 385 | 809 | 3,0 | 7,0% | 0,2% |
| សៀមរាប 2004 | 139 | 561 | 4,0 | 53%* | 38% |
| សេណារីយូ ក 2020 | 211 | 3.342 | 15,8 | 11,8%** | 8,3%*** |
| សេណារីយូ ខ 2020 | 211 | 2.007 | 9,5 | 9,0%** | 3,6%*** |

* 7 ឆ្នាំមុន យោងតាមទិន្នន័យរកបាន
**16 ឆ្នាំ (2005-2020)
*** 10 ឆ្នាំ (2011-2020)

**ចំនួនប្រជាជន**

ការព្យាករណ៍ពីចំនួនប្រជាជនធ្វើឡើង ដោយផ្អែកទៅលើការបំបែកទិន្នន័យថ្នាក់ខេត្តស្តីពី "ការពិនិត្យឡើងវិញពីការព្យាករណ៍ចំនួនប្រជាជនកម្ពុជាសំរាប់ឆ្នាំ២០០១-២០២១" ផ្អែកលើនិន្នាការនៃការប្រែប្រួលរបាយប្រជាជននៅតាមស្រុកក្នុងខេត្តសៀមរាប និងផ្អែកលើគោលនយោបាយរបស់រដ្ឋាភិបាល ដែលមិនអនុញ្ញាតឱ្យមានកំណើនប្រជាជនក្នុងតំបន់ការពារទី១ និងទី២។

ការងារពីវិស័យទេសចរណ៍មួយចំនួនដែលអាចកើតមានពីការព្យាករណ៍នៃភ្ញៀវទេសចរត្រូវធ្វើ ដោយប្រជាជនដែលរស់នៅក្រៅស្រុកសៀមរាប ប៉ុន្តែធ្វើដំណើរចូលស្រុកដើម្បីធ្វើការងារប្រចាំថ្ងៃ។

ក្រុមសិក្សាបានព្យាយាមធ្វើការប៉ាន់ស្មានផ្សេងៗនូវតំរូវការប្រើប្រាស់ទឹក និងអគ្គិសនី របស់ប្រជាជនមូលដ្ឋាន និងភ្ញៀវទេសចរ និងបន្ទុកបរិស្ថានដែលកើតចេញពីតំរូវការទាំងនោះដើម្បីវាយតម្លៃពីលទ្ធផលនៃសេណារីយូទាំងពីរដូចមាន

បង្ហាញក្នុងតារាងខាងក្រោម ។

តារាង ៣ : ការប្រៀបធៀបសេណារីយូទាំងពីរ

| សូចនាករ | | ឆ្នាំមូលដ្ឋាន | សេណារីយូ (ក): ការព្យាករណ៍កំណើនតាមនិន្នាការ | | សេណារីយូ (ខ): ការព្យាករណ៍កំណើនមធ្យម | |
|---|---|---|---|---|---|---|
| | | 2004 | 2012 | 2020 | 2012 | 2020 |
| ចំនួនប្រជាជនក្នុងស្រុក (1000 នាក់ ) | | 139 | 171 | 211 | 171 | 211 |
| ប្រ.ជ ធ្វើដំណើរចូលស្រុកដើម្បីធ្វើការងារ (1000 នាក់) | | 16 | 44 | 100 | 39 | 65 |
| ចំនួនភ្ញៀវទេសចរ (1000 នាក់/ឆ្នាំ) | សរុប | 858 | 2.324 | 4.331 | 2.220 | 2.802 |
| | អន្តរជាតិ | 561 | 1.709 | 3.343 | 1.648 | 2.007 |
| | ក្នុងស្រុក | 297 | 614 | 988 | 572 | 795 |
| តម្រូវការសំរាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានា | ការប្រើប្រាស់ទឹកនៅរដូវមានភ្ញៀវច្រើន (1000ម³/ថ្ងៃ) | 9,0 | 20 | 34 | 19 | 28 |
| | តម្រូវការភ្លើងច្រើនបំផុត (MW) | 33 | 72 | 117 | 61 | 74 |
| ផលប៉ះពាល់បរិស្ថានដែលបានព្យាករណ៍ | សំណល់រាវ (BOD: គ.ក្រ/ថ្ងៃ) | 6.364 | 8.199 | 10.663 | 8.172 | 10.141 |
| | ការបូមទឹកក្រោមដីរបស់ឯកជន (1000ម3/ថ្ងៃ) | 7,0 | 10 | 24 | 9 | 18 |
| | បរិមាណសំណល់រឹង (តោន/ថ្ងៃ) | 99 | 177 | 323 | 176 | 295 |
| | SOX ((តោន/ឆ្នាំ) | 35 | 94 | 162 | 77 | 97 |
| ឥទ្ធិពលលើសេដ្ឋកិច្ច: មូលដ្ឋាននៃការប្រើប្រាស់ លានដុល្លារ/ឆ្នាំ | | 172 | | 1.023 | | 771 (1.243*) |

* តួលេខនៅក្នុងវង់ក្រចកបញ្ជាក់ពីឥទ្ធិពលលើសេដ្ឋកិច្ចដែលមានសមាសភាពភ្ញៀវទេសចរបុគ្គល និងមានការចំណាយខ្ពស់

ប្រភព : ក្រុមសិក្សា

តម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងប្រើប្រាស់ ដូចជា ទឹក ភ្លើង និងបន្ទុកបរិស្ថានក្នុងសេណារីយូកំណើនមធ្យមមានចំនួនតិចជាងសេណារីយូកំណើនតាមនិន្នាការ ប៉ុន្តែសេណារីយូ ខ នេះផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចតិចជាងសេណារីយូ ក។ ផ្ទុយទៅវិញ សេណារីយូ ខ នឹងផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចច្រើនលើសលប់ ប្រសិនបើសមាសភាពភ្ញៀវទេសចរជាភ្ញៀវទេសចរបុគ្គល និងភ្ញៀវទេសចរដែលមានការចំណាយខ្ពស់ ។

ការប្រៀបធៀបនេះបានធ្វើឡើងដោយគិតគូរសំខាន់ទៅលើសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ បញ្ហាបរិស្ថាន និងទេសចរណ៍។ បើពិនិត្យទៅលើគំនិតទាំងឡាយដូចមានបង្ហាញក្នុងតារាងខាងក្រោម សេណារីយូកំណើនមធ្យមមានផលប្រយោជន៍យ៉ាងច្រើន។ ដូចនេះ ក្រុមសិក្សាបានស្នើឱ្យជ្រើសរើសសេណារីយូកំណើនមធ្យមសំរាប់ការអភិវឌ្ឍន៍ស្រុកសៀមរាបប្រកបដោយនិរន្តរភាព ។

តារាង ៤ : ការវាយតម្លៃសេណារីយូពីរ

| វិស័យ | សេណារីយូ ក | សេណារីយូ ខ |
|---|---|---|
| សេដ្ឋកិច្ចជាតិ | ចូលរួមចំណែកយ៉ាងច្រើនដល់ការកាត់បន្ថយបំរែបំរួលពាណិជ្ជកម្ម | ចូលរួមចំណែកយ៉ាងច្រើនដល់ការកាត់បន្ថយបំរែបំរួលពាណិជ្ជកម្ម |
| សេដ្ឋកិច្ចតំបន់ | កំណើនខ្ពស់ ប៉ុន្តែមិនឋិតឋេរ | កំណើនខ្ពស់ ហើយឋិតឋេរ |
| បរិស្ថាន | លំបាកគ្រប់គ្រង | អាចគ្រប់គ្រងបាន |
| គុណភាពទេសចរណ៍ | អាចធ្លាក់ចុះ | អាចគ្រប់គ្រងបាន |
| ភាពប្រកួតប្រជែង | គ្មានភាពប្រកួតប្រជែង ( បើយោងតាមនិន្នាការពីអតីតកាលនៃតំបន់ទេសចរណ៍នៅអាស៊ីអាគ្នេយ៍) | ប្រកួតប្រជែង |

### ៣.៣ ក្រុងសៀមរាប/អង្គរ ឆ្នាំ២០២០

ការបង្កើតឱ្យមានចក្ខុវិស័យមួយគឺជាការចាំបាច់ ដែលស្ថាប័នរដ្ឋាភិបាល ផ្នែកជំនួញ និងសហគមន៍មូលដ្ឋានអាចចែករំលែកចំណេះដឹងរួមមួយ ដើម្បីធ្វើឱ្យក្រុងសៀមរាប/អង្គរមានតម្លៃ និងមានការទាក់ទាញដល់ភ្ញៀវទេសចរ រួមមានទាំងការស្នាក់នៅ ការទស្សនាកំសាន្ត និងការវិលត្រឡប់មកទស្សនាម្ដងទៀត។ អាស្រ័យហេតុនេះ ចក្ខុវិស័យដែលបានបង្កើតឡើងនោះគួរតែជាយុទ្ធសាស្ត្រមួយ ដើម្បីលើកទឹកចិត្តគ្រប់ភាគីទាំងអស់ គិតពិចារណា និងធ្វើការងាររួមគ្នាយូរអង្វែង។

ដូចនេះ យើងបង្កើតចក្ខុវិស័យមួយសំរាប់ក្រុងសៀមរាប/អង្គរនៅឆ្នាំ២០២០ ដែលមានខ្លឹមសារដូចខាងក្រោម :

"ក្រុងទេសចរណ៍ដ៏ល្អ និងមានតែមួយគត់ដោយផ្អែកលើប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ និងលក្ខណៈខ្មែរ"។

ដោយឈរលើទស្សនៈនេះ ក្រុងសៀមរាប/អង្គរនឹងត្រូវមានលក្ខណសម្បត្តិដូចតទៅ :

១. ក្រុងទេសចរណ៍គុណភាពមួយ ដែលភ្ញៀវទេសចរអាចមានអារម្មណ៍ជិតស្និទ្ធទៅនឹងវប្បធម៌ ប្រវត្តិសាស្ត្រ និងសិល្បៈខ្មែរ។

សៀមរាបនឹងត្រូវកែប្រែឱ្យទៅជាកន្លែងមួយដែលភ្ញៀវទេសចរផ្សេងៗធ្វើការស្នាក់នៅយូរ និងទស្សនាកន្លែងប្រវត្តិសាស្ត្រច្រើនកន្លែងគ្រប់រដូវកាល។ តាមរយៈការទស្សនាកំសាន្តគ្រប់រដូវកាលនេះ ស្រុកសៀមរាបអាចកាត់បន្ថយកំរិតឡើងចុះខុសគ្នាខ្លាំងនៃចំនួនភ្ញៀវទេសចរនៅតាមរដូវកាល និងធានាឱ្យមាននិរន្តរភាពទេសចរណ៍។ ពេលនោះ សៀមរាបនឹងក្លាយជាមជ្ឈមណ្ឌលសេដ្ឋកិច្ចតំបន់។ នៅក្នុងក្រុងទេសចរណ៍គុណភាព :

- ភ្ញៀវទេសចរបរទេសប្រមាណជាពីរលាននាក់នឹងមកទស្សនាទីនេះ ហើយភ្ញៀវភាគច្រើនស្នាក់នៅច្រើនថ្ងៃជារៀងរាល់ឆ្នាំ
- ភ្ញៀវទេសចរនឹងមិនត្រឹមតែជាភ្ញៀវធ្វើដំណើរកំសាន្តជាក្រុម និងភ្ញៀវដើរកំសាន្តគ្មានផែនការច្បាស់លាស់ប៉ុណ្ណោះទេ ប៉ុន្តែក៏មានភ្ញៀវធ្វើដំណើរជាបុគ្គល ជាគ្រួសារ និងជាភ្ញៀវដែលមានកំរិតចំណាយខ្ពស់ផងដែរ
- ភ្ញៀវដែលស្នាក់នៅច្រើនថ្ងៃ ប្រហែលជាអាចមកទស្សនាម្ដងទៀត ដោយមានបំណងស្វែងយល់បន្ថែមទៀតអំពីប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរ
- ភ្ញៀវទេសចរនឹងទទួលអារម្មណ៍រីករាយជាមួយបរិយាកាសក្រុង តាមរយៈការបរិភោគ ការទិញទំនិញ និងការសំរាកកំសាន្ត។ ការនេះនឹងធ្វើឱ្យប្រជាជននៅមូលដ្ឋានច្រើននាក់ទទួលផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍។

២. ក្រុងដែលមានចំនួនមនុស្សសមរម្យ សមស្របទៅនឹងបរិយាកាសអង្គរ

ក្រុងសៀមរាបគឺជាមូលដ្ឋានរួមសំរាប់ភ្ញៀវទេសចរទស្សនាកំសាន្តរមណីយដ្ឋានអង្គរ។ វាជាក្រុងមានពណ៌បៃតង និងជាក្រុងស្ថិតក្នុងបរិយាកាសអង្គរ។ ក្រុងទាំងមូលត្រូវតែមានសុវត្ថិភាព ស្អាត ងាយស្រួលធ្វើដំណើរ និងមានផាសុកភាពសំរាប់ការស្នាក់នៅរបស់ភ្ញៀវទេសចរ និងការរស់នៅរបស់ប្រជាជនក្នុងស្រុក។ ក្រុងដែលមានប្រជាជនសមស្រប :

- ប្រជាជនចំនួន ២១០.០០០ នាក់នឹងរស់នៅក្នុងក្រុង។ ជាងនេះទៀត ប្រជាជនប្រមាណជា ៦៥.០០០ នាក់មកពី

ស្រុកផ្សេងៗជុំវិញក្រុងនឹងធ្វើដំណើរចូលក្រុងរៀងរាល់ថ្ងៃដើម្បីបំរើការក្នុងវិស័យទេសចរណ៍ និងសកម្មភាពផ្សេងៗទៀត ដោយមិនបណ្ដាលឱ្យមានការពង្រីកការតាំងទីលំនៅដែលប្រាសចាកពីគំរោងការឡើយ

- សកម្មភាពក្រុងនឹងត្រូវតែមានលក្ខណៈសមស្របទៅនឹងសេវាកម្ម និងទឹកភ្លើងសាធារណៈ
- តំបន់តាំងទីលំនៅថ្មីត្រូវតែមានទំហំធំបំផុតគឺ ៤.២៤១ ហិចតា ឬពាងធំជាងទំហំបច្ចុប្បន្ន។ តំបន់នោះមិនត្រូវបង្កើតឡើងក្នុងតំបន់ប្រវត្តិសាស្ត្រ កសិកម្ម ពណ៌បៃតង ឬតំបន់ងាយលិចទឹក និងជំរុញឱ្យមានការពង្រីកក្រុងទៅទិសអាគ្នេយ៍
- មជ្ឈមណ្ឌលក្រុងនឹងមានសុវត្ថិភាព ស្អាត និងផាសុកភាព ដើម្បីឱ្យក្រុងក្លាយជាកន្លែងទេសចរណ៍ដ៏សំខាន់របស់ក្រុង
- នឹងត្រូវរក្សា និងពង្រីកសកម្មភាពកំសាន្ត និងបរិយាកាសរមណីយដ្ឋានអង្គរនៅមុនពេលថ្ងៃលិច និងពេលថ្ងៃលិចសំរាប់ភ្ញៀវទេសចរ និងប្រជាជនមូលដ្ឋាន ពោលគឺកំសាន្តក្នុងព្រៃ និងតាមទិដ្ឋភាពថ្ងៃលិចដ៏អស្ចារ្យ ។

៣. ទីក្រុងដែលមានការយកចិត្តទុកដាក់ដល់បរិស្ថាន

វប្បសម័យអង្គរមានឈ្មោះល្បីល្បាញខាងការប្រើប្រាស់ធនធានដោយនិរន្តរភាព។ ដោយសិក្សាពីភាពវៃឆ្លាតពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនេះ សៀមរាប ដែលជាក្រុងយកចិត្តទុកដាក់លើបរិស្ថាន នឹងត្រូវ :

- ការពារបរិស្ថានក្រុងពីផលប៉ះពាល់អវិជ្ជមានដែលបណ្ដាលមកពីទេសចរណ៍គំហុក និងការពង្រីកក្រុង
- សន្សំ និងកែច្នៃឡើងវិញនូវធនធាន និងថាមពលដើម្បីធ្វើឱ្យក្រុងមាននិរន្តរភាពខាងបរិស្ថាន
- ធ្វើឱ្យក្រុងមានលក្ខណៈស៊ីចង្វាក់គ្នាទៅនឹងលក្ខណៈ និងបេតិកភណ្ឌអង្គរ និង
- ធ្វើឱ្យក្លាយជាក្រុងគំរូមួយក្នុងប្រទេសកម្ពុជា។

ក្រុងដូចនេះគឺជាក្រុងមាននិរន្តរភាព។ សៀមរាបមិនត្រឹមតែជាក្រុងមាននិរន្តរភាពប៉ុណ្ណោះទេ តែថែមទាំងធ្វើការឆ្លុះបញ្ចាំងពីគតិបណ្ឌិតសម័យអង្គរលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព វប្បធម៌សម្បូរបែប និងការចូលរួមរបស់ប្រជាជនក្នុងសតវត្សរ៍ទី២១។ ក្រុងមិនត្រឹមតែជាកន្លែងដែលមានប្រាសាទប៉ុណ្ណោះទេ ប៉ុន្តែជាប្រភពនៃព្រលឹងសកលដែលកំពុងត្រូវបានផ្សព្វផ្សាយទៅកាន់តំបន់ផ្សេងៗទៀតនៃសកលលោក។ សៀមរាបគឺជាក្រុង ដែលមានការទាក់ទាញខាងវប្បធម៌ខ្លាំងបំផុតនៅអាស៊ីអាគ្នេយ៍ផងដែរ។

៣.៤ យុទ្ធសាស្ត្រ

រហូតដល់ឆ្នាំ២០២០ យើងស្នើឡើងនូវយុទ្ធសាស្ត្រ៦ ដូចមានបង្ហាញក្នុងរូបទី៥។ យុទ្ធសាស្ត្រទី១ និងទី២គឺជាចលករជំរុញសេដ្ឋកិច្ចស្រុកសៀមរាប។ យុទ្ធសាស្ត្រទី៣ និងទី៤ត្រូវបានស្នើឡើងដើម្បីរៀបចំមូលដ្ឋានគ្រឹះមួយសំរាប់ការអភិវឌ្ឍន៍សៀមរាបប្រកបដោយនិរន្តរភាព។ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាព ដូចនេះ សៀមរាបត្រូវពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងស្ថាប័នតាមរយៈយុទ្ធសាស្ត្រទី៥ និងទី៦។




ប្រភព : ក្រុមសិក្សា

រូបទី ៥ : យុទ្ធសាស្ត្រសំរាប់សៀមរាប/អង្គរ ឆ្នាំ២០២០

យុទ្ធសាស្ត្រទី ១ : ការលើកកំពស់វិស័យទេសចរណ៍ដោយយកចិត្តទុកដាក់លើភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់

លក្ខណៈទេសចរណ៍បច្ចុប្បន្ននៅសៀមរាបគឺជាទេសចរណ៍ប្រមូលផ្ដុំស្នាក់នៅរយៈពេលខ្លី ដែលទេសចរណ៍ប្រភេទនេះបង្កកំណើនបន្ទុកបរិស្ថាន ផ្ដល់ផលប្រយោជន៍តិចតួចដល់សេដ្ឋកិច្ចមូលដ្ឋាន និងមានទំនាក់ទំនងផ្ទាល់តិចតួចជាមួយនឹងវប្បធម៌ក្នុងស្រុក។ វិធីសាស្ត្រដ៏ចាំបាច់សំរាប់ក្រុងសៀមរាប/អង្គរឆ្នាំ ២០២០ គឺត្រូវបង្កើនឥទ្ធិពលសេដ្ឋកិច្ចវិជ្ជមានរបស់ទេសចរណ៍ទៅលើសេដ្ឋកិច្ចតំបន់ឱ្យដល់កំរិតអតិបរមា និងត្រូវកំណត់បន្ទុកបរិស្ថានឱ្យនៅក្នុងកំរិតមួយសមស្រប។

នៅពេលទទួលបានជោគជ័យលើការ "ការទាក់ទាញភ្ញៀវដែលមានកំរិតចំណាយខ្ពស់"នោះ សៀមរាបនឹងក្លាយជាកន្លែងទេសចរណ៍ដែលមានការទាក់ទាញមិនត្រឹមតែភ្ញៀវទេសចរដែលមានការចំណាយខ្ពស់ប៉ុណ្ណោះទេ ថែមទាំងប្រភេទទេសចរណ៍ផ្សេងៗទៀត។ វិធីសាស្ត្រនេះត្រូវផ្សារភ្ជាប់ជាមួយនឹងការបង្កើនបរិមាណនៃការប្រើប្រាស់ផលិតផល និងសេវាកម្មក្នុងស្រុកផ្សេងៗរបស់ភ្ញៀវទេសចរម្នាក់ៗ កាត់បន្ថយចំនួនភ្ញៀវទេសចរនៅរដូវមានភ្ញៀវទេសចរច្រើន និងពង្រីករយៈពេលនៃការស្នាក់នៅរបស់ភ្ញៀវទេសចរទាំងនោះ ប៉ុន្តែត្រូវមានវិធានការទប់ស្កាត់មិនឱ្យមានវិនិយោគផ្សេងៗ និងការដើរកំសាន្តជារបៀបទេសចរណ៍ប្រមូលផ្ដុំ។ ភ្ញៀវទេសចរបុគ្គល ដែលស្នាក់នៅក្នុងសណ្ឋាគារផ្កាយ៤ ឬខ្ពស់ជាងនេះមានបំណងស្នាក់នៅយូរ និងចំណាយច្រើន។ ទោះជាយ៉ាងនេះក៏ដោយ នាពេលបច្ចុប្បន្ន ភ្ញៀវទេសចរមួយផ្នែកធំគឺជាទេសចរដើរកំសាន្តជាក្រុម និងស្នាក់នៅក្នុងសណ្ឋាគារផ្កាយបីចុះក្រោម។ ភ្ញៀវទេសចរទាំងនោះជ្រើសរើសយកប្រាសាទអង្គរជាទិសដៅកំសាន្តតែមួយគត់ ដែលការនេះនាំឱ្យមានការស្ទះ និងអាចនាំឱ្យបាក់បែកដល់បេតិកភណ្ឌនេះ។

ដើម្បីទាក់ទាញភ្ញៀវទេសចរដែលមានការចំណាយច្រើន ចាំបាច់ត្រូវបំពេញចន្លោះរវាងថាតើភ្ញៀវទេសចរទាំងនោះត្រូវការអ្វី ហើយតើក្រុងសៀមរាប/អង្គរអាចផ្ដល់អ្វីខ្លះដល់ពួកគេ។ ភ្ញៀវទេសចរដែលមានការចំណាយច្រើនទាំងនោះមិនត្រឹមតែចង់មើលប្រាសាទអង្គរតែមួយមុខប៉ុណ្ណោះទេ តែពួកគេចង់ដឹង និងស្វែងយល់ពីប្រជាជនមូលដ្ឋាន វិករាយ

នឹងវប្បធម៌ ព្រមទាំងកំសាន្តក្នុងក្រុង។ ជាងនេះទៀត ពួកគេមានការ យកចិត្តទុកដាក់ខ្លាំងទៅលើបញ្ហាបរិស្ថាន និងមានចិត្តរំភើបរីករាយ ប្រសិនបើការចំណាយទាំងឡាយរបស់គេជួយដល់ការ លើកកំពស់ជីវភាពរបស់ប្រជាជននៅមូលដ្ឋាន និងកិច្ចអភិរក្សវប្បធម៌ខ្មែរ។ ការទាក់ទាញ និងការលើកកំពស់កន្លែង និងសកម្មភាពទាក់ទាញក្រៅពីរមណីយដ្ឋានអង្គរគឺជាការចាំបាច់ ដើម្បីបំពេញចន្លោះខ្វះខាតនេះ។

- ផែនការ និងការគ្រប់គ្រងរួមនៃតំបន់ប្រាសាទអង្គរសំខាន់ៗ ដូចជា ទំហំនៃកន្លែងចត ច្បាប់ចរាចរណ៍ ការឆ្លងកាត់ផ្នែកខាងក្នុងប្រាសាទ រមណីយដ្ឋានផ្សេងៗ និងហាងទំនិញ
- កន្លែង និងសកម្មភាពទាក់ទាញផ្សេងៗទៀត ក្រៅពីប្រាសាទអង្គរមាន :
  - សុវត្ថិភាព អនាម័យ និងវិថីល្អៗក្នុងក្រុង ដែលអាចឱ្យភ្ញៀវទេសចរដើរកំសាន្តក្នុងក្រុង ការទិញទំនិញក្នុងផ្សារ និងបរិភោគអាហារក្នុងបរិយាកាសរីករាយ និងទិដ្ឋភាពក្រុង
  - បរិស្ថានធម្មជាតិមានលក្ខណៈដោយឡែកពិសេសសំរាប់ខេត្តសៀមរាប បឹងទន្លេសាប និងជាពិសេសភ្នំគូលេន
  - មានទំនាក់ទំនងទៅវិញទៅមកជាមួយនឹងជីវភាពរស់នៅ និងវប្បធម៌របស់ប្រជាជនខ្មែរ តាមរយៈដំណើរកំសាន្តនៅតាមភូមិនានា
- ការលើកកំពស់តំលៃវប្បធម៌ និងការអភិវឌ្ឍន៍ផ្លូវសំរាប់ឱ្យភ្ញៀវទេសចរធ្វើដំណើរកំសាន្តនៅតាមតំបន់វប្បធម៌ និងការប្រមូលផ្តុំធនធានវប្បធម៌សំខាន់ៗ ដូចជាពិធីបុណ្យ លំនៅដ្ឋានជនជាតិដើម និងទំនៀមទំលាប់នៅមូលដ្ឋាន
- កែលំអសេវាកម្មទេសចរណ៍ រួមមានការរៀបចំព័ត៌មានសំរាប់ភ្ញៀវទេសចរ មធ្យោបាយដឹកជញ្ជូនក្នុងស្រុក និងការនាំភ្ញៀវ
- ការពង្រីងទីផ្សារ និងលើកកំពស់វិស័យទេសចរណ៍។

**យុទ្ធសាស្ត្រទី ២ : លើកកំពស់ផលប្រយោជន៍មូលដ្ឋានតាមរយៈទេសចរណ៍ឱ្យដល់កំរិតអតិបរមា**

ការកែប្រែទៅរកទេសចរណ៍ដែលមានគុណភាពនឹងមិនត្រឹមតែជួយលើកកំពស់ដល់ឧស្សាហកម្មទេសចរណ៍ប៉ុណ្ណោះទេ តែថែមទាំងជួយដល់សកម្មភាពសេដ្ឋកិច្ចមូលដ្ឋានផ្សេងៗទៀត។ ជាពិសេស ភ្ញៀវទេសចរមកកំសាន្តជាបុគ្គលនាំមកនូវផលប្រយោជន៍សេដ្ឋកិច្ចច្រើនជាងទេសចរជាក្រុម។ ការជំរុញឱ្យមានផលប្រយោជន៍ពីវិស័យទេសចរណ៍ដល់ប្រជាជនមូលដ្ឋានកាន់តែច្រើន គឺជាការចាំបាច់។

- យុទ្ធសាស្ត្រមួយដែលអាចនាំឱ្យទៅរកភាពជោគជ័យបានគឺការផ្សព្វផ្សាយផលិតផលផ្សេងៗក្រោមផ្លាកពាណិជ្ជកម្ម "អង្គរ"។ ក្រុងសៀមរាបអាចទទួលបានផលប្រយោជន៍ពីផលិតផលកាន់តែច្រើនឡើង ប្រសិនបើអ្នកជំនួញក្នុងស្រុក និងកសិករទទួលជោគជ័យក្នុងការលើកកំពស់ និងលក់ផលិតផលរបស់គេ ជាពិសេសទៅឱ្យភ្ញៀវទេសចរដែលមានការចំណាយខ្ពស់
- ជាពិសេស តំបន់ជនបទពុំទាន់មានទំនាក់ទំនងជាមួយនឹងឧស្សាហកម្មទេសចរណ៍ឡើយ ដែលជាហេតុធ្វើឱ្យឧស្សាហកម្មនេះផ្តល់ផលប្រយោជន៍តិចតួចដល់សេដ្ឋកិច្ចមូលដ្ឋាន។ វិធីសាស្ត្រមួយទៀតគឺត្រូវធ្វើសមាហរ-

ណកម្មសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍ដោយផ្អែកលើវិធានការពីរយ៉ាងគឺការលើកកំពស់ទំនិញសហគមន៍តាមរយៈភូមិមួយ ផលិតផលមួយដើម្បីផ្តល់ផលប្រយោជន៍ពីទេសចរណ៍ជាអតិបរមាដល់តំបន់ជនបទ និងការបង្កើតភូមិផលិតកម្មដើម្បីបំរើភ្ញៀវទេសចរនៅតាមផ្លូវកំសាន្ត។

យុទ្ធសាស្ត្រទី ៣ : ការធ្វើឱ្យក្រុងឱ្យកាន់តែមានការទាក់ទាញសំរាប់ភ្ញៀវទេសចរ

តាមទស្សនៈបង្កើតក្រុងឱ្យស៊ីសង្វាក់គ្នាទៅនឹងបរិយាកាសអង្គរ ដែលមានចំនួនមនុស្សសមស្រប និងជាមូលដ្ឋាននៃទេសចរណ៍ដោយផ្អែកលើបេតិកភណ្ឌអង្គរដ៏យូរលង់ "ការធ្វើឱ្យក្រុងកាន់តែមានការទាក់ទាញដល់ភ្ញៀវទេសចរ" ត្រូវបានស្នើឡើងជាយុទ្ធសាស្ត្រមួយ។ យុទ្ធសាស្ត្រមានចំណុចទាំងឡាយដូចខាងក្រោម :

- ការពង្រីកក្រុងគួរតែមានការរៀបចំត្រឹមត្រូវ ដើម្បីបង្កើតក្រុងទំនើបមួយ។ មិនគួរជំរុញឱ្យមានការសាងសង់សណ្ឋាគារនៅគ្រប់ទីកន្លែងនោះទេ។
- ដើម្បីធ្វើឱ្យសំរេចសកម្មភាពទាំងអស់ខាងលើ ភារកិច្ចដ៏ចាំបាច់បំផុតមួយគឺត្រូវបង្កើតក្របខ័ណ្ឌសកម្មភាពដែលមានភាពប្រាកដប្រជា តម្លាភាព និងភាពរឹងមាំសំរាប់ធ្វើផែនការក្រុង។ ត្រូវពង្រឹងសមត្ថភាពធ្វើផែនការក្រុង។ ការអភិវឌ្ឍន៍បណ្តាញផ្លូវថ្នល់ និងប្រព័ន្ធបង្ហូរទឹកជាមុនក៏ជាវិធានមួយក្នុងចំណោមវិធានទាំងឡាយ ដើម្បីតំរង់ទិសនៃការពង្រីកក្រុងដែរ។
- មជ្ឈមណ្ឌលក្រុងនៅតាមស្ទឹងសៀមរាបគួរតែកែលំអឱ្យដល់កំរិតអតិបរមា។ ស្ទឹងនេះគឺជាច្រក យុទ្ធសាស្ត្រមួយក្នុងការលើកកំពស់ការទាក់ទាញភ្ញៀវទេសចរក្នុងតំបន់ក្រុងឱ្យមានភាពរស់រវើក។

យុទ្ធសាស្ត្រទី ៤ : ការធ្វើឱ្យក្រុងកាន់តែមាននិរន្តរភាពខាងបរិស្ថាន

រួមផ្សំជាមួយនឹងការទាក់ទាញរបស់ក្រុង និរន្តរភាពបរិស្ថានគឺជាកត្តាចាំបាច់ក្នុងការធ្វើឱ្យវិស័យទេសចរណ៍កាន់តែមានតុល្យភាព។ តាមរយៈការសិក្សាពីគតិបណ្ឌិតបុរាណអំពីការប្រើប្រាស់ធនធាន ត្រូវមានទិសដៅធ្វើឱ្យសៀមរាបក្លាយជាក្រុងដែលមាននិរន្តរភាពខាងបរិស្ថាន ដែលការនេះនឹងអាចផ្តល់តម្លៃបន្ថែមដល់តំបន់ទេសចរណ៍។

ទី១ : សៀមរាបត្រូវតែការពារបរិស្ថានក្រុងពីផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីទេសចរណ៍គំហុក និងការពង្រីកក្រុង។ ផលប៉ះពាល់អវិជ្ជមានទាំងនោះមានការបំពុលទឹកដោយសារសំណល់រាវ ការបំពុលខ្យល់ដោយសារកំណើនយានយន្ត និងម៉ាស៊ីនភ្លើង និងសំណល់រឹង។ ការបំពុលទាំងនេះធ្វើឱ្យធ្លាក់ចុះនូវវិជ្ជភាពទេសភាព និងស្ថានភាព អនាម័យដែលជាផ្នែកដ៏សំខាន់នៃបរិយាកាសទេសចរណ៍។ តំរូវការអប្បបរមានៃទីក្រុងទេសចរណ៍ដែលមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិគឺភាពស្អាតនៅតាមទីកន្លែងសាធារណៈ ដូចជាផ្លូវថ្នល់ និងស្ទឹង។ ការមានប្រព័ន្ធបង្ហូរទឹកភ្លៀង និង សំណល់រាវ និងការគ្រប់គ្រងសំណល់ល្អគឺជាការចាំបាច់។ ក្រុងគួរតែមាននិរន្តរភាពលើមូលដ្ឋានបរិស្ថានធម្មជាតិ ជាពិសេសធនធានទឹក។ មុននឹងធ្វើប្រព្រឹត្តិកម្មទឹក គួរធ្វើឱ្យមាននិរន្តរភាពបរិស្ថានដោយការកាត់បន្ថយបន្ទុកបរិស្ថាន តាមរយៈការខិតខំប្រឹងប្រែងជាប្រចាំដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាជន និងការអនុវត្តន៍ច្បាប់ឱ្យបានតឹងរឹង។ បើអាចធ្វើបាន យើងសំណូមពឱ្យមានការកាត់បន្ថយបន្ទុកបរិស្ថានមកនៅត្រឹម១០ % ក្នុងអំឡុងពេល១៥ ឆ្នាំខាងមុខ។

ទី២ : សៀមរាបត្រូវតែមានភាពលក្ខណៈសមស្របទៅនឹងបេតិកភណ្ឌអង្គរ និងធម្មជាតិជុំវិញ។ ត្រូវតែការពារសៀមរាបពីផលប៉ះពាល់អវិជ្ជមាន និងត្រូវតែបញ្ចៀសតំបន់បេតិកភណ្ឌទាំងនោះឱ្យផុតពីគ្រោះថ្នាក់នៃការបាក់ស្រុតដី

កំណើនយានយន្តយ៉ាងគំហុកនៅតំបន់ខុឡាន និងការប្រមូលផ្តុំភ្ញៀវទេសចរច្រើនហួសហេតុនៅតាមតំបន់អង្គរវត្ត ។ ជាពិសេស ប្រជាជននៅក្នុងតំបន់ការពារទី១ និងទី២ត្រូវតែអាចរស់នៅបានជាមួយនឹងបេតិកភណ្ឌអង្គរ។

ដោយយកចិត្តទុកដាក់ទៅលើវិធីនានាក្នុងក្រុង និងរមណីយដ្ឋានបេតិកភណ្ឌអង្គរ ក្រុងសៀមរាប/អង្គរគួរតែ :

- បង្កើតអង្គភាពត្រួតពិនិត្យបរិស្ថានដ៏មានប្រសិទ្ធភាពមួយនៅថ្នាក់ខេត្ត
- លើកកំពស់ការកសាងចំណេះដឹងរបស់ប្រជាជនអំពីបរិស្ថាន
- ធានាឱ្យមានមូលនិធិមូលដ្ឋានសំរាប់ការថែទាំបរិស្ថាន
- លើកកំពស់ការធ្វើផែនការដែលយកចិត្តទុកដាក់ខ្ពស់លើបរិស្ថាន
  - លក្ខណវិនិច្ឆ័យក្នុងការធ្វើផែនការក្រុងដោយមានបញ្ចូលស្តង់ដាបរិស្ថានសំរាប់សណ្ឋាគារ
  - កាត់បន្ថយការបំពុលទឹកតាមរយៈការអភិវឌ្ឍន៍ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ
  - ការប្រមូលសំណល់រឹង និងការធ្វើប្រព្រឹត្តិកម្មសំណល់រាវ ជាពិសេសតំបន់សាធារណៈ និងតំបន់តាំងទីលំនៅ
  - កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីនភ្លើង តាមរយៈការផ្គត់ផ្គង់អគ្គិសនីពីសាធារណៈឱ្យបានច្រើន
  - កាត់បន្ថយការបូមទឹកពីក្រោមដីរបស់ឯកជនតាមរយៈការពង្រីក និងជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មីរបស់ក្រុង និង
  - ការលើកកំពស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថានក្នុងរមណីយដ្ឋានបេតិកភណ្ឌ

### យុទ្ធសាស្ត្រទី ៥ : ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវទេសចរ និងប្រជាជន

ហេដ្ឋារចនាសម្ព័ន្ធគួរតែត្រូវបានពង្រឹង និងលើកកំពស់ឱ្យដល់កំរិត សំរាប់បំរើវិស័យទេសចរណ៍ សេដ្ឋកិច្ច និងបរិស្ថាននៅសៀមរាប ដែលជាក្រុងទេសចរណ៍អន្តរជាតិមួយ ។ ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវតែពង្រឹងជាសំខាន់នោះរួមមានការផ្គត់ផ្គង់ទឹក ផ្លូវថ្នល់ ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ ការគ្រប់គ្រងសំណល់រឹង និងអគ្គិសនី។

ហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុកសៀមរាបត្រូវបានប្រើប្រាស់ដោយមនុស្សពីរក្រុមផ្សេងគ្នាគឺក្រុមភ្ញៀវទេសចរ និងប្រជាជនមូលដ្ឋាន។ ការវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធនឹងមិនអាចគេចផុតពីការយកចិត្តទុកដាក់ដល់ទេសចរណ៍ឡើយ ដោយសារថា ទេសចរណ៍គឺជាមូលដ្ឋានសេដ្ឋកិច្ចក្នុងខេត្តសៀមរាបមានការរីកចំរើនរហ័ស និងអាចឱ្យវិនិយោគិនទទួលបានដើមទុនមកវិញលឿន។ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសាធារណៈមួយចំនួននឹងត្រូវផ្តល់ និងថែទាំ ដោយវិនិយោគិនឯកជនតាមរយៈដៃគូរដ្ឋ-ឯកជន ដោយសារសមត្ថភាពខាងហិរញ្ញវត្ថុមានកំណត់ និងការគ្រប់គ្រងរបស់អាជ្ញាធរនៅមូលដ្ឋាននៅមានកំរិត។ គេគួរតែចែងឱ្យបានច្បាស់ថា ការរៀបចំដៃគូរដ្ឋ-ឯកជនដូចនេះគួរតែធ្វើឡើង ដោយឈរលើមូលដ្ឋានប្រកួតប្រជែង និងតម្លាភាព។

### យុទ្ធសាស្ត្រទី ៦ : ការពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន

មូលដ្ឋានសំខាន់ចាំបាច់មួយទៀតដែលជាផ្នែកស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច និងបរិស្ថានគឺការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន។ គេគួរតែពន្លឿនគំនិតផ្តួចផ្តើមរបស់អភិបាលខេត្តដែលកំពុងតែអនុវត្ត ដើម្បីពង្រឹងការគ្រប់គ្រងការអភិវឌ្ឍន៍។

- អភិបាលខេត្តត្រូវបង្កើតគណៈកម្មការមួយ ដែលមានសមាជិកមកពីមន្ទីរជំនាញក្នុងខេត្ត និងអាជ្ញាធរអប្សរា ក្នុងគោលបំណងឱ្យភាគីពាក់ព័ន្ធទាំងអស់ចែករំលែកព័ត៌មានអំពីគំរោងដែលកំពុងអនុវត្ត និងដែលបានស្នើឡើងក្នុងខេត្ត
- ពង្រឹងមូលដ្ឋានធនធានមនុស្សទាំងនៅថ្នាក់ខេត្ត ជាពិសេសសំរាប់ការគ្រប់គ្រង និងត្រួតពិនិត្យគំរោងសាធារណការ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ និងប្រព័ន្ធព័ត៌មានដើម្បីជួយទ្រទ្រង់ដល់ការងារសំរបសំរួល និងការគ្រប់គ្រងគណនី
- គួរអនុវត្តច្បាប់ និងបទដ្ឋានច្បាប់ផ្សេងៗ ដោយភាពអត់ធ្មត់ ប៉ុន្តែគ្មានការលើកលែង។ ច្បាប់អាទិភាពសំរាប់ពង្រឹងនោះរួមមានការប្រើប្រាស់ដីសាធារណៈ លិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីយានយន្ត ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន




រូបទី ៦ : តំបន់ទាំងបីនៃសៀមរាប

- គួរបង្កើត និងគ្រប់គ្រងគោលនយោបាយក្រុងឱ្យស្រប ទៅតាមគំនិតផ្តួចផ្តើមរបស់អាជ្ញាធរខេត្ត។

## ៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់

ដើម្បីធ្វើឱ្យសំរេចនូវចក្ខុវិស័យជាយុទ្ធសាស្ត្រ ឆ្នាំ២០២០ ផ្នែកនេះរៀបរាប់អំពីយុទ្ធសាស្ត្រតំបន់ ដែលជាចំណុចអាទិភាពសំរាប់ការអភិវឌ្ឍន៍ឱ្យបានទូលំទូលាយ ។

**ទស្សនៈលើការបែងចែកតំបន់**

តំបន់សៀមរាបត្រូវបែងចែកជាបីតំបន់ ដូចមានបង្ហាញក្នុងរូបទី៦ ។

- តំបន់ក្រុង
- តំបន់ជនបទ/បេតិកភណ្ឌ
- តំបន់ទន្លេសាប

តំបន់ក្រុងគឺជាតំបន់ទាំងឡាយណាដែលនឹងត្រូវអភិវឌ្ឍឱ្យទៅជាតំបន់ក្រុងនៅត្រឹមឆ្នាំ២០២០ ។ គោលគំនិតអភិវឌ្ឍន៍សំរាប់តំបន់នីមួយៗមានបង្ហាញដូចខាងក្រោម :

**<u>គោលគំនិតអភិវឌ្ឍន៍តំបន់ក្រុង</u>**

ការសិក្សានេះរៀបចំគោលគំនិតអភិវឌ្ឍន៍សំរាប់តំបន់ក្រុងឱ្យទៅជា "សៀមរាប : ធ្វើឱ្យក្រុងសៀមរាបកាន់តែមានការទាក់ទាញ" ។

**<u>គោលគំនិតអភិវឌ្ឍន៍តំបន់ជនបទ/បេតិកភណ្ឌ</u>**

តំបន់ជនបទ និងតំបន់បេតិកភណ្ឌមានសារៈសំខាន់ដូចគ្នា និងមិនអាចផ្តាច់ពីគ្នាបានឡើយ ។ ទស្សនៈអភិវឌ្ឍន៍សំរាប់តំបន់នេះគឺ "តំបន់ជនបទ/បេតិកភណ្ឌ : សហគមន៍ជនបទត្រូវមានភាពស៊ីគ្នាជាមួយនឹងបេតិកភណ្ឌ ដែលអាចជួយគាំទ្រដល់ទេសចរណ៍ និងការអភិរក្ស" ។

តាមរយៈគោលគំនិតនេះ ត្រូវអនុវត្តយុទ្ធសាស្ត្រពីរដូចខាងក្រោម :

- អភិវឌ្ឍកសិកម្មនៅតំបន់ជាយក្រុងភាគខាងលិច
- លើកកំពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍ធម្មជាតិ

**<u>គោលគំនិតអភិវឌ្ឍន៍តំបន់បឹងទន្លេសាប</u>**

តំបន់បឹងទន្លេសាបគឺជាតំបន់មួយដែលមិនអាចខ្វះបាន នៅពេលគិតគូរដល់ខេត្តសៀមរាប និងបេតិកភណ្ឌអង្គរ។ ការសិក្សានេះរៀបចំគោលគំនិតអភិវឌ្ឍន៍សំរាប់តំបន់នេះឱ្យទៅជា " បឹងទន្លេសាប : តំបន់ទេសចរណ៍ធម្មជាតិ ដែលមានការការពារ និងប្រើប្រាស់ឱ្យមាននិរន្តរភាពនូវបរិស្ថានធម្មជាតិដ៏សម្បូរបែប " ។

## ៥. ផែនការអភិវឌ្ឍន៍តាមវិស័យ

### ៥.១ ផែនការដើម្បីធ្វើឱ្យសំរេចយុទ្ធសាស្ត្រខាងលើ

យោងតាមយុទ្ធសាស្ត្រខាងលើ ត្រូវមានវិធានការមួយចំនួននៅតាមវិស័យផ្សេងៗ។ ជំពូកនេះឆ្លុះបញ្ចាំងវិធានការដែលត្រូវស្នើឡើងក្នុងផែនការអភិវឌ្ឍន៍តាមវិស័យ ស្របតាមយុទ្ធសាស្ត្រនីមួយៗ។

១. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី១ : "ការលើកកំពស់ទេសចរណ៍ដោយយកចិត្តទុកដាក់លើភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់"

ផែនការអភិវឌ្ឍន៍ទេសចរណ៍គឺជាផ្នែកដ៏សំខាន់របស់យុទ្ធសាស្ត្រនេះ ដែលពាក់ព័ន្ធទៅនឹងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដូចជា មធ្យោបាយដឹកជញ្ជូន និងអគ្គីសនី និងការគ្រប់គ្រងការអភិវឌ្ឍន៍។ ដើម្បីបង្កើតក្រុងទេសចរណ៍គុណភាពមួយ ផែនការអភិវឌ្ឍន៍ទេសចរណ៍ត្រូវមានគោលដៅបង្កើតតំបន់ទេសចរណ៍គុណភាពទៅតាមបរិបទប្រវត្តិសាស្ត្រ និងវប្បធម៌អង្គរ។ សៀមរាបពុំទាន់ត្រូវបានអភិវឌ្ឍន៍រួចរាល់ដើម្បីទាក់ទាញប្រភេទភ្ញៀវទេសចរផ្សេងៗ ដែលមានបំណងស្វែងយល់ស៊ីជំរៅលើប្រវត្តិសាស្ត្រ និងវប្បធម៌អង្គរនៅឡើយទេ។ ទីផ្សារទេសចរណ៍អន្តរជាតិចាត់ទុកក្រុងសៀមរាប/អង្គរជាក្រុងពុំទាន់មានសុវត្ថិភាពគ្រប់គ្រាន់សំរាប់ភ្ញៀវទេសចរបុគ្គលដើរកំសាន្តឡើយ។ កត្តាមួយក្នុងចំណោមកត្តានានានោះគឺថា ទីផ្សារ និងការលើកកំពស់ភាពជាដៃគូរដ្ឋ-ឯកជននៅមានកំរិតខ្សោយ។ យោងតាមយុទ្ធសាស្ត្រទី១នេះមានការស្នើឡើងនូវវិធានការទាំងឡាយដូចខាងក្រោម :

១) អភិវឌ្ឍន៍តំបន់ទេសចរណ៍ និងផ្លូវផ្សេងៗសំរាប់ទស្សនាកំសាន្ត :

ធ្វើការប្រើប្រាស់ឱ្យបានពេញលេញនូវធនធានទេសចរណ៍សំខាន់ៗក្នុងក្រុងសៀមរាប/អង្គរ។ ត្រូវតែបង្កើតតំបន់ទេសចរណ៍ ៤ ជុំ និងត្រូវបញ្ចូលតំបន់ទាំងនោះទៅក្នុងផ្លូវសំរាប់ទស្សនាកំសាន្ត។

- តំបន់បេតិកភណ្ឌអង្គរ : ធ្វើផែនការ និងការគ្រប់គ្រងរួម
- តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពក្រុង : លើកកំពស់សោភ័ណភាព និងបរិយាកាស
- តំបន់ជនបទ និងតំបន់ទន្លេសាប : ទេសចរណ៍តាមភូមិ/ទេសចរណ៍ធម្មជាតិសំរាប់ឱ្យភ្ញៀវទេសចរមានទំនាក់ទំនងជាមួយវប្បធម៌
- តំបន់រមណីយដ្ឋាននៅឆ្ងាយពីប្រាសាទអង្គរ : ត្រូវដាក់បញ្ចូលទៅក្នុងផ្លូវទស្សនាកំសាន្តរបស់ភ្ញៀវ។

ដើម្បីអភិវឌ្ឍន៍តំបន់ទេសចរណ៍តាមតំបន់បេតិកភណ្ឌអង្គរ ក្រុមសិក្សាស្នើឱ្យមានការអភិវឌ្ឍន៍មធ្យោបាយធ្វើដំណើរក្នុងវិស័យមធ្យោបាយធ្វើដំណើរ និងស្នើឱ្យធ្វើការកែលំអលទ្ធភាពធ្វើដំណើរទៅកាន់តំបន់ប្រាសាទផ្សេងៗទៀតដែលស្ថិតនៅឆ្ងាយពីរមណីយដ្ឋានអង្គរ។ ទាក់ទងនឹងសោភ័ណភាពក្រុង និងតំបន់ទេសចរណ៍វប្បធម៌ យុទ្ធសាស្ត្រទី១នេះមានទំនាក់ទំនងគ្នាជាមួយនឹងយុទ្ធសាស្ត្រទី២។ ការបំភ្លឺផ្លូវ និងបេតិកភណ្ឌអង្គរត្រូវបានស្នើឡើងក្នុងវិស័យអគ្គីសនី។

២) ផ្តល់ឱ្យភ្ញៀវទេសចរនូវបទពិសោធន៍ជាក់ស្តែងពីវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ និងលក្ខណៈខ្មែរដ៏សម្បូរបែប :

បង្កើតផ្លូវសំរាប់ដំណើរកំសាន្តជាក់លាក់ និងប្រមូលផ្តុំធនធានវប្បធម៌សំខាន់ៗ ដូចជាពិធីបុណ្យ ផ្ទះជនជាតិដើម និងទំនៀមទំលាប់នៅមូលដ្ឋាន។

៣) កែលំអសេវាកម្ម និងបដិសណ្ឋារកិច្ចដើម្បីឱ្យការស្នាក់នៅរបស់ភ្ញៀវទេសចរប្រកបដោយភាពរីករាយ :

ព័ត៌មានអំពីទេសចរណ៍ មធ្យោបាយដឹកជញ្ជូនក្នុងស្រុក និងការនាំភ្ញៀវទេសចរ ។

៤) ពង្រឹងទីផ្សារ និងការលើកកំពស់ទេសចរណ៍ :

ត្រូវតែធ្វើការពង្រឹងទីផ្សារ និងការលើកកំពស់តាមរយៈភាពជាដៃគូរដ្ឋ-ឯកជនដើម្បីទាក់ទាញភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់ ។

២. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី២ : "លើកកំពស់ផលប្រយោជន៍មូលដ្ឋានតាមរយៈទេសចរណ៍ឱ្យដល់កំរិតអតិបរមា"

ការពង្រីកសិកម្ម និងការលើកកំពស់ផលិតផលក្នុងស្រុកគឺជាផ្នែកដ៏សំខាន់នៃយុទ្ធសាស្ត្រទី២ ដែលមានទំនាក់ទំនងជាមួយនឹងការគ្រប់គ្រងការអភិវឌ្ឍន៍ ។ ការបង្កើតនិមិត្តសញ្ញាអង្គរសំរាប់លើកកំពស់ការផ្គត់ផ្គង់របស់មូលដ្ឋានទៅក្នុងទីផ្សារទេសចរណ៍ត្រូវបានស្នើឡើង ។ ជាមួយគ្នានេះដែរ គេត្រូវយកចិត្តទុកដាក់ពិសេសទៅលើតំបន់ជនបទ ព្រមទាំងស្នើឱ្យគិតគូរដាក់បញ្ចូលសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍តាមរយៈភូមិ១ ផលិតផល១ និងការអភិវឌ្ឍន៍ភូមិផលិតកម្ម ។

១) បង្កើតនិមិត្តសញ្ញាអង្គរសំរាប់ការផ្គត់ផ្គង់ពីមូលដ្ឋានឱ្យបានកាន់តែច្រើនឡើង

២) បញ្ចូលសេដ្ឋកិច្ចមូលដ្ឋានទៅក្នុងវិស័យទេសចរណ៍ ។

ដើម្បីបង្កើតនិមិត្តសញ្ញាផលិតផលអង្គរ ភាពជាដៃគូរដ្ឋ-ឯកជនគឺជាការចាំបាច់ ។ ទីផ្សារពេលយប់ ដែលបានស្នើឡើងក្នុងវិស័យអភិវឌ្ឍន៍ទេសចរណ៍ក៏មានទំនាក់ទំនងទៅនឹងភាពជាដៃគូនេះដែរ ។

៣. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី៣ : "ការធ្វើឱ្យសៀមរាបកាន់តែមានការទាក់ទាញថែមទៀតដល់ភ្ញៀវទេសចរ"

ដើម្បីធ្វើឱ្យសំរេចក្រុងមួយដែលមានចំនួនប្រជាជន ស្របទៅនឹងបរិយាកាសអង្គរ ផែនការអភិវឌ្ឍន៍ក្រុងមានមុខងារសំខាន់មួយ ដែលមានការគាំទ្រពីវិស័យហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងការអភិវឌ្ឍន៍ ។ ខាងក្រោមនេះគឺជាយុទ្ធសាស្ត្រនានាក្នុងផែនការអភិវឌ្ឍន៍ក្រុង ។

១) តំរង់ទិសលើការពង្រីកក្រុង ដើម្បីបង្កើតក្រុងទំនើបមួយ

២) អភិវឌ្ឍតំបន់កណ្ដាលក្រុងសំរាប់ធ្វើជាច្រកយុទ្ធសាស្ត្រសំរាប់លើកកំពស់ការទាក់ទាញភ្ញៀវទេសចរ

៣) ការពង្រីកក្រុងដោយផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ

ដើម្បីតំរង់ទិសលើការពង្រីកក្រុងដើម្បីបង្កើតទីក្រុងទំនើបមួយ ការបង្កើតបណ្ដាញផ្លូវក្នុងក្រុង និងការលើកកំពស់ប្រព័ន្ធបង្ហូរទឹកគឺជាវិធានដ៏សំខាន់ ។ ដើម្បីធ្វើឱ្យក្រុងមានការទាក់ទាញ ផ្លូវសំរាប់ដើរ និងការបំភ្លឺតាមផ្លូវគឺជាការចាំបាច់ ។ ការធ្វើផែនការក្រុងក៏អាចជួយដល់ការពង្រីកក្រុង ព្រមទាំងចូលរួមពង្រឹងផែនការប្រើប្រាស់ដីធ្លី និងសមត្ថភាពធ្វើផែនការគ្រប់គ្រាន់ ។ ដើម្បីធ្វើឱ្យផែនការក្រុងមានប្រសិទ្ធភាព ការកែលំអការគ្រប់គ្រង ដូចជាគណៈកម្មការអភិវឌ្ឍន៍គឺជាការចាំបាច់សំរាប់វាយតំលៃគំរោងអភិវឌ្ឍន៍ដើម្បីឱ្យដឹងថាតើគំរោងនោះស្របទៅតាមផែនការក្រុងឬយ៉ាងណា ។ ការគ្រប់គ្រងព័ត៌មានក៏ជាតំរូវការចាំបាច់ផងដែរដើម្បីពង្រឹងផែនការប្រើប្រាស់ដីធ្លីដោយផ្អែកលើព័ត៌មានសមស្រប ។

## ៤. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី៤ : "ការធ្វើឱ្យក្រុងកាន់តែមាននិរន្តរភាពខាងបរិស្ថាន"

ដើម្បីធ្វើឱ្យក្រុងមួយមានការគិតគូរដល់បរិស្ថាន យុទ្ធសាស្ត្រសមស្របមួយគឺជាការចាំបាច់។ យុទ្ធសាស្ត្រនេះមានៈ ការគ្រប់គ្រងបរិស្ថាន ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រង និងហិរញ្ញវត្ថុ។ វិស័យគ្រប់គ្រងបរិស្ថានលើកឡើងវិធីសាស្ត្រមួយចំនួនដូចខាងក្រោម ដោយធ្វើយ៉ាងណាឱ្យសមស្របទៅនឹងបេតិកភណ្ឌ និងលក្ខណៈអង្គរ និងសំរាប់កាន់បន្ថយធនធាន និងថាមពល។

១) ការកសាងសមត្ថភាពស្ថាប័ន

២) ការលើកកំពស់ការយល់ដឹងអំពីបរិស្ថាន

៣) ផ្តល់ហិរញ្ញវត្ថុដើម្បីការអភិរក្សបរិស្ថាន

៤) ធ្វើផែនការអភិវឌ្ឍន៍ដោយយកចិត្តទុកដាក់ដល់បរិស្ថាន

វិធីសាស្ត្រខាងលើមិនអាចអនុវត្តដាច់ដោយឡែកតែមួយបានទេ ផ្ទុយទៅវិញត្រូវផ្គួបផ្សំជាមួយនឹងវិស័យទេសចរណ៍ ការអភិវឌ្ឍន៍ក្រុង ការគ្រប់គ្រង និងហិរញ្ញវត្ថុ ដូចមានបង្ហាញក្នុងតារាងខាងក្រោម។

| | ភាពសមស្របទៅនឹងបេតិកភណ្ឌ និងលក្ខណៈអង្គរ | ការកាត់បន្ថយធនធាន និងថាមពល |
|---|---|---|
| ទេសចរណ៍ | ការគ្រប់គ្រងរមណីយដ្ឋានអង្គរ (TO-6) | |
| ការអភិវឌ្ឍន៍ក្រុង | ការគ្រប់គ្រងតំបន់បៃតងតាមរយៈផែនការប្រើប្រាស់ដីធ្លី | |
| មធ្យោបាយដឹកជញ្ជូន | ការដឹកជញ្ជូនដោយមិនបំពុលបរិស្ថានតាមរមណីយដ្ឋានបេតិកភណ្ឌ (TR-8, 9) | |
| ធនធានទឹក/ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ | ការគ្រប់គ្រងការយកទឹកក្រោមដី (W-1,2) | ការធ្វើប្រព្រឹត្តិកម្មសំណល់រាវ |
| ការគ្រប់គ្រងសំណល់រឹង | | ការគ្រប់គ្រងសំណល់រឹង<br>កន្លែងចាក់សំរាមអនាម័យ (SW-3) |
| ថាមពល | | ការគ្រប់គ្រងម៉ាស៊ីនភ្លើងឯកជន (P-9) |
| ការគ្រប់គ្រងការអភិវឌ្ឍន៍/ហិរញ្ញវត្ថុមូលដ្ឋាន | ការពង្រឹងច្បាប់ និងបទដ្ឋានទាក់ទងនឹងការយកទឹកក្រោមដី និងម៉ាស៊ីនភ្លើងរបស់បុគ្គល<br>ភាពជាដៃគូរវាងរដ្ឋ-ឯកជនសំរាប់ការគ្រប់គ្រងសំណល់រឹង<br>ការពង្រឹងមូលដ្ឋានហិរញ្ញវត្ថុ<br>ការអភិវឌ្ឍន៍ធនធានមនុស្សទាក់ទងនឹងការគ្រប់គ្រងព័ត៌មានអំពីការបូមទឹកក្រោមដី និងម៉ាស៊ីនភ្លើងរបស់បុគ្គល | |
| ការផ្តល់អំណាចដល់មូលដ្ឋាន | រស់នៅជាមួយនឹងរមណីយដ្ឋានអង្គរ (TR-8, 9) | |

កំណត់សំគាល់ : ចំនួនក្នុងវង់ក្រចកតំណាងចំនួនគំរោងដែលនឹងពិភាក្សានៅផ្នែកខាងក្រោម។

## ៥. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី៥ : "ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវទេសចរ និងប្រជាជន"

ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធត្រូវអនុវត្តចំពោះវិស័យ៥ គឺមធ្យោបាយដឹកជញ្ជូន ធនធាន និងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ និងថាមពល។ ហេដ្ឋារចនាសម្ព័ន្ធជួយដល់វិស័យទេសចរណ៍ក្រុងដែលមានការទាក់ទាញ និងបរិស្ថាន ដូចមានលើកឡើងក្នុងយុទ្ធសាស្ត្រ១-៣។

### ៦. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី៦ : "ការពង្រឹងរដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋាន"

រដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋានរួមមានការគ្រប់គ្រងការអភិវឌ្ឍន៍ ហិរញ្ញវត្ថុមូលដ្ឋាន និងការផ្ដល់សិទ្ធិអំណាចដល់សហគមន៍។ វិស័យទាំងនេះក៏ជួយដល់ វិស័យទេសចរណ៍ ក្រុងដែលមានការទាក់ទាញ និងបរិស្ថាន ដូចមានលើកឡើងក្នុងយុទ្ធសាស្ត្រ ១-៣ដែរ។ វិធីសាស្ត្រសំខាន់រួមមានដូចខាងក្រោម :

១) ការធ្វើឱ្យរដ្ឋបាលមូលដ្ឋានមានភាពរលូន

២) ភាពជាដៃគូថ្មីរវាងផ្នែកជំនួញ ប្រជាជន និងរដ្ឋាភិបាល

៣) ពង្រឹងមូលដ្ឋានហិរញ្ញវត្ថុមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

៤) ពង្រឹងការអនុវត្តន៍ច្បាប់ និងបទដ្ឋានច្បាប់ផ្សេងៗ

៥) ការអភិវឌ្ឍន៍ធនធានមនុស្សនៅមូលដ្ឋាន។

តារាងខាងក្រោមគឺជាសេចក្ដីសង្ខេបយុទ្ធសាស្ត្រនៃផែនការអភិវឌ្ឍន៍តាមវិស័យ។

តារាង ៥ : យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមវិស័យ : ខ្លឹមសាររួម

| ចក្ខុវិស័យជាយុទ្ធសាស្ត្រ | | | ផែនការអភិវឌ្ឍន៍តាមវិស័យ | | |
|---|---|---|---|---|---|
| គោលបំណង | ចក្ខុវិស័យ : ក្រុងសៀមរាប/អង្គរឆ្នាំ ២០២០ | យុទ្ធសាស្ត្រ | សេដ្ឋកិច្ច ការអភិវឌ្ឍន៍ និងបរិស្ថានក្រុង | ហេដ្ឋារចនាសម្ព័ន្ធ | រដ្ឋបាល និងហិរញ្ញវត្ថុ |
| ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពដល់ ឆ្នាំ ២០២០តាមរយៈ:<br>● ការលើកកំពស់ទេសចរណ៍តាមវិធីចិរភាព<br>● លើកកំពស់ និងពង្រីកសេដ្ឋកិច្ច មូលដ្ឋានទាក់ទងនឹងទេសចរណ៍<br>● អភិរក្សបរិស្ថាន<br>● ពង្រឹងសមត្ថភាព | <u>ក្រុងទេសចរណ៍គុណភាព</u><br>● ក្រុងនៃវប្បធម៌ ប្រវត្តិសាស្ត្រ និង សិល្បៈ<br>● មូលដ្ឋានសំរាប់ទេសចរណ៍ រមណីយដ្ឋានអង្គរ<br>● សេវាកម្មប្រកបដោយគុណភាពសំរាប់ការស្នាក់នៅដោយក្ដីរីករាយ | ១.<br>លើកកំពស់ទេសចរណ៍ដោយយកចិត្តទុកដាក់ភ្ញៀវដែលមាន ការចំណាយខ្ពស់ | <u>អភិវឌ្ឍទេសចរណ៍</u><br>● អភិវឌ្ឍន៍ និងពង្រីកផ្លូវធ្វើដំណើរឱ្យបានទូលំទូលាយ<br>– តំបន់ឧទ្យានបេតិកភណ្ឌអង្គរ<br>– តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពក្រុង<br>– តំបន់ជនបទ និងទន្លេសាប<br>– តំបន់រមណីយដ្ឋាននៅឆ្ងាយពីអង្គរ<br>● លើកកំពស់តំលៃវប្បធម៌<br>● កែលំអសេវាកម្ម<br>● ពង្រឹងទីផ្សារ និងការផ្សព្វផ្សាយ | <u>មធ្យោបាយដឹកជញ្ជូន</u><br>● លទ្ធភាពចូលតំបន់បេតិកភណ្ឌ<br>● ការដឹកជញ្ជូនក្នុងឧទ្យានបេតិកភណ្ឌអង្គរ<br><u>ថាមពល</u><br>● បំភ្លឺសំរាប់រមណីយដ្ឋានអង្គរ | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>● ភាពជាដៃគូរវាងរដ្ឋ-ឯកជនសំរាប់លើកកំពស់ទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ |
| | | ២.<br>ពង្រីកផលប្រយោជន៍<br>មូលដ្ឋានជាអតិបរមាពី ទេសចរណ៍ | <u>ការពង្រីកកសិកម្ម និងការផ្សព្វផ្សាយផលិតផលក្នុងស្រុក</u><br>● និមិត្តសញ្ញាអង្គរសំរាប់ការផ្គត់ផ្គង់ផលិតផលក្នុងស្រុកឱ្យបានច្រើនឡើង<br>● គិតគូរបញ្ចូលសេដ្ឋកិច្ចមូលដ្ឋានទៅក្នុងវិស័យទេសចរណ៍<br><u>ការអភិវឌ្ឍន៍ទេសចរណ៍</u><br>● ទីផ្សារទេសចរណ៍ពេលយប់ | | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>● ភាពជាដៃគូរវាងរដ្ឋ-ឯកជនសំរាប់មជ្ឈមណ្ឌលលើកកំពស់ផលិតផលអង្គរ |
| | <u>ក្រុងដែលមានមនុស្សរស់នៅ និងបរិយាកាសអង្គរ</u><br>● បរិយាកាសអង្គរ<br>● ស្អាត សុវត្ថិភាព ផាសុកភាព និងងាយធ្វើដំណើរកំសាន្ត<br>● ក្រុងមានចំនួនមនុស្សសមស្រប | ៣.<br>ធ្វើឱ្យក្រុងកាន់តែមានការទាក់ទាញដល់ ភ្ញៀវទេសចរ | <u>ការអភិវឌ្ឍន៍ក្រុង</u><br>● ការពង្រីកក្រុងតាមគោលដៅដើម្បីបង្កើតជាក្រុងទំនើប<br>● កែលំអមជ្ឈមណ្ឌលក្រុង<br>● អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំរាប់គាំទ្រដល់ការពង្រីកក្រុង | <u>មធ្យោបាយដឹកជញ្ជូន</u><br>● បណ្ដាញផ្លូវសំរាប់គាំទ្រការពង្រីកក្រុង<br>● ផ្លូវដើរកំសាន្ត និងសោភ័ណភាពក្រុង<br>● សុវត្ថិភាពក្រុង<br><u>ប្រព័ន្ធបង្ហូរសំណល់រាវ និងទឹកភ្លៀង</u><br>● ប្រព័ន្ធបង្ហូរទឹកភ្លៀងសំរាប់គាំទ្រការពង្រីកក្រុង<br><u>ថាមពល</u><br>● ភ្លើងតាមផ្លូវ | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>● គណៈកម្មការអភិវឌ្ឍន៍សំរាប់ត្រួតពិនិត្យការអភិវឌ្ឍន៍តាមទស្សនៈផែនការក្រុង<br>● ពង្រឹងផែនការប្រើប្រាស់ដី ការចុះបញ្ជីយានយន្ត និងច្បាប់ចរាចរណ៍<br>● ការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់គ្រប់គ្រងព័ត៌មាន |

| | | | | | |
|---|---|---|---|---|---|
| | <u>ក្រុងដែលយកចិត្តទុកដាក់លើបរិស្ថាន</u><br>● សាកសមទៅនឹងបេតិកភណ្ឌ និងលក្ខណៈអង្គរ<br>● សម្បូរធនធាន និងថាមពល | ៤. ធ្វើឱ្យក្រុងកាន់តែមាននិរន្តរភាពខាងបរិស្ថាន | <u>ការគ្រប់គ្រងបរិស្ថាន</u><br>● កសាងសមត្ថភាពសំរាប់ការគ្រប់គ្រងបរិស្ថាន<br>● ការលើកកំពស់ការយល់ដឹងបរិស្ថាន<br>● ការផ្តល់ហិរញ្ញវត្ថុសំរាប់ការអភិរក្សបរិស្ថាន<br>● ផែនការអភិវឌ្ឍន៍ដោយយកចិត្តទុកដាក់ដល់បរិស្ថាន | <u>មធ្យោបាយដឹកជញ្ជូន</u><br>● ការដឹកជញ្ជូនដោយមានការគិតគូរពីបរិស្ថានក្នុងឧទ្យានបេតិកភណ្ឌអង្គរ<br><u>ធនធានទឹក និងការផ្គត់ផ្គង់ទឹក</u><br>● ការគ្រប់គ្រងលើការបូមទឹកក្រោមដី<br>● ការប្រើប្រាស់ទឹកដោយគិតគូរពីបរិស្ថាន<br><u>ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់</u><br>● ការធ្វើប្រព្រឹត្តិកម្មសំណល់រាវ<br><u>ការគ្រប់គ្រងសំណល់រឹង</u><br>● កន្លែងចាក់សំរាមអនាម័យ និងការកាត់បន្ថយសំណល់រឹង<br><u>ថាមពល</u><br>● ការកាត់បន្ថយម៉ាស៊ីនភ្លើងឯកជន | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>● គណៈកម្មការសំរាប់វាយតំលៃផលប៉ះពាល់ទស្សនៈបរិស្ថាន<br>● ពង្រឹងច្បាប់ និងបទដ្ឋានច្បាប់សំរាប់ការបូមទឹកក្រោមដី និងម៉ាស៊ីនភ្លើងប្រើម៉ាស៊ូត<br>● ពង្រឹងហិរញ្ញវត្ថុសំរាប់បរិស្ថាន<br>● ភាពជាដៃគូរដ្ឋ-ឯកជនដើម្បីគ្រប់គ្រងសំណល់រឹង<br>● ការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់គ្រប់គ្រងព័ត៌មាន<br><u>ការផ្តល់សិទ្ធិអំណាចដល់សហគមន៍</u><br>● ការរស់នៅរបស់ប្រជាជនជាមួយនឹងរណ៍យដ្ឋានអង្គរ |
| | *ក្រុងដ៏ល្អ និងមានតែមួយ ដោយផ្អែកលើ ប្រវត្តិសាស្ត្រ សិល្បៈ និងលក្ខណៈខ្មែរ*<br>● *បង្ហាញពីគតិបណ្ឌិតសម័យអង្គរដើម្បីជាគំរូទៅសតវត្សរ៍ទី២១សំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងភាពសម្បូរបែបខាងវប្បធម៌*<br>● *ការទាក់ទាញដោយសារវប្បធម៌នៅអាស៊ីអាគ្នេយ៍* | ៥. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវទេសចរណ៍ និងប្រជាជន | | <u>មធ្យោបាយដឹកជញ្ជូន</u><br>● បណ្តាញផ្លូវគ្រប់គ្រាន់សំរាប់ភ្ញៀវ និងប្រជាជន<br><u>ធនធានទឹក និងការផ្គត់ផ្គង់ទឹក</u><br>● ការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព និងការផ្គត់ផ្គង់ទឹក<br><u>ការគ្រប់គ្រងសំណល់រឹង</u><br>● ការធ្វើឱ្យក្រុងក្លាយជាទីស្រស់ស្អាត<br><u>ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ</u><br>● ប្រព័ន្ធបង្ហូរសំណល់រាវ និងទឹកភ្លៀងប្រកបដោយនិរន្តរភាពដើម្បីអនាម័យ និងសោភ័ណភាពក្រុង<br><u>ថាមពល</u><br>● ថាមពលដែលអាចទុកចិត្តបានដោយបង្កបន្ទុកបរិស្ថានតិចតួច | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>● ការធ្វើផែនការ ការគ្រប់គ្រង និងការត្រួតពិនិត្យគំរោង<br><u>ការផ្តល់ហិរញ្ញវត្ថុដល់មូលដ្ឋាន</u><br>● មូលនិធិអភិវឌ្ឍន៍សៀមរាប |

| | | | | | |
|---|---|---|---|---|---|
| | | ៦.<br>ពង្រឹងរដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋាន | | | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>● ធ្វើឱ្យរលូននូវរដ្ឋបាលមូលដ្ឋានដោយមានតម្លាភាព និងការទទួលខុសត្រូវ<br>● ភាពជាដៃគូថ្មីរវាងផ្នែកឯកជន ប្រជាជន និងរដ្ឋាភិបាល<br>● ពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានច្បាប់ផ្សេងៗ<br>● អភិវឌ្ឍន៍ធនធានមនុស្សសំរាប់ការអភិវឌ្ឍន៍<br><u>ការផ្តល់ហិរញ្ញវត្ថុដល់មូលដ្ឋាន</u><br>● ពង្រឹងមូលដ្ឋានហិរញ្ញវត្ថុសំរាប់មូលដ្ឋាន<br><u>ការផ្តល់សិទ្ធិអំណាចដល់សហគមន៍</u><br>● ពង្រឹងសមត្ថភាពប្រជាជន |

វិធានការមួយចំនួននៅតាមយុទ្ធសាស្ត្រនីមួយៗដូចបានរៀបរាប់ខាងលើមានទំនាក់ទំនងគ្នា សំរាប់ក្រុងសៀមរាប/អង្គរឆ្នាំ២០២០ ។ ដ្យាក្រាមលំហូរអំពីការអភិវឌ្ឍន៍ខាងក្រោមបញ្ជាក់ពីដំណើរការស្របទៅតាមផែនការមេ ។




ប្រភព : ក្រុមសិក្សា

**រូបទី ៧ : ឌីយ៉ាក្រាមលំហូរអំពីការអភិវឌ្ឍន៍**

## ៥.២ វិស័យអភិវឌ្ឍន៍ក្រុង

១. ស្ថានភាពបច្ចុប្បន្ន

- ការពង្រីកក្រុងគ្មានសណ្ដាប់ធ្នាប់
- គុណភាពទាបនៃបរិស្ថាន កន្លែងទាក់ទាញ និងសោភ័ណភាពក្នុងមណ្ឌលក្រុង
- កំរិតទាបនៃអនាម័យ និងបរិស្ថានរស់នៅក្នុងតំបន់លំនៅដ្ឋាន

២.បញ្ហា

ចំពោះតំបន់ក្រុង

- អភិរក្សស្ថាបត្យកម្មសម័យអាណានិគមបារាំង
- ការធ្វើឱ្យក្រុងមានការទាក់ទាញដល់ភ្ញៀវទេសចរ
- ការកែលំអតំបន់តាំងទីលំនៅដែលមានដង់ស៊ីតេខ្ពស់

ចំពោះតំបន់សំរាប់ពង្រីកក្រុង

- ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់
- ការសាងសង់សណ្ឋាគារគ្មានសណ្ដាប់ធ្នាប់

៣. គោលដៅ

- ធ្វើឱ្យសៀមរាបក្លាយជាក្រុងដែលមានការទាក់ទាញបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

៤. យុទ្ធសាស្ត្រ

- បង្កើតក្រុងទំនើបដោយមានការអនុវត្តន៍ផែនការក្រុងប្រកបដោយប្រសិទ្ធភាពខ្ពស់
- អភិវឌ្ឍឡើងវិញនូវតំបន់ផ្សារចាស់ និងធ្វើសមាហរណកម្មតំបន់នេះ
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវក្នុងក្រុង

៥. គំរោង និងកម្មវិធី

- U-1 លើកកំពស់តំបន់មណ្ឌលក្រុង
- U-2 កសាងសមត្ថភាពធ្វើផែនការក្រុង
- U-3 បង្កើតបញ្ជីសារពើភ័ណ្ឌនៃស្ថាបត្យកម្មប្រវត្តិសាស្ត្រ
- U- 4 អភិវឌ្ឍតំបន់តាំងទីលំនៅ
- U-5 ធ្វើផែនការ និងអនុវត្តតំបន់វប្បធម៌ និងទេសចរណ៍




រូបទី ៨ : ផែនការរួមសំរាប់គំរោង U-1

## ៥.៣ វិស័យគ្រប់គ្រងបរិស្ថាន

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

- យន្តការ និងសមត្ថភាពស្ថាប័នសំរាប់គ្រប់គ្រងបរិស្ថានមិនអាចដោះស្រាយបញ្ហាបរិស្ថាន ដែលបណ្តាលមកពីការពង្រីកក្រុង និងការអភិវឌ្ឍន៍យ៉ាងលឿន
- ពុំមានគំនិតយល់ដឹងខាងបរិស្ថានគ្រប់គ្រាន់សំរាប់ធ្វើផែនការ
- អាកប្បកិរិយារបស់ប្រជាជន និងជំនួញពុំមានការគាំទ្រដល់បរិស្ថាន
- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំរាប់ការអភិរក្សបរិស្ថានមិនអាចទប់ទល់នឹងវិនិយោគខាងជំនួញយ៉ាងឆាប់រហ័ស ។

២. គោលដៅ

ធ្វើការគ្រប់គ្រងបរិស្ថានសមស្របដើម្បីធ្វើឱ្យសៀមរាបកាន់តែមានសោភ័ណភាពឡើង និងបរិស្ថានកាន់តែមាននិរន្តរភាពតាមរយៈ :

- ធ្វើឱ្យក្រុងសៀមរាបកាន់តែស្រស់ស្អាតឡើង សមស្របទៅនឹងលក្ខណៈ និងបេតិកភណ្ឌអង្គរ ជាពិសេសមជ្ឈមណ្ឌលក្រុង និងឧទ្យានបេតិកភណ្ឌអង្គរ
- ធ្វើក្រុងមានការសន្សំសំចៃធនធាន ដោយធ្វើការកាត់បន្ថយបន្ទុកបរិស្ថានមកត្រឹម១០ %។

៣. យុទ្ធសាស្ត្រ

- ពង្រឹងសមត្ថភាពស្ថាប័នលើការគ្រប់គ្រងបរិស្ថានដើម្បីដោះស្រាយបញ្ហាដែលបណ្តាលមកពីការអភិវឌ្ឍន៍យ៉ាងលឿន

- ផែនការអភិវឌ្ឍន៍ដែលគិតគូរពីបញ្ហាបរិស្ថាន
- ជំរុញឱ្យមានការកែប្រែអាកប្បកិរិយាមនុស្សអោយចេះស្រលាញ់បរិស្ថាន
- បង្កើតប្រព័ន្ធហិរញ្ញវត្ថុសំរាប់ការអភិរក្សបរិស្ថាន

៤. កម្មវិធី និងគំរោងអភិវឌ្ឍន៍

- E-1 ពង្រឹងសមត្ថភាពស្ថាប័ន
- E-2 លើកកំពស់ការយល់ដឹងបរិស្ថាន
- E-3 ប្រមូលតំលៃសេវាកម្មជាមួយគ្នានឹងសេវាកម្មសាធារណៈផ្សេងៗទៀត




រូបទី ៩ : លំដាប់នៃកម្មវិធី

## ៩.៤ ការអភិវឌ្ឍវិស័យទេសចរណ៍

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

- ទេសចរណ៍នៅសៀមរាបគឺជាទេសចរណ៍មានលក្ខណៈប្រមូលផ្ដុំ។ នោះគឺជាភ្ញៀវទេសចរថ្នាក់កណ្ដាលដើរកំសាន្តជាក្រុមនៅតាមរមណីយដ្ឋានមួយចំនួន មានចំនួនច្រើនតែរដូវមានភ្ញៀវច្រើន និងស្នាក់នៅរយៈពេលខ្លី
- ទេសចរណ៍ប្រភេទនេះធ្វើឱ្យបរិស្ថានធ្លាក់ចុះ និងគំរាមកំហែងដល់និរន្តរភាពទេសចរណ៍ ផ្ដល់ផលប្រយោជន៍សេដ្ឋកិច្ចតិចតួចដល់ប្រជាជននៅជនបទ ហើយភ្ញៀវទេសចរមានទំនាក់ទំនងតិចតួចជាមួយនឹងវប្បធម៌ក្នុងស្រុក
- សៀមរាបពុំទាន់ត្រូវបានអភិវឌ្ឍរួចរាល់ដើម្បីទាក់ទាញប្រភេទភ្ញៀវទេសចរផ្សេងៗ ដែលមានបំណងស្វែងយល់ស៊ីជំរៅលើប្រវត្តិសាស្ត្រ និងវប្បធម៌អង្គរនៅឡើយទេ

- ទីផ្សារទេសចរណ៍អន្តរជាតិចាត់ទុកក្រុងសៀមរាប/អង្គរជាក្រុងពុំទាន់មានសុវត្ថិភាពគ្រប់គ្រាន់សំរាប់ភ្ញៀវទេសចរបុគ្គលដើរកំសាន្តឡើយ និង
- ការលើកកំពស់ទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍រវាងភាពជាដៃគូរដ្ឋ-ឯកជននៅមានកំរិត ។

២. គោលដៅ

បង្កើតតំបន់ទេសចរណ៍គុណភាពដោយផ្អែកលើបេតិកភណ្ឌអង្គរ

*- សំរាប់ធ្វើឱ្យភ្ញៀវទេសចរទទួលបានបទពិសោធន៍ផ្ទាល់ជាមួយវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ និងរបៀបរស់នៅរបស់ខ្មែរ ដែលមានលក្ខណៈស្របគ្នាទៅនឹងធម្មជាតិសម្បូរបែប ។*

៣. យុទ្ធសាស្ត្រ

- អភិវឌ្ឍតំបន់ទេសចរណ៍ និងផ្លូវទស្សនាកំសាន្តសម្បូរបែប
- ផ្តល់ឱ្យភ្ញៀវទេសចរនូវរសជាតិវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ និងធម្មជាតិរបស់ខ្មែរដ៏សម្បូរបែប
- កែលំអសេវាកម្ម និងបដិសណ្ឋារកិច្ចសំរាប់ឱ្យការស្នាក់នៅរបស់ភ្ញៀវមានភាពសប្បាយរីករាយ
- ពង្រឹងទីផ្សារទេសចរណ៍ និងលើកកំពស់ទេសចរណ៍តាមរយៈភាពជាដៃគូរដ្ឋ-ឯកជនដោយយកចិត្តទុកដាក់ភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់ ។




ប្រភព : ក្រុមសិក្សា JICA

រូបទី ១០ : តំបន់រមណីយដ្ឋានឆ្ងាយពីអង្គរ និងបណ្តាញផ្លូវថ្នល់ទៅកាន់តំបន់ទាំងនោះ

៤. គំរោង និងកម្មវិធីអភិវឌ្ឍន៍

- TO-1 គំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទេសចរណ៍បេតិកភណ្ឌអង្គរ
- TO-2 គំរោងអភិវឌ្ឍន៍ទីផ្សារពេលយប់
- TO-3 កម្មវិធីលើកកំពស់ទេសចរណ៍គុណភាពតាមរយៈភាពជាដៃគូរដ្ឋ-ឯកជន
- TO-4 ការអភិវឌ្ឍន៍ និងការលើកកំពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍ធម្មជាតិ
- TO-5 ពង្រឹងបណ្តាញនាំភ្ញៀវ និងការបង្កើតប្រព័ន្ធនាំភ្ញៀវទំនើប
- TO-6 សិក្សាលំអិតលើលទ្ធភាពទទួលភ្ញៀវទេសចរ និងការគ្រប់គ្រងរមណីយដ្ឋាន ។

**៥.៥ វិស័យពង្រីកកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក**

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

- មានលេចចេញនូវសកម្មភាពជាក្រុមក្នុងចំណោមកសិករ ជាពិសេសជំនួញតាមសហគមន៍
- ទំនាក់ទំនងរវាងផលិតផលក្នុងស្រុកជាមួយផ្នែកទេសចរណ៍នៅមានកំរិត : មានចំណែកតូចនៃផលិតផលក្នុងស្រុកក្នុងទីផ្សារទេសចរណ៍ក្នុងស្រុកសៀមរាប
- ផលិតផលកសិកម្មដែលបានពង្រីកមានសក្តានុពលក្នុងទីផ្សារក្នុងស្រុក និងទីផ្សារទេសចរណ៍ ផ្ទុយទៅវិញកសិករមួយចំនួនជួបប្រទះនឹងកង្វះខាតបទពិសោធន៍លើកសិ-ជំនួញថ្មីៗ ដូចជា បន្លែ សត្វ និងទីផ្សារ កសិកម្ម
- ផលិតផលកែច្នៃដោយដៃនៅមូលដ្ឋាន និងវត្ថុអនុស្សាវរីយ៍មានសក្តានុពលក្នុងហាងទំនិញក្នុងស្រុក និងទីផ្សារនាំចេញ
- សកម្មភាពគាំទ្រពីថ្នាក់ខេត្តមានកំរិតដោយសារកង្វះខាតព័ត៌មាននៃឧស្សាហកម្មជនបទ ធនធានមនុស្សទន់ខ្សោយ និងកង្វះខាតបទពិសោធន៍
- បទពិសោធន៍ប្រកបដោយជោគជ័យនៃគំរោងសាកល្បង "ការតាំងពិព័រណ៌ផលិតផលអង្គរ ឆ្នាំ ២០០៥" ឆ្លុះបញ្ចាំងពីសក្តានុពលនៃទីផ្សារថ្នាក់កណ្តាលនៅមូលដ្ឋានដែលកំពុងមានកំណើន និងផ្តល់ទំនុកចិត្តដល់មន្ត្រីសមភាគី ។

២. គោលដៅ

បង្កើតផ្លាកសញ្ញាអង្គរសំរាប់ការផ្គត់ផ្គង់ផលិតផលក្នុងស្រុកដើម្បីលើកកំពស់ផលប្រយោជន៍សេដ្ឋកិច្ចក្នុងស្រុកពីវិស័យទេសចរណ៍ ។

៣. យុទ្ធសាស្ត្រ

- បង្កើតប្រព័ន្ធគាំទ្រសំរាប់លើកកំពស់ផលិតផលកសិកម្ម និងផលិតផលក្នុងស្រុក
- តំរង់ទិសដៅទៅរកទីផ្សារទេសចរណ៍ ព្រមទាំងទីផ្សារថ្នាក់កណ្តាលដែលកំពុងមានកំណើន
- ពង្រឹងទំនាក់ទំនងរវាងទេសចរណ៍ និងសេដ្ឋកិច្ចមូលដ្ឋាន
- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់លើកកំពស់ផលិតផលកសិកម្ម និងផលិតផលក្នុងស្រុក

៤. គំរោង និងកម្មវិធីអភិវឌ្ឍន៍

- A-1 ការអភិវឌ្ឍន៍ធនធានមនុស្ស និងការបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ (APPC)
- A-2 ចលនាភូមិមួយ ផលិតផលមួយ
- A-3 ការអភិវឌ្ឍន៍ភូមផលិតកម្ម
- A-4 ការតាំងពិព័រណ៏ផលិតផលអង្គរ




រូបទី ១១ : រចនាសម្ព័ន្ធផែនការតាមវិស័យ

## ៥.៦ វិស័យដឹកជញ្ជូន

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

- បណ្តាញផ្លូវថ្នល់មេមិនគ្រប់គ្រាន់ និងចរាចរចង្អៀតនៅតាមផ្លូវជាតិលេខ ៦ នៅក្នុងតំបន់ក្រុង
- លទ្ធភាពកំណត់ក្នុងការធ្វើដំណើរទៅកាន់រមណីយដ្ឋានឆ្ងាយៗ
- កង្វះខាតផ្លូវដែលមានសុវត្ថិភាព និងសោភ័ណភាព
- ការយល់ដឹងពីសាធារណៈលើច្បាប់ចរាចរ
- កង្វះខាតលើការថែទាំផ្លូវ

២. គោលបំណង

- ផ្តល់បណ្តាញផ្លូវ និងមុខងារគ្រប់គ្រាន់សំរាប់ភាពងាយស្រួលនៃការធ្វើដំណើរ
- ធ្វើឱ្យភ្ញៀវទេសចរពេញចិត្តនឹងទស្សនាបេតិកភណ្ឌអង្គរ និងស្នាក់នៅសៀមរាប
- តំរង់ទិសការពង្រីកក្រុង ដោយផ្អែកលើផែនការក្រុង

៣. យុទ្ធសាស្ត្រ

- កែលំអស្ថានភាពរាំងស្ទះ និងបង្កើតបណ្ដាញផ្លូវវណបប្រទាក់ក្រឡាក្នុងតំបន់ក្រុង
- កែលំអស្ថានភាពផ្លូវ និងស្ពានក្នុងតំបន់ក្រុង
- បង្កើតបណ្ដាញផ្លូវសំរាប់តំបន់ពង្រីកក្រុងនៅពេលអនាគត
- លើកកំពស់លទ្ធភាពធ្វើដំណើរទៅកាន់រមណីយដ្ឋានអង្គរផ្សេងៗ
- បង្កើតប្រព័ន្ធថែទាំផ្លូវឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព

៤. គំរោង និងកម្មវិធីអភិវឌ្ឍន៍

- TR-1 គំរោងកែលំអស្ពានពីសម័យបារាំង
- TR-2 គំរោងសាងសង់ផ្លូវវណបប្រទាក់ក្រឡាស្របនឹងផ្លូវជាតិលេខ ៦ ( ជំហាន ១)
- TR-3 កែលំអផ្លូវសន្តិភាពហ៊ុន សែន ( ជំហាន ២)
- TR-4 សាងសង់បញ្ចប់បណ្ដាញផ្លូវវណបប្រទាក់ក្រឡាក្នុងតំបន់ក្រុងរហូតដល់ឆ្នាំ២០១២( ជំហាន ៣)
- TR-5 សាងសង់បញ្ចប់បណ្ដាញផ្លូវវណបប្រទាក់ក្រឡាក្នុងតំបន់ក្រុងរហូតដល់ឆ្នាំ ២០២០ ( ជំហាន ៤)
- TR-6 ការលើកកំពស់ស្ថាប័ន និងយុទ្ធនាការសំរាប់សុវត្ថិភាពតាមផ្លូវថ្នល់
- TR-7 គំរោងស្តារបណ្ដាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌឆ្ងាយៗ
- TR-8 គំរោងចាប់ផ្ដើមការដឹកជញ្ជូនសាធារណៈដែលមិនបំពុលបរិស្ថានក្នុងរមណីយដ្ឋានអង្គរ
- TR-9 គំរោងសាងសង់ផ្លូវសំរាប់ជិះកង់ក្នុងរមណីយដ្ឋានអង្គរ
- TR-10 ការលើកកំពស់ស្ថាប័នសំរាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព




ប្រភព : ក្រុមសិក្សា JICA

រូបទី ១២ : បណ្ដាញផ្លូវសំខាន់ៗ (២០១២)




ប្រភព : ក្រុមសិក្សា JICA

បណ្ដាញផ្លូវសំខាន់ៗ (២០២០)

## ៥.៧ វិស័យធនធានទឹក និងការផ្គត់ផ្គង់ទឹក

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

- កង្វះខាតការគ្រប់គ្រងធនធានទឹក : កង្វះខាតព័ត៌មានគ្រឹះសំរាប់ធ្វើផែនការ កង្វះខាតទិន្នន័យត្រួតពិនិត្យ ផែនការគ្រប់គ្រង និងអនុវត្ត និងក្របខ័ណ្ឌច្បាប់ ។
- ការពឹងផ្អែកខ្លាំងលើការយកទឹកក្រោមដីក្នុងតំបន់កណ្ដាលក្រុងអាចបណ្ដាលឱ្យកំរិតទឹកក្រោមដីធ្លាក់ចុះ និងការបាក់ស្រុតដី
- កង្វះខាតសេវាកម្មផ្គត់ផ្គង់ទឹកសាធារណៈ ដែលធ្វើឱ្យអត្រាគ្របដណ្ដប់ផ្គត់ផ្គង់មានកំរិតទាប

២. គោលដៅ

- អភិវឌ្ឍធនធានទឹកសំរាប់ការផ្គត់ផ្គង់ទឹក កសិកម្ម និងបរិស្ថាន
- លើកកំពស់សមត្ថភាព និងអត្រាគ្របដណ្ដប់នៃសេវាកម្មផ្គត់ផ្គង់ទឹកសាធារណៈ
- គ្រប់គ្រង និងអភិរក្សទឹកក្រោមដី

៣. យុទ្ធសាស្ត្រ

<u>យុទ្ធសាស្ត្រសំរាប់ធនធានទឹក</u>

- អភិវឌ្ឍធនធានទឹកក្របដោយនិរន្តរភាព
- ផែនការអភិវឌ្ឍធនធានទឹកប្រកបដោយនិរន្តរភាព
- លើកកំពស់អនាម័យនៅតាមស្ទឹង និងបរិស្ថានទឹកនៃរមណីយដ្ឋានអង្គរ

<u>យុទ្ធសាស្ត្រសំរាប់ការផ្គត់ផ្គង់ទឹក</u>




រូបទី ១៣ : ក្របខ័ណ្ឌពេលវេលា និងការអភិវឌ្ឍន៍តាមដំណាក់កាលដែលស្នើឡើង

- ផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់សំរាប់ប្រជាជន និងជំនួញ
- គ្រប់គ្រងការផ្គត់ផ្គងទឹកឱ្យមានប្រសិទ្ធភាពដើម្បីកាត់បន្ថយគំលាតរវាងរយៈពេលតំរូវការទាប និងរយៈពេលតំរូវការខ្ពស់

- លើកកំពស់សេវាកម្មផ្គត់ផ្គង់ទឹកដើម្បីពង្រីកអត្រាគ្រប ដណ្ដប់តាមរយៈការខិតខំ
- ប្រឹងប្រែងបំពេញចិត្តអតិថិជន ។

៤. គំរោង និងកម្មវិធីអភិវឌ្ឍន៍

- W-1 ការកំណត់នៅថ្នាក់ខេត្តលើការចុះបញ្ជីនៃអណ្ដូងពាណិជ្ជកម្ម
- W-2 អនុក្រឹត្យស្ដីពីទឹកក្រោមដី
- W-3 ការជិនួសបំពង់ទឹកចាស់ៗ
- W-4 សិក្សាបែបយុទ្ធសាស្ត្រអំពីការគ្រប់គ្រងធនធានទឹករួមគ្នាសំរាប់អាងស្ទឹងសៀមរាប និងស្ទឹងរលួស
- W-5 អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកក្នុងក្រុងសៀមរាប ( ជំហានទី ១)
- W-6 អភិវឌ្ឍធនធានទឹកនៅបារាយណ៍ភាគពាយ័ព្យសាន
- W-7 អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅក្រុងសៀមរាប ( ជំហានទី ២)

**៥.៤ វិស័យគ្រប់គ្រងសំណល់រឹង**

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

សំណល់រឹងត្រូវបានពង្រាយនៅទីសាធារណៈដែលបង្កផលប៉ះពាល់អវិជ្ជមានមួយចំនួនដូចជា :

- ធ្វើឱ្យកខ្វក់ដល់បរិស្ថាន ដូចជា ការបំពុលទឹកក្រោមដី ស្ទះផ្លូវទឹក សត្វចង្រៃច្រើន និងក្លិនស្អុយ
- ប៉ះពាល់សោភ័ណភាព និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ភ្ញៀវទេសចរ
- បញ្ហាសង្គមផ្សេងៗ ដូចជាកំណើនមនុស្សរើសសំរាមក្នុងក្រុង និង
- អាចបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរលើបរិស្ថាននៅតាមតំបន់ជុំវិញកន្លែងចោលសំរាមនាពេលអនាគត

សំរាមពង្រាយដោយសារ :

- កង្វះខាតការយល់ដឹងពីបញ្ហាសំរាមរបស់ប្រជាជន និងកែប្រែជីវិតរស់នៅទៅជាជីវិត "ចោលសំរាម"
- អាជ្ញាធរទទួលខុសត្រូវពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសំណល់រឹង
- អត្រានៃការប្រមូលសំណល់លំនៅដ្ឋាននៅមានកំរិតទាបដោយសារតំរៃនៃការប្រមូលសំរាមខ្ពស់
- មានការពឹងផ្អែកហួសហេតុលើផ្នែកឯកជនក្នុងការគ្រប់គ្រងសំរាម
- ប្រព័ន្ធហិរញ្ញវត្ថុទន់ខ្សោយសំរាប់ការគ្រប់គ្រងសំរាម

២. គោលដៅ

ការធ្វើក្រុងឱ្យមាន "*សោភ័ណភាព*" សំរាប់ជនគ្រប់រូប ។

- <u>តំបន់ក្រុងសៀមរាប</u> : ការធ្វើឱ្យក្រុងមានសោភ័ណភាព និង
- <u>តំបន់រមណីយដ្ឋានអង្គរ</u> : គំរូនៃការគ្រប់គ្រងបរិស្ថានក្នុងប្រទេសកម្ពុជា

ចំណុចគោលដៅនៃការគ្រប់គ្រងសំណល់រឹង

- ការគ្របដណ្ដប់នៃការប្រមូលសំណល់ : ១០០ %នៅតាមលំនៅដ្ឋានក្នុងក្រុង និងកន្លែងជំនួញ
- ប្រព័ន្ធចោលសំរាមចុងក្រោយ : កន្លែងចោលសំរាមអនាម័យ

- ចំនួននៃការចោលសំរាម : តិចជាង៦០០ ក្រាមរបស់មនុស្សម្នាក់ក្នុង១ ថ្ងៃសំរាប់សំណល់លំនៅដ្ឋាន និង តិចជាង ១.២០០ ក្រាមសំរាប់មនុស្សម្នាក់ក្នុងមួយថ្ងៃសំរាប់សំណល់ទាំងអស់
- គោលដៅនៃការកែច្នៃឡើងវិញ : សំណល់មិនមែនសរីរាង្គច្រើនជាង ២០%ត្រូវប្រើវិធានការ ៣ យ៉ាង (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) និង
- តំលៃនៃការគ្រប់គ្រងសំណល់រឹង : ៣០ ដុល្លារក្នុង១តោន ។

៣. យុទ្ធសាស្ត្រ

- ពង្រឹងការយល់ដឹងរបស់ប្រជាជនលើបញ្ហាបរិស្ថាន
- បង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានបច្ចេកទេសខ្ពស់ដោយការបង្កើតឱ្យមានស្ថាប័នទទួលខុសត្រូវនៅក្នុងអាជ្ញាធរខេត្ត និងអភិវឌ្ឍសមត្ថភាពរបស់ពួកគេសំរាប់ធ្វើផែនការ និងការគ្រប់គ្រង
- បង្កើតប្រព័ន្ធហិរញ្ញវត្ថុសមស្របមួយសំរាប់ការគ្រប់គ្រងសំណល់រឹងដោយការភ្ជាប់ទៅនឹងពន្ធ ឬដោយការភ្ជាប់កំរៃជាមួយនឹងកំរៃនៃការប្រើប្រាស់ផ្សេងៗទៀត និង
- ពង្រឹងភាពជាដៃគូរដ្ឋ-ឯកជន

៤. កម្មវិធី និងគំរោងអភិវឌ្ឍន៍

- SW-1 ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងសំណល់រឹងសមស្រប
- SW-2 ការពង្រឹងប្រព័ន្ធប្រមូលសំណល់
- SW-3 ការអភិវឌ្ឍន៍កន្លែងចាក់សំរាមអនាម័យ

**៥.៩ វិស័យប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ**

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

- មានការលិចទឹកជាញឹកញាប់នៅតាមមណ្ឌលពាណិជ្ជកម្ម និងតំបន់ស្នាក់នៅរបស់ភ្ញៀវទេសចរ និង
- ការលិចទឹកបណ្តាលឱ្យមានបញ្ហាសុខភាព/អនាម័យ និងបញ្ហាបរិស្ថាន

២. គោលដៅ

បង្កើតប្រពន្ធ័បង្ហូរទឹក និងសំណល់រាវប្រកបដោយ និរន្តរភាពសំរាប់អនាម័យ និងសោភ័ណភាពក្រុង :

- លើកកំពស់សុខភាព និងអនាម័យ
- លើកកំពស់សុខភាព និងអនាម័យនៅតាមតំបន់ជុំវិញក្រុង
- ទប់ស្កាត់ការបំផ្លាញបរិស្ថាន និងលើកកំពស់គុណភាពទឹកក្នុងស្ទឹងសៀមរាប

៣. យុទ្ធសាស្ត្រ

- រៀបចំឱ្យមានការគ្រប់គ្រងសំណល់រួម
- គ្រប់គ្រងទឹកភ្លៀង
- ការគ្រប់គ្រងសំណល់រាវ

៤. គំរោង និងកម្មវិធីអភិវឌ្ឍន៍

- SD-1 គំរោងអភិវឌ្ឍន៍ទេសចរណ៍ទន្លេមេគង្គភាគ A1 : ការលើកកំពស់ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវក្នុងតំបន់១ ស្ថិតនៅភាគខាងលិចស្រុក
- SD-2 គំរោងអភិវឌ្ឍន៍ក្រុងសៀមរាប-អង្គរ : ប្រព័ន្ធបង្ហូរទឹកនៅភាគខាងកើតស្រុក
- SD-3 គំរោងប្រព័ន្ធបង្ហូរសំណល់រាវនៅសៀមរាប-ជំហាន ១ : ប្រព័ន្ធបង្ហូរទឹក និងសំណល់តំបន់១ ស្ថិតនៅភាគខាងលិចស្រុក។




រូបទី ១៤ : ផែនការរួមសំរាប់ប្រព័ន្ធបង្ហូរសំណល់រាវ

- SD-4 គំរោងប្រព័ន្ធបង្ហូរសំណល់រាវនៅសៀមរាប - ជំហាន ២ : ប្រព័ន្ធបង្ហូរសំណល់នៅតំបន់មួយស្ថិតនៅភាគខាងកើតស្រុក
- SD-5 គំរោងប្រព័ន្ធបញ្ចេញទឹកភ្លៀងក្នុងមណ្ឌលក្រុងសៀមរាប : ប្រព័ន្ធបង្ហូរសំណល់រាវនៅភាគខាងលិចស្រុក
- SD-6 គំរោងគ្រប់គ្រងទឹកស្អុយនៅសៀមរាប ជំហាន ១ : ការចោលសំណល់កកពីសំណល់ភក់នៅខាងលិចស្រុក
- SD-7 គំរោងគ្រប់គ្រងទឹកស្អុយនៅសៀមរាប ជំហាន ២ : ការចោលសំណល់កកពីសំណល់ភក់នៅខាងកើតស្រុក
- SD-8 គំរោងបញ្ចេញចោលទឹកបន្ទាប់ពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្ម ជំហាន ១ : ការបញ្ចេញចោលសំណល់រាវក្រោយពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្មនៅតំបន់ ២ ភាគខាលិចស្រុក
- SD-9 គំរោងបញ្ចេញចោលទឹកបន្ទាប់ពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្ម ជំហាន១I : ការបញ្ចេញចោលសំណល់រាវក្រោយពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្មនៅតំបន់២ ភាគខាងកើតស្រុក។

## ៥.១០ វិស័យថាមពល

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

- ការលំបាកក្នុងការផ្គត់ផ្គង់ថាមពលឱ្យបានគ្រប់គ្រាន់ និងអាចទុកចិត្តបានពីអ្នកប្រើប្រាស់
- តំបន់គ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គីសនីនៅមានកំណត់ដោយសារតែបណ្តាញចែកចាយតូច
- ប្រពន្ធ័ចែកចាយការផ្គត់ផ្គង់មានតែមួយ
- អត្រាពន្ធអគ្គីសនីខ្ពស់
- សមត្ថភាពថែទាំនៅមានកំរិត

២. គោលដៅ

ផ្គត់ផ្គង់ថាមពលអគ្គីសនីដែលគួរឱ្យទុកចិត្ត សំរាប់ទាំងអស់គ្នាដែលប៉ះពាល់តិចតួចដល់បរិស្ថាន

- ពង្រីកបណ្តាញអគ្គីសនីនៅតំបន់ក្រុង និងតំបន់ជុំវិញក្រុងត្រឹមឆ្នាំ២០១២
- ធ្វើឱ្យមានអគ្គីសនី១០០% នៅក្នុងស្រុកសៀម រាបទាំងមូលត្រឹម ឆ្នាំ២០២០

៣. យុទ្ធសាស្ត្រ

- អភិវឌ្ឍលើការផ្គត់ផ្គង់ថាមពលបន្ថែម
- ពង្រឹង EdC
- ត្រួតពិនិត្យឱ្យស្របទៅតាមច្បាប់ បទបញ្ជា និងក្រឹត្យច្បាប់ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន

៤. គំរោង និងកម្មវិធីអភិវឌ្ឍន៍

- P-1 ការបំពាក់ជាបន្ទាន់នូវម៉ាស៊ីនភ្លើងប្រើម៉ាស៊ូត
- P-2 គំរោងពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ូតនៅពេលបច្ចុប្បន្ន
- P-3 គំរោងសំរាប់ពង្រីកបណ្តាញបែងចែកអគ្គីសនី
- P-4 គំរោងសំរាប់តម្លើង និងជុសជុលភ្លើងតាមវិថី
- P-5 ការធ្វើផែនការនៃការប្រើប្រាស់អគ្គីសនីប្រកបដោយប្រសិទ្ធភាពខ្ពស់សំរាប់ប្រាសាទអង្គរវត្ត និងប្រាសាទផ្សេងៗទៀត ។
- P-6 ការធ្វើផែនការសំរាប់បំភ្លឺតំបន់ដែលពុំទាន់មានភ្លើង
- P-7 ជំនួយដល់ការកសាងសមត្ថភាព EdC
- P-8 ជំនួយលើការពិនិត្យឡើងវិញនូវអត្រាពន្ធភ្លើង
- P-9 គំរោងសំរាប់ពិនិត្យ ឬបង្កើតច្បាប់

បទបញ្ញា និងក្រឹត្យច្បាប់អំពីការផ្គត់ផ្គង់អគ្គិសនី ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន ។

- P-10 គំរោងដើម្បីរកប្រភពថាមពលប្រកបដោយ និរន្តរភាពសំរាប់ស្រុកសៀមរាប ។




រូបទី ១៥ : ផែនការបែងចែកភ្លើង ឆ្នាំ ២០២០

## ៦. គំរោង និងកម្មវិធី

ផែនការមេស្នើឡើងនូវគំរោង និងកម្មវិធីចំនួន៦៩ ទៅតាមវិស័យផ្សេងៗដូចមានបង្ហាញក្នុងតារាងខាងក្រោម ។

តារាង ៦ : គំរោង និងកម្មវិធីដែលបានស្នើឡើង (១/២)

| ល.រ | បញ្ហាស្នូល ពាក់ព័ន្ធ | វិស័យ | លេខកូដ | ឈ្មោះគំរោង/កម្មវិធី | ការពិពណ៌នាសង្ខេប | ស្ថាប័ន/ទីភ្នាក់ងារអនុវត្ត | អាទិភាព | តំលៃ ១០០០$ | កាលវិភាគ 2008 | 2012 | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 3,4,5 | ទីក្រុង | U-1 | ការកែលំអតំបន់មជ្ឈមណ្ឌលក្រុង | ហេដ្ឋារចនាសម្ព័ន្ធ និងទេសភាពចាំបាច់ផ្សេងៗ | ខេត្ត មន្ទីរពាក់ព័ន្ធ | អាទិភាព | 7.600 | | | |
| 2 | 3,5,6 | | U-2 | កសាងសមត្ថភាពធ្វើផែនការក្រុង | អភិវឌ្ឍសមត្ថភាពសំរាប់ចក្ខុវិស័យ និងផែនការប្រើប្រាស់ដី ធ្វើផែនការក្រុង និងផែនការប្រើប្រាស់ដី | ដែនដី ស្រុក អប្សរា ខេត្ត | អាទិភាព | 500 | | | |
| 3 | 3 | | U-3 | ការចុះបញ្ជីស្ថាបត្យកម្មប្រវត្តិសាស្ត្រ | បញ្ជីសារពើភ័ណ្ឌស្ថាបត្យកម្មពីសម័យបារាំង | អប្សរា /ខេត្ត | | 200 | | | |
| 4 | 3,5 | | U-4 | លើកកំពស់ការអ.វតំបន់លំនៅដ្ឋាន | ផ្តល់បរិយាកាសរស់នៅល្អសំរាប់ចំណូលថ្មី | អប្សរា ស្រុក ឯកជន | | n/a | | | |
| 5 | 1,3,4 5 | | U-5 | អភិវឌ្ឍតំបន់វប្បធម៌ និងទេសចរណ៍ | អ.វតំបន់សំរាប់ការទ/ទ និងសណ្ឋាគារប្រណិត | អប្សរា វិនិយោគិនឯកជន | | n/a | | | |
| 6 | 4,6 | បរិស្ថាន | E-1 | អភិវឌ្ឍសមត្ថភាពស្ថាប័ន | លើកកំពស់សមត្ថភាពស្ថាប័នសំរាប់វិស័យសាធារណៈ | ខេត្ត សាធារណការ ម.បរិស្ថាន ប្រជាជន | | 310 | | | |
| 7 | 3,4 | | E-2 | លើកកំពស់ការយល់ដឹងបរិស្ថាន | យុទ្ធនាការបរិស្ថាន ជាពិសេស ចំពោះសិស្សសាលា | សាលាបឋមសិក្សា | អាទិភាព | 330 | | | |
| 8 | 4,5,6 | | E-3 | ប្រមូលកំរៃមកលើសេវាកម្មសាធារណៈ | ប្រមូលថ្លៃមធ្យមសំរាប់ថ្លៃទឹក សំណល់រាវ និងសំណល់រឹង | ខេត្ត សាធារណការ [illegible] | | 310 | | | |
| 9 | 1,2,3, 5,6 | ទេសចរណ៍ | TO-1 | បណ្តាញទេសចរណ៍បេតិកភណ្ឌខ្មែរ និងការអភិវឌ្ឍន៍ | លើកកំពស់កន្លែងទេសចរណ៍ថ្មីនៅជុំវិញសៀមរាប | ក្រ. និងម.ទេសចរណ៍ អប្សរា សារណការ ក្រ.វប្បធម៌ | អាទិភាព | 26.550 | | | |
| 10 | 2,3 | | TO-2 | អភិវឌ្ឍផ្សារពេលយប់ | បង្កើតការទាក់ទាញ និងជំរើសសំរាប់កំសាន្តពេលយប់ | ផ្នែកឯកជន | | 260 | | | |
| 11 | 1,2,3 | | TO-3 | លើកកំពស់គុណភាពទេសចរណ៍តាមរយៈរដ្ឋ-ឯកជន | ភាពជាដៃគូរដ្ឋ-ឯកជនសំរាប់ទីផ្សារ និងការផ្សព្វផ្សាយ | នឹងកំណត់នៅពេលក្រោយ | អាទិភាព | n/a | | | |
| 12 | 1,2,6 | | TO-4 | អភិវឌ្ឍ និងលើកកំពស់ទេសចរណ៍ធម្មជាតិ និងតាមភូមិ | អង្កេតតាមភូមិ អង្កេតសំរាប់គំរោងសាកល្បង និងជ្រើសរើសផលិតផលសំរាប់ទេសចរ | អង្គការមិនមែនរដ្ឋាភិបាល អប្សរា | | 158 | | | |
| 13 | 1,2 | | TO-5 | បណ្តុះបណ្តាលដំនាញនាំភ្ញៀវ និងប្រព័ន្ធនាំភ្ញៀវទំនើប | ពង្រឹងកម្មវិធីបណ្តុះបណ្តាលនាំភ្ញៀវ និងលើកកំពស់ប្រព័ន្ធផ្តល់លិខិតអនុញ្ញាត | ក្រ. និងមន្ទីរទេសចរណ៍ អប្សរា | | 211 | | | |
| 14 | 1,5 | | TO-6 | សិក្សាពីសមត្ថភាពទទួលភ្ញៀវតាមទីកន្លែង និងការគ្រប់គ្រង | សិក្សា/វិភាគពីចលនាភ្ញៀវ សមត្ថភាពទីកន្លែង និងការគ្រប់គ្រងទីកន្លែង | អប្សរា | | 163 | | | |
| 15 | 1,2,6 | ពង្រឹងកសិ. និង ជ.ជនបទ | A-1 | ការអភិវឌ្ឍធនធានមនុស្ស និងមជ្ឈ. មណ្ឌលផ្សព្វផ្សាយផលិតផល | អភិវឌ្ឍសមត្ថភាពខេត្ត និងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលក្នុងស្រុក | ខេត្ត APPC | អាទិភាព | 80 | | | |
| 16 | 1,2,6 | | A-2 | ចលនាភូមិមួយផលិតផលមួយ | លើកកំពស់ចលនាភូមិមួយ ផលិតផលមួយ | ខេត្ត APPC | | 60 | | | |
| 17 | 1,2,6 | | A-3 | អភិវឌ្ឍភូមិផលិតកម្ម | សកម្មភាពប្រមូលផ្តុំរបស់អ្នកភូមិ និងការទំនាក់ទំនងជាមួយទេសចរណ៍ | ខេត្ត APPC | | 36 | | | |
| 18 | 1,2,3 | | A-4 | ការតាំងពិព័រផលិតផលអង្ករ | រៀបចំការតាំងពិព័រផលិតផលអង្ករ ស្របជាមួយគ្នាទៅនឹងគំរោងសាកល្បង | APPC | | 108 | | | |
| 19 | 3,5 | មធ្យោបាយដឹកជញ្ជូន | TR-1 | កែលំអស្ពានសល់ពីសម័យបារាំង | សាងសង់ស្ពានបន្ថែមឆ្លងស្ទឹងសៀមរាប | មន្ទីរសាធារណការ | អាទិភាព | 957 | | | |
| 20 | 3,5 | | TR-2 | បណ្តាញផ្លូវថ្នល់ ដំណាក់ ១ | អភិវឌ្ឍផ្លូវបីនៅក្នុងតំបន់ក្រុង | សាធារណការ និងខេត្ត | អាទិភាព | 10.839 | | | |
| 21 | 3,5 | | TR-3 | បណ្តាញផ្លូវថ្នល់ ដំណាក់ ២ | សាងសង់បញ្ចប់ផ្លូវហ៊ុន សែន | មន្ទីរសាធារណការ | | 6.817 | | | |
| 22 | 3,5 | | TR-4 | បណ្តាញផ្លូវថ្នល់ ដំណាក់ ៣ | បង្កើតផ្លូវជុំខាងក្នុង | សាធារណការ និងខេត្ត | | 16.736 | | | |
| 23 | 3,5 | | TR-5 | បណ្តាញផ្លូវថ្នល់ ដំណាក់ ៤ | អភិវឌ្ឍផ្លូវធំៗក្នុងតំបន់ពាក់កណ្តាលទីប្រជុំជនបច្ចុប្បន្ន | ខេត្ត | | 14.921 | | | |
| 24 | 3,6 | | TR-6 | អភិវឌ្ឍផ្លូវធំៗ នៅតាមតំបន់ពាក់កណ្តាលក្រុងបច្ចុប្បន្ន | ពង្រឹងច្បាប់ចរាចរណ៍លើផ្នែកការផ្តល់សិទ្ធិបើកបរ សុវត្ថិភាព និងការពាក់មួកការពារ | ប៉ូលិស សាធារណការ និងខេត្ត | | 7.000 | | | |
| 25 | 2,3,5 | | TR-7 | ស្តារបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌនៅជនបទ | កែលំអផ្លូវទៅកាន់រមណីយដ្ឋានប្រាសាទឆ្ងាយៗ | សាធារណការ និង អភិវឌ្ឍន៍ជនបទ | អាទិភាព | 33.150 | | | |
| 26 | 3,4,5 | | TR-8 | មធ្យោបាយដឹកជញ្ជូនសាធារណៈដែលមិនបំពុលបរិស្ថាន | ប្រព័ន្ធឡានក្រុងដែលមានការបំពុលតិចនៅតាមរមណីយដ្ឋានប្រាសាទបុរាណ | អប្សរា | | 7.104 | | | |
| 27 | 3,4,5 | | TR-9 | សាងសង់ផ្លូវសំរាប់ជិះកង់ | បង្កើតផ្លូវសំរាប់កង់នៅតាមរមណីយដ្ឋានប្រាសាទបុរាណ | អប្សរា | | 1.417 | | | |
| 28 | 3,5,6 | | TR-10 | លើកកំពស់សមត្ថភាពស្ថាប័នសំរាប់ថែទាំផ្លូវ | រៀបចំបញ្ជីផ្លូវ និងបង្កើតប្រព័ន្ធត្រួតពិនិត្យលក្ខខ័ណ្ឌផ្លូវ | សាធារណការ និង អភិវឌ្ឍន៍ជនបទ | | 1.800 | | | |

## តារាង ៧ : គំរោង និងកម្មវិធីដែលបានស្នើឡើង (២/២)

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 29 | 4,5,6 | ទឹក | W-1 | ការត្រួតពិនិត្យរបស់ខេត្តលើការ និងការបំពាក់នាឡិកាទឹក | ការចុះបញ្ជីអ្នកប្រើប្រាស់សំរាប់ពាណិជ្ជកម្ម និងការតម្លើងទឹកម៉ាស៊ីន | ខេត្ត | | 0 |
| 30 | 5,6 | ទឹក | W-2 | អនុក្រឹត្យថ្នាក់ក្រសួងស្តីពីការយកកម្រៃប្រើប្រាស់ទឹកពីអណ្តូង | បង្កើតអនុក្រឹត្យស្តីពីការប្រើប្រាស់ទឹកអណ្តូង | ខេត្ត | | 0 |
| 31 | 4,5 | ទឹក | W-3 | ប្តូរបំពង់ទឹកចាស់ | ប្តូរបំពង់ទឹកចាស់ (៦.៥ គីឡូម៉ែត្រ) ក្នុងតំបន់កណ្តាលក្រុង | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | អាទិភាព | 450 |
| 32 | 4,5 | ទឹក | W-4 | សិក្សាជាយុទ្ធសាស្ត្រអំពីសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹក | រៀបចំការគ្រប់គ្រងធនធានទឹកតាមបែបសមាហរណកម្ម | ក្រសួងធនធានទឹក | អាទិភាព | 7.282 |
| 33 | 4,5 | ទឹក | W-5 | អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅសៀមរាប ជំហាន ១ | បង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មី | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | | 13.716 |
| 34 | 4,5 | ទឹក | W-6 | អភិវឌ្ឍធនធានទឹកនៅបារាយណ៍ភាគឦសាន | លើកកំពស់មុខងារបារាយណ៍ភាគឦសានឱ្យទៅជាធនធានទឹក | ក្រសួងធនធានទឹក | | 8.320 |
| 35 | 4,5 | ទឹក | W-7 | អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅសៀមរាប ជំហាន ២ | បង្កើតរោងចក្រប្រព្រឹត្តកម្មទឹក និងប្រព័ន្ធបែងចែកទឹក | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | | 12.310 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 36 | 3,4,5,6 | សំណល់រឹង | SW-1 | អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសំណល់រឹងសមាហរណកម្ម | អភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ និងស្ថាប័នសំរាប់គ្រប់គ្រងសំណល់រឹង | ក្រុមហ៊ុនសហប្រតិបត្តិការ-វិនិយោគចំរុះ និងខេត្ត | | 1.000 |
| 37 | 3,4,5,6 | សំណល់រឹង | SW-2 | ពង្រឹងប្រព័ន្ធប្រមូលសំណល់ | ពង្រីកការប្រមូលសំណល់រឹងឱ្យបាន ១០០ % | ក្រុមហ៊ុនសហប្រតិបត្តិការ-វិនិយោគចំរុះ និងខេត្ត | | 300 |
| 38 | 4,5,6 | សំណល់រឹង | SW-3 | កន្លែងចាក់សំរាមអនាម័យ | លើកកំពស់ការអនុវត្តន៍នៅតាមកន្លែងចាក់សំរាមបច្ចុប្បន្ន និងផែនការសំរាប់កន្លែងថ្មី | ក្រុមហ៊ុនសហប្រតិបត្តិការ-វិនិយោគចំរុះ និងខេត្ត | | 2.000 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 39 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-1 | គំរោងអភិវឌ្ឍន៍ទេសចរណ៍មេគង្គ ក១ | លើកកំពស់ប្រព័ន្ធបង្ហូរទឹកក្នុងក្រុង | សាធារណការ (ជំនួយADB) | | 11.988 |
| 40 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-2 | គំរោងអភិវឌ្ឍន៍ក្រុងសៀមរាប | ពង្រឹងប្រព័ន្ធបង្ហូរទឹក និងសំណល់រាវក្នុងតំបន់កណ្តាលក្រុង | ខេត្ត និង សាធារណការ (ជំនួយ AFD) | អាទិភាព | 4.800 |
| 41 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-3 | ប្រព័ន្ធបង្ហូរសំណល់រាវ ជំហាន ១ | ប្រព័ន្ធប្រមូលសំណល់រាវក្នុងមណ្ឌលក្រុងភាគខាងលិច តំបន់១ | ម. និងក្រសួងសាធារណការ | | 18.326 |
| 42 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-4 | ប្រព័ន្ធបង្ហូរសំណល់រាវ ជំហាន ២ | ប្រព័ន្ធប្រមូលសំណល់រាវក្នុងមណ្ឌលក្រុងភាគខាងកើត និងរោងចក្រប្រព្រឹត្តកម្មទឹក | ម. និងក្រសួងសាធារណការ | | 17.271 |
| 43 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-5 | ការបញ្ចេញទឹកភ្លៀង | ប្រព័ន្ធបង្ហូរទឹកក្នុងក្រុងថ្មីនៅភាគខាងលិច | ម. និងក្រសួងសាធារណការ | | 10.935 |
| 44 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-6 | ការគ្រប់គ្រងសំណល់រាវ (ជំហាន ១) | រចនាប្រមូលសំណល់រាវ និងរោងប្រព្រឹត្តកម្មសំរាប់ (SD-1) | ម. និងក្រសួងសាធារណការ | | 1.614 |
| 45 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-7 | ការគ្រប់គ្រងសំណល់រាវ (ជំហាន ២) | រចនាប្រមូលសំណល់រាវ និងរោងប្រព្រឹត្តកម្មសំរាប់ (SD-4) | ម. និងក្រសួងសាធារណការ | | 1.027 |
| 46 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-8 | ការចោលសំណល់ បន្ទាប់ពីប្រព្រឹត្តកម្ម ជំហាន ១ | សំរួលប្រព័ន្ធបំពង់សំរាប់ប្រមូល និងនាំទឹកបន្ទាប់ពីធ្វើប្រព្រឹត្តកម្មទៅកាន់អាងចំរោះ ដោយ SD-3 | ម. និងក្រសួងសាធារណការ | | 13.137 |
| 47 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-9 | ការចោលសំណល់ បន្ទាប់ពីប្រព្រឹត្តកម្ម ជំហាន ២ | សំរួលប្រព័ន្ធបំពង់សំរាប់ប្រមូល និងនាំទឹកបន្ទាប់ពីធ្វើប្រព្រឹត្តកម្មទៅកាន់អាងចំរោះ ដោយ SD-3 | ម. និងក្រសួងសាធារណការ | | 7.634 |
| 48 | 5,6 | ថាមពល | P-1 | ការបំពាក់ម៉ាស៊ីនភ្លើងម៉ាស៊ូតជាបន្ទាន់ | បំពាក់ម៉ាស៊ីនប្រើម៉ាស៊ូតថ្មី កំលាំង៨មេហ្គាវ៉ាត់ នៅទីតាំងអគ្គិសនីកម្ពុជា | អគ្គិសនីកម្ពុជា | អាទិភាព | 2.090 |
| 49 | 5 | ថាមពល | P-2 | ពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ូតបច្ចុប្បន្ន | ពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ូតឱ្យផលិតកើត ១០ មេហ្គាវ៉ាត់ | អគ្គិសនីកម្ពុជា | | 20.800 |
| 50 | 5 | ថាមពល | P-3 | ពង្រីក និងបន្ថែមបណ្តាញចែកចាយ | បន្ថែមខ្សែដែលមានវ៉ុលទាប និងខ្ពស់ និងបន្ថែមអនុស្ថានីយ៍ និងនាឡិកាវ៉ាត់ម៉ោងថ្មីៗ | អគ្គិសនីកម្ពុជា | | 7.800 |
| 51 | 3,5 | ថាមពល | P-4 | បំពាក់ និងជួសជុលភ្លើងតាមផ្លូវ | កែលម្អភ្លើងតាមផ្លូវសំរាប់ភ្ញៀវទេសចរ | ស្រុក | | 780 |
| 52 | 1,3,6 | ថាមពល | P-5 | ប្រើប្រាស់អគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់សំរាប់អង្គរ និងប្រាសាទផ្សេងៗ | បំភ្លឺរមណីយដ្ឋានអង្គរដោយប្រភពភ្លើងសាធារណៈ | អប្សរា / ស្ថាប័នពាក់ព័ន្ធ | | 330 |
| 53 | 2,5 | ថាមពល | P-6 | ធ្វើផែនការផ្តល់អគ្គិសនីដល់កន្លែងដែលគ្មានអគ្គិសនី | ពង្រីកតំបន់មានអគ្គិសនី នៅពេលមានការពង្រីកក្រុង | អគ្គិសនីកម្ពុជា | | 275 |
| 54 | 5,6 | ថាមពល | P-7 | ជំនួយដល់ការកសាងសមត្ថភាពសំរាប់អគ្គិសនីកម្ពុជា | បង្កើតមណ្ឌលវិស្វករពីអគ្គិសនីកម្ពុជានៅសៀមរាប | អគ្គិសនីកម្ពុជា | | 550 |
| 55 | 5,6 | ថាមពល | P-8 | ជំនួយដល់ការពិនិត្យឡើងវិញនូវអត្រាតំលៃភ្លើង | ផ្តល់អត្រាតំលៃភ្លើងទៅតាមប្រភេទអ្នកប្រើប្រាស់ | អគ្គិសនីកម្ពុជា/ អាជ្ញាធរអគ្គិសនីកម្ពុជា | | 990 |
| 56 | 5,6 | ថាមពល | P-9 | ពិនិត្យឡើងវិញនូវច្បាប់ បទបញ្ជា និងក្រឹត្យទាក់ទងអគ្គិសនីដើម្បីបន្ថយបន្ទុកបរិស្ថាន | ពិនិត្យ កែសំរួល និងបង្កើតច្បាប់ពាក់ព័ន្ធដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន | ក្រុង អគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា | | 1.800 |
| 57 | 5,6 | ថាមពល | P-10 | អភិវឌ្ឍប្រភពថាមពលចិរភាព | ស្វែងរកជំរើសសំរាប់ប្រភពថាមពល | អគ្គិសនីកម្ពុជា ថាមពល | | 660 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | (អនុសាសន៍) | | | | | | |
| 58 | 6 | រដ្ឋបាលមូលដ្ឋាន | L-1 | គណៈកម្មការអភិវឌ្ឍន៍សំរាប់អនុម័តគំរោង | បង្កើតគណៈកម្មការមួយសំរាប់ប្រតិបត្តិការរួមក្នុងខេត្ត | ខេត្ត | | 0 | | |
| 59 | 6 | | L-2 | អភិវឌ្ឍន៍ធនធានមនុស្សក្នុងខេត្ត | ការលើកកំពស់ចំណេះដឹងមន្ត្រីខេត្ត | ខេត្ត | | 1.600 | | |
| 60 | 6 | | L-3 | កំណែទំរង់ស្ថាប័ននៃអាជ្ញាធរខេត្តស.រ | ធ្វើឱ្យល្អនូវប្រព័ន្ធគ្រប់គ្រងនៅក្នុងខេត្ត | ខេត្តសៀមរាប | | | | |
| 61 | 6 | | L-4 | បង្កើត និងអនុវត្តច្បាប់ និងបទដ្ឋានច្បាប់ឱ្យមានប្រសិទ្ធភាព | រៀបចំក្របខ័ណ្ឌច្បាប់សំរាប់រដ្ឋបាលឯករាជ | ខេត្ត ក្រសួងមហាផ្ទៃ | | | | |
| 62 | 6 | | L-5 | កំណែទំរង់ហិរញ្ញវត្ថុនៅថ្នាក់ខេត្តសំរាប់រដ្ឋបាលឯករាជ | ពង្រឹងធនធានហិរញ្ញវត្ថុរបស់ខេត្តសៀមរាប | ក្រសួងហិរញ្ញវត្ថុ សភាជាតិ | | | | |
| 63 | 3,6 | ការចូលរួមរបស់សហគមន៍ | C-1 | ធ្វើផែនទីប្រើប្រាស់ដី | រៀបចំសិក្ខាសាលាដើម្បីធ្វើផែនទីក្នុងស្រុក | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 10 | | |
| 64 | 3,6 | | C-2 | ធ្វើផែនការសហគមន៍ | សិក្ខាសាលាធ្វើផែនការជាមួយភាគីពាក់ព័ន្ធនៅមូលដ្ឋាន | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 10 | | |
| 65 | 3,6 | | C-3 | សមាគមសហគមន៍ | សមាគមសហគមន៍ដើម្បីអនុវត្តគំរោង | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 10 | | |
| 66 | 2,3,6 | | C-4 | ការអនុវត្តការងារទៅតាមសហគមន៍ | អនុវត្តវិធីសាស្ត្រមជ្ឈការសំរាប់ធ្វើផែនការគំរោង | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 100 | | |
| 67 | 2,3,6 | | C-5 | ការត្រួតពិនិត្យអំពីការរស់នៅរួមគ្នារវាងអ្នកភូមិ និងបេតិកភណ្ឌ | ផែនការសំរាប់តំបន់១ និង២របស់អប្សរាសំរាប់ឱ្យសហគមន៍អាចរស់នៅជាមួយនឹងបេតិកភណ្ឌ | អប្សរា ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 100 | | |
| 68 | 2,3,6 | | C-6 | ផែនការគ្រប់គ្រងអង្គរ និងការអភិវឌ្ឍន៍សហគមន៍ | លើកកំពស់ជីវភាពប្រជាជនដើម្បីរស់នៅសមរម្យជាមួយបេតិកភណ្ឌ | អប្សរា ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 3.000 | | |
| 69 | 3,6 | | C-7 | ស្វែងយល់ពីតំរូវការរបស់ប្រជាជន | ប្រើប្រាស់ប្រព័ន្ធព័ត៌មានដើម្បីផ្សព្វផ្សាយសំលេងរបស់ប្រជាជន | ខេត្ត | | 1 | | |
| សរុប | | | | | | | | 310.633 | | |

## គំរោង និងកម្មវិធីអាទិភាព

គំរោង និងកម្មវិធីអាទិភាពដែលបានស្នើឡើងខាងលើត្រូវបានផ្តល់អាទិភាពដោយផ្អែកទៅលើលក្ខណវិនិច្ឆ័យដូចខាងក្រោម ។

### លក្ខណវិនិច្ឆ័យជ្រើសរើស

ការសិក្សានេះប្រើប្រាស់លក្ខណវិនិច្ឆ័យពីរ ដើម្បីជ្រើសរើសគំរោងអាទិភាព ។

(១) សារៈសំខាន់រយៈពេលខ្លី

គំរោងមួយអាចមានអាទិភាពរយៈពេលខ្លី ដោយសារគំរោងនោះមានភាពចាំបាច់ ហើយអាចអនុវត្តមានប្រសិទ្ធភាពរយៈពេលខ្លី ។

(២) សារៈសំខាន់រយៈពេលវែង

គំរោងមួយមានអាទិភាពរយៈពេលវែង ដោយសារគំរោងនោះ :

- ឆ្លុះបញ្ចាំងផ្ទាល់ពីគោលគំនិត និងយុទ្ធសាស្ត្រស្នូលនៃផែនការមេ
- ជាការចាំបាច់ដើម្បីនាំទៅរកភាពជោគជ័យនៃផែនការមេក្នុងរយៈពេលយូរ និង
- ត្រូវការអនុវត្តន៍មុន បើពិនិត្យទៅលើរយៈពេលរៀបចំដ៏យូរ ។

### គំរោងអាទិភាព

តារាងខាងក្រោមគឺជាបញ្ជីនៃគំរោងអាទិភាពដែលបានជ្រើសរើស ។

តារាង ៨ : គំរោង និងកម្មវិធីអាទិភាព (១/២)

| វិស័យ | លេខសំគាល់ | ឈ្មោះគំរោង | រយៈពេលអនុវត្តគំរោង | សារៈសំខាន់ | | ការផ្តល់ហេតុផល |
|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី | រយៈពេលវែង | |
| ក្រុង | U-1 | កែលំអតំបន់កណ្តាលក្រុង | 2006-2007 | X | | ការកែប្រែមុខមាត់ថ្មី ដើម្បីលើកកំពស់បរិស្ថានក្រុង /ទេសចរណ៍ ក្នុងមណ្ឌលក្រុងដោយសង្កត់ធ្ងន់លើតំបន់ក្បែរផ្សារចាស់ |
| ក្រុង | U-2 | ការកសាងមត្ថភាពធ្វើផែនការក្រុង | 2006-2007 | | X | យុទ្ធសាស្ត្រដើម្បីដាក់បញ្ចូល និងពង្រឹងគោលនយោបាយ /ការគ្រប់គ្រងក្រុងក្នុងរដ្ឋបាលខេត្ត ។ ការងារជាចំបងនោះគឺការកែលំអផែនការ/ការគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងគណៈកម្មការនៅថ្នាក់ខេត្តឱ្យកាន់តែមានប្រសិទ្ធភាពឡើងសំរាប់ការរៀបចំផែនការក្រុង ។ |
| បរិស្ថាន | E-2 | ការលើកកំពស់ចំណេះដឹងបរិស្ថាន | 2006-2012 | | X | ជាការសំខាន់គឺត្រូវបន្តធ្វើឱ្យគំរោងសាកល្បង "ធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង " កាន់តែមាននិរន្តរភាព និងទូលំទូលាយ ។ |
| ទេសចរណ៍ | TO-1 | បណ្តាញទេសចរណ៍បេតិកភណ្ឌខ្មែរ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំរាប់ទេសចរណ៍ | 2007-2012 | X | | ការស្វែងរកតំលៃនៃវប្បធមិខ្មែរឡើងវិញគឺជាការចាំបាច់ ។ |
| ទេសចរណ៍ | TO-3 | ការលើកកំពស់គុណភាពទេសចរណ៍តាមរយៈភាពជាដៃគូរដ្ឋ-ឯកជន | 2006-2020 | X | X | ត្រូវមានកម្មវិធីសំខាន់មួយដើម្បីសំរបសំរួលសំរាប់ភ្ញៀវទេសចរគំរោងផ្សេងៗ ដើម្បីគ្រប់គ្រងផ្នែកឯកជនជាមុន និងដើម្បីលើកកំពស់គោលដៅទីផ្សារទេសចរណ៍ |
| ការពង្រីកកសិកម្ម និងផលិតផលក្នុងស្រុក | A-1 | អភិវឌ្ឍន៍ធនធានមនុស្ស និងមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផល | 2006-2008 | X | | ជាការសំខាន់ដើម្បីធ្វើឱ្យគំរោងសាកល្បង "ការតាំងពិព័រណ៍ផលិតផលអង្គរ" កាន់តែមាននិរន្តរភាពដោយការពង្រឹងមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ(APPC) |

តារាង ៩ : គំរោងអាទិភាព (២/២)

| | | | | | | |
|---|---|---|---|---|---|---|
| មធ្យោបាយដឹកជញ្ជូន | TR-1 | កែលំអស្ពានបារាំង | 2006-2012 | X | X | ជាការសំខាន់ក្នុងការភ្ជាប់លទ្ធភាពធ្វើដំណើរពីភាគខាងកើតនិងខាងលិចក្រុង ដោយរក្សាទុកនូវស្ពានបច្ចុប្បន្ន |
| មធ្យោបាយដឹកជញ្ជូន | TR-2 | បណ្តាញផ្លូវវាណបប្រទាត់ក្រឡា (ដំណាក់១) | 2006-2008 | X | X | ការសំរួលជាបន្ទាន់កុំឱ្យមានការកកស្ទះតាមបណ្តោយផ្លូវជាតិលេខ ៦ គឺជាការសំខាន់ |

| | | | | | | |
|---|---|---|---|---|---|---|
| មធ្យោបាយដឹកជញ្ជូន | TR-7 | ការស្តារបណ្តាញផ្លូវទៅកាន់កន្លែងបេតិកភណ្ឌនៅតាមតំបន់ឆ្ងាយៗ | 2006-2009 | X | X | ជាការចាំបាច់មិនអាចខ្វះបានដើម្បីលើកកំពស់ភាពសម្បូរបែបនៃកន្លែងទាក់ទាញភ្ញៀវទេសចរ និងធានាដល់ការធ្វើដំណើរងាយស្រួលទៅកាន់រមណីយដ្ឋានប្រវត្តិសាស្ត្រផ្សេងៗ |
| ទឹក | W-3 | ការជំនួសបំពង់ទឹកចាស់ | 2006-2007 | X | | គឺជាការចាំបាច់ដើម្បីដាក់ជំនួសបំពង់ទឹកចាស់ៗក្នុងប្រព័ន្ធទឹកបច្ចុប្បន្នសំរាប់ដំណើរការចែកចាយទឹកពីគំរោងបែងចែកទឹកថ្មីប្រកបដោយប្រសិទ្ធភាព ។ |
| ទឹក | W-4 | សិក្សាតាមបែបយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងធនធានទឹករួម | 2007-2011 | X | X | យុទ្ធសាស្ត្រ និងតំរូវការជាបន្ទាន់ដើម្បីកំណត់វិធី និងមធ្យោបាយដើម្បីជំនួសការបូមទឹកក្រោមដីតាមកន្លែងនីមួយៗ ដោយការ ផ្គត់ផ្គង់ទឹកសាធារណៈជាបណ្តើរៗ និងធានាការគ្រប់គ្រងទឹករយៈ ពេលយូរអង្វែងសំរាប់អ្នកប្រើប្រាស់ និងកន្លែងផ្សេងៗក្នុងស្រុកសៀមរាប ។ |
| ប្រព័ន្ធបង្ហូរសំណល់រាវ/ទឹកភ្លៀង | SD-2 | គំរោងអភិវឌ្ឍន៍តំបន់ក្រុងក្នុងខេត្តសៀមរាប | 2006-2020 | X | | ជាការចាំបាច់ដើម្បីលើកកំពស់អនាម័យ និងបរិស្ថានតំបន់កណ្តាលក្រុងដែលជាកន្លែងប្រមូលផ្តុំនៃសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ សំរាប់ភ្ញៀវទេសចរ និងប្រជាជនក្នុងខេត្ត ។ អាស្រ័យហេតុនេះ គំរោងដែលជួយដោយ ADB មានផែនការបង្កើតរោងចក្រប្រព្រឹត្តិកម្មទឹកមួយ ។ |
| ថាមពល | P-1 | ការបំពាក់ម៉ាស៊ីនភ្លើងជាបន្ទាន់ | 2006-2007 | X | X | មានប្រសិទ្ធភាព និងងាយស្រួលអនុវត្តដែលជាវិធានការបន្ទាន់ដើម្បីកាត់បន្ថយការដាច់ចរន្តដែលមានភាពរាំរ៉ៃ ។ |

**តំលៃគំរោងសរុប**

តារាងខាងក្រោមគឺជាសេចក្តីសង្ខេបពីការចំណាយសរុបនៃគំរោងតាមវិស័យ ។

តារាង ១០ : ការប៉ាន់ស្មានតំលៃគំរោង

| វិស័យ | | គំរោងអាទិភាព | | គំរោងផ្សេងៗ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃគំរោង (000 ដុល្លារ) | ចំនួន | តំលៃគំរោង (000 ដុល្លារ) | ចំនួន | តំលៃគំរោង (000 ដុល្លារ) |
| ការអភិវឌ្ឍន៍ក្រុង | U-1 ទៅ 5 | 2 | 8.100 | 3 | 200 | 5 | 8.300 |
| ការគ្រប់គ្រងបរិស្ថាន | E-1 ទៅ 3 | 1 | 330 | 2 | 620 | 3 | 950 |
| ទេសចរណ៍ | TO-1 ទៅ 6 | 2 | 26.550 | 4 | 792 | 6 | 27.342 |
| ការពង្រីកកសិកម្ម និងផលិតផលក្នុងស្រុក | A-1 ទៅ 4 | 1 | 80 | 3 | 204 | 4 | 284 |
| មធ្យោបាយដឹកជញ្ជូន | TR-1 ទៅ 10 | 3 | 44.946 | 7 | 55.795 | 10 | 100.741 |
| ទឹក | W-1 ទៅ 7 | 2 | 7.732 | 5 | 34.346 | 7 | 42.078 |
| សំណល់រឹង | SW-1 ទៅ 3 | | | 3 | 3.300 | 3 | 3.300 |
| ប្រព័ន្ធបង្ហូរសំណល់រាវ/ទឹក | SD-1 ទៅ 9 | 1 | 4.800 | 8 | 81.932 | 9 | 86.732 |
| អគ្គិសនី | P-1 ទៅ 10 | 1 | 2.090 | 9 | 33.985 | 10 | 36.075 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| រដ្ឋបាលមូលដ្ឋាន | L-1 ទៅ 5 | | | 5 | 1.600 | 5 | 1.600 |
| ការផ្ដល់សិទ្ធិអំណាចដល់ស.គ | C-1 ទៅ 7 | | | 7 | 3.231 | 7 | 3.321 |
| សរុប | | 13 | 94.628 | 56 | 216.205 | 69 | 310.633 |

## ៧. ការរៀបចំហិរញ្ញវត្ថុ និងស្ថាប័ន

ដើម្បីធ្វើឱ្យជោគជ័យលើផែនការតាមវិស័យដែលបានលើកឡើងក្នុងគំរោង/កម្មវិធី ក្រុមសិក្សាស្នើអនុសាសន៍មួយចំនួនក្នុងជំពូកនៃការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុនេះ។ អនុសាសន៍ទាំងនោះរួមមាន (១) អនុសាសន៍សំរាប់ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ខេត្ត និង (២) អនុសាសន៍សំរាប់ក្រសួងនៅថ្នាក់ជាតិ។

១. អនុសាសន៍សំរាប់ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ខេត្ត

បញ្ហាជាគន្លឹះគឺត្រូវពង្រឹងគំនិតផ្តួចផ្តើម និងអាជ្ញាធររបស់អភិបាលខេត្តជាជំហានៗ។ ខាងក្រោមនេះគឺជាអនុសាសន៍សំខាន់ៗសំរាប់ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ខេត្ត។

ក. ធានាឱ្យមានការចែករំលែកព័ត៌មាន និងការយល់ដឹងរួមអំពីគោលនយោបាយ ផែនការ ថវិកា និងគំរោងនានា ក្នុងស្រុកសៀមរាបរវាងសាលាខេត្ត មន្ទីរពាក់ព័ន្ធក្នុងខេត្ត និងអាជ្ញាធរអប្សរា។

ខ. ធានាឱ្យមានអាជ្ញាធរជាក់លាក់មួយដើម្បីអនុញ្ញាត/ហាមឃាត់សកម្មភាពឯកជននៅក្នុងវិស័យជាអាទិភាព មួយចំនួនដូចជា :

- ការប្រើប្រាស់ដី និងការគ្រប់គ្រងសំណង់
- ការត្រួតពិនិត្យបរិស្ថាន និង
- ការប្រើប្រាស់ធនធានទឹក ទាំងទឹកក្រោមដី និងទឹកលើដី

គ. ពង្រឹងមុខងារនៃការបង្កើតគោលនយោបាយក្រុង និងការគ្រប់គ្រងក្រុង : ដោយសារសេដ្ឋកិច្ច និងសង្គមរបស់ស្រុកសៀមរាបមានទំនាក់ទំនងយ៉ាងខ្លាំងលើការអភិវឌ្ឍន៍ក្រុង និងការអភិវឌ្ឍន៍ទេសចរណ៍ គោលនយោបាយក្រុង និងការគ្រប់គ្រងក្រុងគួរផ្តួចផ្តើមឡើងនៅថ្នាក់ខេត្ត។

ឃ. ពង្រឹងគំនិតផ្តួចផ្តើមរបស់ខេត្តដើម្បីធានាឱ្យមានការចូលរួមយ៉ាងមានប្រសិទ្ធភាពពីផ្នែកឯកជន : ដោយសារសមត្ថភាពរដ្ឋាភិបាលនៅថ្នាក់ខេត្តមានកំរិត ការចូលរួមពីផ្នែកឯកជនគឺជាការចាំបាច់។ ទោះជាយ៉ាងនេះក៏ដោយតាមការសង្កេតនៅពេលបច្ចុប្បន្ន ការពឹងអាស្រ័យដែលមិនទទួលខុសត្រូវលើការចូលរួមពីផ្នែកឯកជនបណ្តាលឱ្យមានការប្រើប្រាស់ធនធានសាធារណៈមិនសមស្របដើម្បីបំរើផលប្រយោជន៍ឯកជន និងការធ្លាក់ចុះនូវគុណភាពសេវាកម្ម ដែលប្រហែលជាអាចនាំទៅដល់ការបាត់បង់ផលប្រយោជន៍សាធារណៈ និងដល់ការបរាជ័យលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

ដើម្បីធ្វើឱ្យសំរេចអានុសាសន៍ទាំងនេះ ជាដំបូង ចាំបាច់ពង្រឹងមូលដ្ឋានស្ថាប័ននៅថ្នាក់ខេត្តដោយប្រើប្រាស់វិធានការដូចខាងក្រោម :

១) ពង្រឹងរដ្ឋបាលថ្នាក់ខេត្ត ដោយយកចិត្តទុកដាក់ទៅលើ

- ធនធានមនុស្សលើជំនាញបច្ចេកទេស និងគ្រប់គ្រង
- មូលដ្ឋានហិរញ្ញវត្ថុ សំរាប់ចំណាយប្រតិបត្តិ និង
- មូលដ្ឋានទិន្នន័យ ដើម្បីសំរួលដល់ការត្រួតពិនិត្យការប្រើប្រាស់ដី បរិស្ថាន ការប្រើប្រាស់ទឹក និងសេវាកម្ម

សាធារណៈឱ្យមានប្រសិទ្ធភាព។

២) លើកកំពស់ការរៀបចំឱ្យមានការចូលរួមពីផ្នែកឯកជន

ការរៀបចំឱ្យមានការចូលរួមពីផ្នែកឯកជនគួរធ្វើឡើងដោយផ្អែកលើមូលដ្ឋានតម្លាភាព និងការប្រកួតប្រជែង ដើម្បីធានាភាពយុត្តិធម៌ គណនេយ្យភាព និងប្រសិទ្ធភាពនៃសេវាកម្មដែលបានផ្ដល់ជូន ស្របតាមផែនការអភិវឌ្ឍន៍ចិរភាព។

៣) វិស័យដែលស្នើឱ្យមានការចូលរួមពីផ្នែកឯកជន

វិស័យមួយចំនួនដែលស្នើឱ្យមានការចូលរួមពីផ្នែកឯកជនរួមមាន ការប្រមូលសំណល់រឹង ការផ្សព្វផ្សាយ/លើកកំពស់ផលិតផលក្នុងស្រុក ការកសាងចំណេះដឹងក្នុងការលើកកំពស់បរិស្ថាន និងការផ្សព្វផ្សាយទេសចរណ៍។

២. អនុសាសន៍សំរាប់ក្រសួងនៅថ្នាក់ជាតិ

បញ្ហាជាគន្លឹះនោះគឺត្រូវពង្រឹងសមត្ថភាពច្បាប់ និងជំនាញរបស់ក្រសួងពាក់ព័ន្ធដើម្បីជួយអនុវត្តគំនិតផ្ដួចផ្ដើម និងអាជ្ញាធរខេត្តដូចបានលើកឡើងខាងលើ។ អនុសាសន៍សំខាន់មានដូចខាងក្រោម :

ក. បង្កើត និងបកស្រាយច្បាប់ លិខិតបទដ្ឋានច្បាប់ និងនីតិវិធីក្នុងផ្នែកសំខាន់ៗ ដូចជា ការគ្រប់គ្រងលើការប្រើប្រាស់ដីធ្លី និងបរិស្ថាន ការគ្រប់គ្រងទឹក។ ជាមួយគ្នានេះ ចាំបាច់ត្រូវពិនិត្យ និងធ្វើឱ្យរលូនក្នុងការបែងចែកការទទួលខុសត្រូវរវាងក្រសួង និងមន្ទីរពាក់ព័ន្ធនៅតាមផ្នែកជាអាទិភាពទាំងនោះ

ខ. ពង្រឹងសមត្ថភាពបច្ចេកទេសរបស់ក្រសួង និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីជួយអភិបាលខេត្តប្រើប្រាស់គំនិតផ្ដួចផ្ដើម និងអាជ្ញាធរខេត្តប្រកបដោយប្រសិទ្ធភាព ដោយសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងដីធ្លី បរិស្ថាន និងទឹក។

គ. គួរមានការកែទំរង់ពន្ធជាបន្ទាន់សំរាប់ជួយដល់ការអភិវឌ្ឍន៍មូលដ្ឋាន រួមទាំងការអភិវឌ្ឍន៍ក្នុងស្រុកសៀមរាប។ ការខិតខំប្រឹងប្រែងដែលកំពុងធ្វើផ្សេងៗគួរតែធ្វើសេចក្ដីសំរេចឱ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើបាន។

ផ្អែកតាមអនុសាសន៍ទាំងឡាយខាងលើ និងសេចក្ដីត្រូវការចាំបាច់ដែលមិនអាចខ្វះបានសំរាប់ធាតុបញ្ចូលពីខាងក្រៅ ការយកចិត្តទុកដាក់គួរធ្វើឡើងទៅលើបញ្ហាសំខាន់ៗពីរសំរាប់ការវិភាគឱ្យបានស៊ីជំរៅ និងសំរាប់សំណើសុំផ្សេងៗ (១) ការគ្រប់គ្រងការអភិវឌ្ឍន៍ជាពិសេសនៅថ្នាក់ខេត្ត និង(២) ហិរញ្ញវត្ថុនៅមូលដ្ឋាន។

**៧.១ ការគ្រប់គ្រងលើការអភិវឌ្ឍន៍**

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

- ការត្រួតគ្នានៃភារកិច្ច និងការទទួលខុសត្រូវក្នុងចំណោមស្ថាប័នរដ្ឋាភិបាល
- កង្វះការធ្វើសមាហរណកម្មនៃរចនាសម្ព័ន្ធស្ថាប័នរបស់អាជ្ញាធរខេត្ត
- ធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់សំរាប់រដ្ឋបាលមូលដ្ឋាន
- សមត្ថភាពគ្រប់គ្រងរបស់រដ្ឋបាលមូលដ្ឋានខ្សោយ
- កង្វះក្របខ័ណ្ឌច្បាប់ជាខ្សែសង្វាក់ និងការពង្រឹងការអនុវត្តន៍ច្បាប់

២. គោលដៅ

*"បង្កើតរដ្ឋបាលមូលដ្ឋានស្វយ័ត និងឯកភាពសំរាប់ខេត្តសៀមរាបដើម្បីធានាឱ្យមានតម្លាភាព និងគណនេយ្យភាព"* ។

៣. យុទ្ធសាស្ត្រ

- អនុវត្តរដ្ឋបាលស្វយ័ត និងឯកភាពដោយអនុលោមទៅតាមកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ជាតិ
- ពង្រឹងរដ្ឋបាលថ្នាក់ខេត្តរបស់ខេត្តសៀមរាបដើម្បីឱ្យក្លាយជាស្ថាប័នស្វយ័ត សំរាប់រដ្ឋបាលមូលដ្ឋានសមស្រប
- ធានាឱ្យមានថវិកាគ្រប់គ្រាន់សំរាប់រដ្ឋបាលឯកភាព
- បង្កើតប្រព័ន្ធប្រជាធិបតេយ្យអាស្រ័យសភាដើម្បីធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាព
- បង្កើតក្របខ័ណ្ឌច្បាប់សំរាប់គាំទ្រដល់រដ្ឋបាលឯកភាព

៤. អនុសាសន៍

- បង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ខេត្ត
- កំណែទំរង់រដ្ឋអំណាចខេត្ត
- ការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងរដ្ឋអំណាចថ្នាក់ខេត្ត
- ការបង្កើត និងការអនុវត្តន៍ច្បាប់ និងបទដ្ឋានច្បាប់
- កំណែទម្រង់ហិរញ្ញវត្ថុ និងថវិកាសំរាប់រដ្ឋបាលឯកភាព

តារាង ១១ : កម្មវិធីកសាងសមត្ថភាពសំរាប់អាជ្ញាធរខេត្ត

| សេវាសាធារណៈដែលរំពឹងទុក | អនុសាសន៍ស្ដីពីកម្មវិធីពង្រឹងសមត្ថភាព | ក្រុមគោលដៅសំរាប់ពង្រឹងសមត្ថភាព |
|---|---|---|
| ១. ធ្វើផែនការមេសំរាប់ក្រុង និងផែនការគំរោងនានា | ធ្វើផែនការគំរោងដោយផ្អែកលើផែនការមេ | • អភិបាលខេត្ត និងប្រធានមន្ទីរខេត្ត |
| ២. អនុវត្ត និងគ្រប់គ្រងការងារសាធារណៈ (គំរោង) | • វិធីសាស្ត្រគ្រប់គ្រងគំរោង និងត្រួតពិនិត្យគំរោង<br>• ការវាយតំលៃគំរោង | • មន្ត្រីគ្រប់គ្រងការងារសាធារណៈក្នុងខេត្ត<br>• មន្ត្រីទាំងអស់នៅតាមមន្ទីរខេត្ត |
| | • វិធីដោះស្រាយទំនាស់ដីធ្លី | • មន្ត្រីថ្នាក់ខេត្តទទួលបន្ទុកខាងការគ្រប់គ្រងដីធ្លី ផែនការ និងអភិវឌ្ឍន៍ និងវិនិយោគ<br>• មន្ត្រីមន្ទីរខេត្តខាងការគ្រប់គ្រងដីធ្លី នគរូបនីយកម្ម សំណង់ និងកម្មសិទ្ធិដីធ្លី |

## ៧.២ ការផ្ដល់ហិរញ្ញវត្ថុដល់មូលដ្ឋាន

១. ស្ថានភាព និងបញ្ហាបច្ចុប្បន្ន

- ធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់
- ការធ្វើផែនការថវិកាមិនបានគ្រប់គ្រាន់ និងការប្រើប្រាស់ថវិកាគ្មានប្រសិទ្ធភាព
- កង្វះធនធានមនុស្ស
- កង្វះតម្លាភាព

២. គោលដៅ

រយៈពេលខ្លី : "រដ្ឋាភិបាលផ្តល់នូវធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ដើម្បីធានាឱ្យមាននិរន្តរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់សៀមរាប"។

រយៈពេលវែង : "ប្រាក់ចំណូលសារពើពន្ធនៅខេត្តសៀមរាបជួយជំរុញឱ្យមាននិរន្តរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកម្ពុជា" ។

៣. យុទ្ធសាស្ត្រ

១) បង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋអំណាចខេត្ត

ការធ្វើឱ្យមានកំណើនធនធានហិរញ្ញវត្ថុសំរាប់អាជ្ញាធរខេត្តគឺជាការចាំបាច់ ជាពិសេសសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្រុង ដោយសារតែឥទ្ធិពលនៃការអភិវឌ្ឍន៍នេះទៅលើសេដ្ឋកិច្ចខេត្តសៀមរាប តាមរយៈការអភិវឌ្ឍន៍វិស័យទេសចរណ៍ ។

វិធានការនានា ដើម្បីបង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋអំណាចថ្នាក់ខេត្តរួមមាន :

- ការពង្រឹងការប្រមូលពន្ធ
- ការធ្វើការបែងចែកធនធានដែលមានស្រាប់ទៅឱ្យរដ្ឋអំណាចថ្នាក់ខេត្ត
- អនុវត្តការប្រមូលពន្ធថ្មី/កំរៃ និងបង្កើនអត្រាពន្ធ

២) កែលំអផែនការថវិកា/ការប្រើប្រាស់ថវិកា និងធនធានមនុស្ស

ត្រូវតែបង្កើតឱ្យមានការចែករំលែកព័ត៌មាន និងការសំរបសំរួលរវាងអាជ្ញាធរខេត្ត និងមន្ទីរជំនាញនៅថ្នាក់ខេត្តឱ្យមានប្រសិទ្ធភាពជាងមុន ។

៣) ពង្រឹងតម្លាភាពដែលទាក់ទងទៅនឹងការផ្តល់ហិរញ្ញវត្ថុដល់មូលដ្ឋាន

ជាការសំខាន់ណាស់ដែល អាជ្ញាធរខេត្តមានតម្លាភាពលើបញ្ហាថវិកា ។

## ៨. ការគិតគូរពីសង្គម និងបរិស្ថាន

ជំពូកនេះពិពណ៌នាអំពីលទ្ធផលនៃការត្រួតពិនិត្យដំបូងនៃផលប៉ះពាល់លើវិស័យសង្គម និងបរិស្ថាន (Initial Examination of Environmental and Social Impact (IEE)) របស់ផែនការមេដោយយោងតាម "ការណែនាំសំរាប់ការត្រួតពិនិត្យដំបូងសំរាប់ការពិចារណាទៅលើសង្គម និងបរិស្ថានរបស់ JICA (២០០៤)" និងក្របខ័ណ្ឌច្បាប់កម្ពុជា ។

### ៨.១ ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គមដែលបានព្យាករណ៍

មានការកំណត់វិសាលភាពនៃផលប៉ះពាល់លើបរិស្ថាន និងសង្គមដែលបានព្យារករណ៍របស់ក្រុមសិក្សានៅដំណាក់កាលនេះ ។ សេចក្ដីសង្ខេបនៃផលប៉ះពាល់បរិស្ថាន និងសង្គមដែលបានព្យាករណ៍ ដែលជាផ្នែកមួយនៃលទ្ធផលនៃការកំណត់វិសាលភាព និងវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នាទុកដែលជាការត្រួតពិនិត្យដំបូងលើផលប៉ះពាល់បរិស្ថាននៃការសិក្សានៅក្នុងដំណាក់កាលនេះ មានបង្ហាញក្នុងតារាងខាងក្រោម ។

តារាង ១២ : សេចក្ដីសង្ខេបនៃផលប៉ះពាល់សំរាប់គំរោងទាំងអស់

| ឈ្មោះគំរោង សហប្រតិបត្តិការ | | ការសិក្សាស្ដីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃសៀមរាប/ក្រុងអង្គរក្នុងព្រះរាជាណាចក្រកម្ពុជា | | |
|---|---|---|---|---|
| ផលប៉ះពាល់ដែលអាចកើតមាន | ការកំណត់អត្រា | ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ (ឧទា: ទំហំ វិសាលភាពតំបន់ រយៈពេល ភាពញឹកញាប់ ការត្រឡប់ទៅរកភាពដើម និងការចិញ្ចឹមជីវិតនៃការកើតឡើង | វិធីសាស្ត្រប្រើប្រាស់ដើម្បីព្យាករណ៍ | វិធានការកាត់បន្ថយផលប៉ះពាល់ដែលសន្មត់ |
| ដំណើរការបំលាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត | ត | ការកសាងផ្លូវថ្នល់ រោងចក្រធ្វើប្រព្រឹត្តិកម្មទឹក ឬសំណល់រាវ កន្លែងចាក់សំរាមត្រូវការទិញដី (សូមមើលរូបថតខាងក្រោម) ។ ការធ្វើប្រព្រឹត្តិកម្មទឹក ឬ សំណល់រាវ និងកន្លែងចាក់សំរាមនឹងត្រូវធ្វើឡើងក្នុងតំបន់ដាំដុះ ។ ហេតុដូច្នេះ គេរំពឹងថា ការមាននៃដំណើរការបំលាស់ទីលំនៅនៅមានកំរិតទាប ។ | • ការត្រួតពិនិត្យផែនទីសំរាប់ទីតាំងគំរោង<br>• ការអង្កេតផល់កន្លែងផ្ទាល់ | • ការជ្រើសរើស ឬកំណត់ទីតាំងដោយប្រយ័ត្នប្រយែង សំរាប់គំរោងពាក់ព័ន្ធដើម្បីបង្ការកុំឱ្យមានការបំលាស់លំនៅឱ្យបានច្រើនទៅតាមលទ្ធភាព<br>• ប្រសិនបើការតាំងទីលំនៅជាថ្មីចៀសមិនរួច ផែនការតាំងទីលំនៅជាថ្មីដោយមានកិច្ចព្រមព្រៀងពីអ្នកពាក់ព័ន្ធចាំបាច់ត្រូវកំណត់ដើម្បីបញ្ចៀស ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ។ |
| សេដ្ឋកិច្ចមូលដ្ឋាន | ខ | • ដីកសិដ្ឋាននៅតាមព្រំប្រទល់រវាងឃុំជ្រាវ និងឃុំសៀមរាបគឺជាកន្លែងត្រូវស្នើសុំសំរាប់រោងចក្រធ្វើប្រព្រឹត្តិកម្មសំណល់រាវមានទំហំ ១៥ហិត បើទោះបីជាទីតាំងពិតប្រាកដមួយមិនត្រូវបានកំណត់ក៏ដោយ ។ | • ការអង្កេតពីប្រាក់ចំណូលរបស់ប្រជា-កសិករ និងភាពជាម្ចាស់ដីនៅតំបន់ស្នើសុំ | • ការពិចារណាដោយប្រយ័ត្នប្រយែងសំរាប់ការកំណត់ទីកន្លែងដើម្បីធ្វើឱ្យមានផលប៉ះពាល់តិច ។<br>• ការពិចារណា និងការអនុវត្តន៍នៃការទូទាត់ដែលសមរម្យ និងការធានាការងារសំរាប់អ្នកស្រុកដែលពាក់ព័ន្ធ ។ |
| បេតិកភណ្ឌវប្បធម៌ | ខ | • លទ្ធភាពនៃការបង្កផលប៉ះពាល់មានកំរិតទាប ប៉ុន្តែសកម្មភាពសាងសង់សំរាប់គំរោង | • ការអង្កេតផល់កន្លែង | • ធ្វើការអង្កេតផ្នែកបុរាណវត្ថុ មុនពេលចាប់ផ្ដើមការសាងសង់ ។ (សូមមើលរូប |

| | | | | |
|---|---|---|---|---|
| | | ដែលបានស្នើសុំអាចជះឥទ្ធិពលលើបេតិកភណ្ឌវប្បធម៌នៅ ក្រោមដី ។ | • ការអង្កេតផ្នែកបុរាណវត្ថុ | ខាងក្រោមសំរាប់ការចែកតំបន់) |
| ជម្លោះផលប្រយោជន៍មូលដ្ឋាន | ខ | • ជម្លោះផលប្រយោជន៍ លើភាពជាម្ចាស់ដីត្រូវគេរំពឹងថាកើតមាននៅក្នុងតំបន់ទាក់ទងនឹងផែនការប្រើប្រាស់ដីថ្មីដែលបានស្នើឡើង ។ | • ប្រជុំជាមួយអ្នកពាក់ព័ន្ធ | • ការប្រជុំ និងការពិភាក្សាជាមួយអ្នកពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់គួរធ្វើឡើង មុនពេលផែនការមេត្រូវបញ្ចប់ ។ |
| ការប្រើប្រាស់ទឹក ឬសិទ្ធិប្រើប្រាស់ទឹក និងសិទ្ធិទូទៅ | ខ | • ប្រសិនបើការសំរបសំរួលមិនត្រូវបានធ្វើក្នុងចំណោមការិយាល័យរដ្ឋបាល ផលប៉ះពាល់នឹងធ្ងន់ធ្ងរ ហើយលំបាកស្តារឡើងវិញ ។ | • ប្រជុំជាមួយអ្នកពាក់ព័ន្ធ | • ការសំរបសំរួលដោយប្រយ័ត្នប្រយែងចាំបាច់ត្រូវធ្វើឱ្យសំរេចរាប់បញ្ចូលទាំងគំរោងសំរាប់ការអភិវឌ្ឍន៍ធនធានទឹកនៅក្នុងផែនការមេ ។ |
| ទឹកក្រោមដី | ខ | • ទឹកក្រោមដីអាចធ្វើអោយកខ្វក់ដោយទឹកសំណល់នៅដំណាក់កាលសាងសង់នៃគំរោងដែលបានស្នើឡើង ។ សំណល់រាវហូរពីកន្លែងចាក់សំរាម ដែលបានស្នើឡើងអាចហូរចូលទៅក្នុងទឹកក្រោមដី ។ | • ការអង្កេតភូគព្ភសាស្ត្រ ជលសាស្ត្រ និងការធ្វើតេស្តបូមទឹក | • វិធានការសមរម្យដើម្បីការពារការធ្វើឱ្យបំពុលទឹកក្រោមដីនៅដំណាក់កាលសាងសង់ |
| ស្ថានភាពជលសាស្ត្រ | ខ | • ស្តារដី ឬការដាក់ទ្វារទឹកនឹងជះឥទ្ធិពលដល់ជលសាស្ត្រស្ទឹងសៀមរាប ។ | • ការអង្កេត និងការស្វែងយល់ជលសាស្ត្រ | • វិធានការនានាចាំបាច់ត្រូវពិចារណាដើម្បីធ្វើឱ្យផលប៉ះពាល់តិចតួចលើស្ថានភាពជលសាស្ត្រនៃស្ទឹងសៀមរាប ។ |
| រុក្ខជាតិ សត្វ និងជីវចំរុះ | ខ | • គ្មានពពួកសត្វដែលរងគ្រោះថ្នាក់ត្រូវបានគេរាយការណ៍ទេនៅក្នុងតំបន់សិក្សា ( មិនរាប់បញ្ចូលបឹងទន្លេសាប) ។ បន្ថែមពីលើនេះទីតាំងគំរោងដែលបានស្នើនឹងស្ថិតនៅលើដីដាំដុះ ។ ហេតុដូច្នេះ ផលប៉ះពាល់មានកំរិត ។ | • ការប្រមូលព័ត៌មាន<br>• ការអង្កេតស៊ីជំរៅដល់កន្លែង | • ប្រសិនបើគំរោងស្នើសុំត្រូវបានរកឃើញថាមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើរុក្ខជាតិសត្វ និងជីវចំរុះ គំរោងគួរត្រូវបញ្ឈប់ និងពិចារណាឡើងវិញ ។ ការពិចារណាដោយប្រុងប្រយ័ត្នគួរត្រូវធ្វើឡើងសំរាប់ផលប៉ះពាល់ទៅលើប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាប ។ |
| កំដៅពិភពលោក | ខ | • ផលប៉ះពាល់មានកំរិតដោយធ្វើការវិនិច្ឆ័យពីវិសាលភាពនៃគំរោង ។ គំរោងខ្លះនឹងជួយកែលំអប្រសិទ្ធភាពនៃថាមពលនៅក្នុងតំបន់សិក្សា ។ | • ការប៉ាន់ស្មានទៅលើទំហំនៃការភាយចេញឧស្ម័នផ្ទះកញ្ចក់ | • វិធានការសមរម្យគួរពិចារណាសំរាប់គំរោងផ្គត់ផ្គង់ថាមពលក្នុងផែនការមេ ដើម្បីកាត់បន្ថយការភាយចេញឧស្ម័នផ្ទះកញ្ចក់ឱ្យដល់កំរិតអប្បបរមា<br>• ប្រសិទ្ធភាព និងការប្រើប្រាស់ថាមពលនៃថាមពលធម្មជាតិគួរពិចារណាសំរាប់គំរោងផ្គត់ផ្គង់ថាមពល |
| ការបំពុលបរិយាកាស | ខ | • ផលប៉ះពាល់មានកំរិតដោយធ្វើការវិនិច្ឆ័យពីគុណភាពបរិយាកាសបច្ចុប្បន្ន និងការកើនឡើងទំហំនៃការភាយចេញនៃសារធាតុបំពុលបរិយាកាសត្រូវបានព្យាករណ៍ ។ | • ការប៉ាន់ស្មាននៃអាំងតង់ស៊ីតេការបំពុល | • យកដីគ្របកន្លែងចាក់សំរាមប្រចាំថ្ងៃដើម្បីបង្ការអគ្គីភ័យ<br>• គ្របសំភារៈសំណង់អោយបានសមរម្យ និងការបាញ់ទឹកផ្លូវថ្នល់នៅដំណាក់កាលសាងសង់នៃគំរោងដែលបានស្នើឡើង ។<br>• ការថែរក្សាអោយបានសមរម្យនៃសំភារៈ |

| | | | | |
|---|---|---|---|---|
| | | | | សំណង់ និងយានយន្ត និងការសាងសង់ដែលត្រូវបានកំណត់ពេលជាយថាហេតុ ។ |
| ការបំពុលទឹក | ខ | • គំរោងធ្វើប្រព្រឹត្តិកម្មសំណល់រាវអាចធ្វើឱ្យធ្លាក់ចុះគុណភាពទឹកស្ទឹងសៀមរាបនៅពេលបញ្ហាប្រតិបត្តិ ។ ទឹកសំណល់ដែលហូរចេញពីកន្លែងចាក់សំរាមអាចធ្វើឱ្យកខ្វក់បឹងឬទន្លេនៅក្បែរនោះ ប្រសិនបើវាមិនត្រូវបានធ្វើប្រព្រឹត្តិកម្មសមរម្យ ។ | • ការអង្កេតផល់ទីកន្លែង ( រាប់បញ្ចូលការអង្កេតឋាន-លេខាសាស្ត្រ) | • ការគ្រប់គ្រងអោយបានសមរម្យនៃទឹកសំណល់ហូរចេញអំឡុងពេលសាងសង់ ។<br>• ការធ្វើប្រព្រឹត្តិកម្មនៃទឹកសំណល់ដែលហូរចេញពីកន្លែងចាក់សំរាម ។<br>• ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចតាមពេលកំណត់នៃសំភារៈធ្វើប្រព្រឹត្តិកម្មទឹក ។ |
| ការធ្វើឱ្យដីកខ្វក់ | ខ | • ដីស្រទាប់លើអាចធ្វើអោយក្រខ្វក់ដោយសំភារៈសំណង់ និងសំណល់សំណង់<br>• ទឹកសំណល់ហូរពីកន្លែងចាក់សំរាមដែលបានស្នើឡើងអាចជ្រាបចូលទៅក្នុងដី ឬធ្វើអោយកខ្វក់ដីស្រទាប់លើនៅដំណាក់កាលប្រតិបត្តិ | • ការអង្កេតភូគព្ភសាស្ត្រ | • ការធ្វើអធិការកិច្ចសំភារៈសំណង់ជាមុន<br>• ការធ្វើប្រព្រឹត្តិកម្មទឹកសំណល់ដែលហូរចេញពីកន្លែងចាក់សំរាម និងការកសាងប្រព័ន្ធធ្វើប្រព្រឹត្តិកម្មដាច់ដោយឡែកសំរាប់សំណល់ដែលបង្កគ្រោះថ្នាក់ និងជំងឺ |
| សំណល់ | ខ | • នឹងមានសំណល់មួយចំនួន នៅពេលមានការអនុវត្តន៏គំរោងដែលបានស្នើឡើង<br>• កន្លែងធ្វើប្រត្តិកម្មសំណល់រាវដែលបានស្នើឡើងនឹងបញ្ចេញទឹកសំណល់ដែលបានធ្វើប្រត្តិកម្ម និងសំណល់ភក់ | • ការពិនិត្យឡើងវិញនៃសមត្ថភាពនៃកន្លែងចាក់សំរាមដែលមានស្រាប់និងប្រព័ន្ធប្រមូលសំណល់ | • ការបង្កើតប្រព័ន្ធប្រមូលសំណល់សំណង់សមរម្យ<br>• ការធានាកន្លែងចាក់សំណល់សមរម្យ |
| សំលេង និងភាពញ័រ | ខ | • កំរិតនៃសំលេងនិងភាពញ័រនឹងកើនឡើងក្នុងកំរិតមួយធំក្នុងកន្លែងខ្លះនៃតំបន់សិក្សាប្រសិនបើមានការអនុវត្តគំរោង ដូចជាការដឹកជញ្ជូន និងសំភារៈសំណង់ ។ | • ការអង្កេតលើទីតាំងគំរោង | • ធានាថា សំភារៈសំណង់មានសភាពល្អដើម្បីធ្វើអោយសំលេង និងភាពញ័រតូច<br>• ការកំនត់ពេល/ការធ្វើផែនការ/ការគ្រប់គ្រងការសាងសង់អោយបានសមរម្យ |
| ការស្រុតដី | គ | • ផលប៉ះពាល់ទៅលើការស្រុតដីមិនទាន់មានភាពច្បាស់នៅឡើយនៅដំណាក់កាលនេះ ។<br>• នៅពេលចាប់ផ្តើមអនុវត្តការអភិវឌ្ឍន៏ទឹកក្រោមដី ពេលនោះលទ្ធភាពនៃការត្រឡប់វិញនៃផលប៉ះពាល់ អវិជ្ជមានមានកំរិតទាប ។ | • ការអង្កេតភូគព្ភសាស្ត្រជលសាស្ត្រ<br>• ការស្វែងយល់ពីការធ្លាក់ចុះទឹកក្រោមដី<br>• តេស្តិ៍បូមទឹក | • ប្រសិនបើផលប៉ះពាល់អវិជ្ជមានត្រូវគេប្រមើលមើលឃើញ គំរោងគួរត្រូវបញ្ឈប់ និងពិចារណាឡើងវិញ |
| ក្លិនស្អុយ | ខ | • ក្លិនស្អុយអាចកើតមានឡើងពីសំណល់សរីរាង្គដែលបំបែកធាតុនៅកន្លែងចាក់សំរាម<br>• ក្លិនស្អុយដែលអាចកើតពីសំណល់រាវ បន្ទាប់ពីឆ្លងកាត់ប្រព្រឹត្តិកម្ម និងសំណល់ភក់ពីកន្លែងធ្វើប្រព្រឹត្តិកម្មដែលបានស្នើឡើង ប្រសិនបើមិនបានថែទាំងឱ្យបានសមស្រប ។ | • ការអង្កេតលើទីតាំងគំរោង | • ទីតាំងនៃកន្លែងចាក់សំរាម ឬសំភារៈធ្វើប្រព្រឹត្តិកម្មសំណល់រាវគួរពិចារណាដោយប្រុងប្រយ័ត្ន ។<br>• ការគ្របដីគួរធ្វើនៅកន្លែងចាក់សំរាមប្រចាំថ្ងៃ ។<br>• ការថែទំាតាមកាលកំណត់នៃការធ្វើ |

| | | | | |
|---|---|---|---|---|
| | | | | ប្រព្រឹត្តិកម្មសំណល់រាវ |

កំណត់ចំណាំ : លក្ខណវិនិច្ឆ័យនៃការកំណត់កំរិតបំពុល

ក : អាចមានផលប៉ះពាល់ធ្ងន់ធ្ងរ

ខ : អាចមានផលប៉ះពាល់មួយចំនួន

គ : មិនដឹងពីកំរិតនៃផលប៉ះពាល់ ( តំរូវការឱ្យមានការត្រួតពិនិត្យ ។ ផលប៉ះពាល់អាចមានភាពច្បាស់លាស់ នៅពេលមានការសិក្សា)

## ៤.២ វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានរបស់ផែនការមេ

១) អំឡុងពេលមុនការសាងសង់

- ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ
- ការជ្រើសរើសទីកន្លែងដោយប្រុងប្រយ័ត្នសំរាប់គំរោងនីមួយៗ
- ការអង្កេតបុរាណវត្ថុ
- ការធានាជំរើសការងារសំរាប់ម្ចាស់ដីក្នុងតំបន់គំរោង
- ការធ្វើពិសោធន៍សាកល្បងនូវគុណភាពទឹកក្រោមដី
- ការសិក្សានៃភូគព្ភសាស្ត្រជលសាស្ត្រ
- ការសំរបសំរួលអន្តរក្រសួងលើការប្រើប្រាស់ទឹក
- ការអង្កេតភូគព្ភសាស្ត្រនៅលើដី
- ការអង្កេតបរិយាកាស

២) អំឡុងពេលនៃការសាងសង់

១. វិធានការកាត់បន្ថយផលប៉ះពាល់ពីសកម្មភាពសាងសង់

- ការគ្រប់គ្រងសម្ភារៈសំណង់ឱ្យបានសមរម្យ
- ការបាញ់ទឹកលើផ្លូវថ្នល់
- ការថែទាំសម្ភារៈសំណង់ និងយានយន្តឱ្យបានសមរម្យ
- ការគ្រប់គ្រងទឹកពីការដ្ឋានសំណង់
- ការបង្កើតប្រព័ន្ធប្រមូលសំណល់សំណង់
- ការកំណត់ពេល / ការធ្វើផែនការ / ការគ្រប់គ្រងការសាងសង់ឱ្យបានសមរម្យ
- ការបំពាក់ជញ្ជាំងខ្ទប់សំលេង ឬតំបន់ទ្រនាប់

២. នីតិវិធីសមរម្យសំរាប់ស្រាវជ្រាវបុរាណវត្ថុ

ម្ចាស់កិច្ចសន្យាសាងសង់ត្រូវបញ្ឈប់សកម្មភាពសាងសង់ជាបន្ទាន់ ប្រសិនបើមានការរាយការណ៍ពីការប្រទះឃើញវត្ថុបុរាណ ។ បើចាំបាច់ អ្នកបុរាណវិទូត្រូវធ្វើការអង្កេតពីវត្ថុបុរាណនោះ ហើយចាំបាច់ត្រូវចាត់វិធានការសមស្របដើម្បីសង្គ្រោះ ។

៣. ការកែប្រែតំបន់រងការប៉ះពាល់ដោយការសាងសង់ទៅរកលក្ខខណ្ឌដើមវិញ

គ្រប់កន្លែងដែលរងផលប៉ះពាល់ដោយសារការអនុវត្តគំរោងចាំបាច់ត្រូវស្ដារឡើងវិញឱ្យដូចភាពដើម បន្ទាប់ពីបញ្ចប់ការសាងសង់។ សម្ភារៈ គ្រឿងចក្រ និងយានយន្តសំរាប់ការសាងសង់ត្រូវប្រមូលចេញ ហើយសំណល់ពីការសាងសង់ សម្ភារៈមិនប្រើប្រាស់ និងដីកខ្វក់ចាំបាច់ត្រូវយកទៅចោលឱ្យបានសមស្រប។

៣) អំឡុងពេលប្រតិបត្តិ

ចាំបាច់ត្រូវពិចារណា និងអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់នានាក្នុងអំឡុងពេលនៃការអនុវត្តន៍គំរោងនីមួយៗ។ វិធានការទាំងនេះត្រូវពិចារណា និងបង្កើតនៅក្រិតផែនការមេ ឬក្រិតសិក្សាលទ្ធភាពអនុវត្តគំរោងដោយសារសេចក្ដីលំអិតនៃគំរោងនីមួយៗមិនត្រូវបានបញ្ជាក់ច្បាស់លាស់នៅដំណាក់កាលនេះទេ។ វិធានការកាត់បន្ថយផលប៉ះពាល់ដែលបានពិចារណានៅដំណាក់កាលនេះសំរាប់គំរោងមួយចំនួន ត្រូវបានពិពណ៌នាដូចខាងក្រោម :

- កន្លែងចាក់សំរាម : ប្រមូលឧស្ម័នពីកន្លែងចាក់សំរាម ប្រើដីសំរាប់គ្របកន្លែងចាក់សំរាមរៀងរាល់ថ្ងៃដើម្បីការពារក្លិនស្អុយ និងកាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវអគ្គីភ័យកើតឡើងដោយចៃដន្យនៅកន្លែងចាក់សំរាម និងអាងប្រព្រឹត្តិកម្ម ដើម្បីធ្វើប្រព្រឹត្តិកម្មទឹកសំណល់ពីកន្លែងចោលសំរាម។
- អាងប្រព្រឹត្តិកម្មសំណល់ : ថែទាំជាប្រចាំដើម្បីការពារក្លិនស្អុយ
- ម៉ាស៊ីនភ្លើងប្រើម៉ាស៊ូត : តម្លើងឧបករណ៍ដើម្បីកាត់បន្ថយការបំភាយផ្សែង
- ការបូមទឹកក្រោមដី : ត្រួតពិនិត្យជាបណ្ដើរៗនូវការបាក់ស្រុតដី

## ៩. អនុសាសន៍

១. រហូតមកដល់ពេលនេះ សៀមរាបបានឆ្លងកាត់ទេសចរណ៍បែបគំហុក។ ទេសចរណ៍បែបគំហុកនេះបានកើតមានឡើងនៅតាមតំបន់ទេសចរណ៍ និងសកម្មភាពកំសាន្តតិចតួចប៉ុណ្ណោះក្រៅពីបរិវេណអង្គរ។ សេវាកម្មសាធារណៈសំខាន់ៗមិនអាចឆ្លើយតបទៅនឹងការអភិវឌ្ឍន៍សណ្ឋាគារយ៉ាងឆាប់រហ័យ។ គេយល់ឃើញថា ក្រុងសៀមរាបពុំទាន់មានសុវត្ថិភាព ស្អាត ឬមានភាពងាយស្រួលសំរាប់ឱ្យភ្ញៀវទេសចរបុគ្គល ឬគ្រួសារដើម្បីដើរកំសាន្តនៅឡើយ។ អ្នកបង្កើតគោលនយោបាយគួរយល់ថា ការអភិវឌ្ឍន៍ទេសចរណ៍ និងក្រុងដូចនេះមិនអាចមាននិរន្តរភាពឡើយនៅពេលអនាគត។ គេគួរតែកែប្រែពីទេសចរណ៍បែបបរិមាណទៅជាទេសចរណ៍គុណភាព និងគួរតែធ្វើឡើងឱ្យស្របទៅនឹងលក្ខខណ្ឌបរិស្ថានធម្មជាតិ។ រដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ខ្ពស់ក្នុងការកំណត់ឱ្យបានច្បាស់លាស់នូវបញ្ហាក្រុង និងបរិស្ថានក្នុងសៀមរាប។ម្យ៉ាងវិញទៀត ការធ្លាក់ចុះខាងបរិស្ថាន និងការខូចខាតដែលអាចកើតមានដល់ក្រុងអាចធ្វើឱ្យភ្ញៀវទេសចរចេញពីសៀមរាប នៅពេលមានការប្រកួតប្រជែងកើតខ្ពស់ពីតំបន់ទេសចរណ៍ផ្សេងៗទៀតនៅលើពិភពលោក។

២. កត្តាដ៏សំខាន់បំផុតមួយគឺទឹកសំរាប់ភ្ញៀវទេសចរ ប្រជាជនមូលដ្ឋាន និងសំរាប់ដីកសិកម្មដែលអាចប្រើជាខ្សែក្រវ៉ាត់បៃតង។ ការបូមទឹកក្រោមដីរបស់បុគ្គលសំរាប់បំរើគោលបំណងពាណិជ្ជកម្មគួរចុះបញ្ជី ត្រួតពិនិត្យ និងបង់ប្រាក់ នៅពេលចាំបាច់។ នៅពេលបច្ចុប្បន្ន ការងារនេះអាចអនុវត្តបាន បន្ទាប់ពីមានប្រព័ន្ធគ្រប់គ្រងទឹកស្អាតក្នុងក្រុង។ គួររៀបចំផែនការសំរាប់ខេត្តទាំងមូលឱ្យបានលឿនបំផុត បើអាចធ្វើបានដើម្បីគ្រប់គ្រងធនធានទឹកដែលមានស្រាប់ និងដែលមានសក្ដានុពល និងសំរបសំរួលឱ្យមានការប្រើប្រាស់ទឹករយៈពេលយូរអង្វែង។

៣. ការគ្រប់គ្រងលើការប្រើប្រាស់ដីគឺជាផ្នែកដ៏សំខាន់មួយទៀត។ ការអភិវឌ្ឍន៍ក្រុងគួរតែអនុវត្តតែនៅក្នុងតំបន់ពង្រីកក្រុងដែលបានស្នើឡើង។ អាស្រ័យហេតុនេះ ត្រូវផ្ដល់ហេដ្ឋារចនាសម្ព័ន្ធក្រុងឱ្យបានគ្រប់គ្រាន់។ គេអាចការពារតំបន់ប្រវត្តិសាស្ត្រ និងដីកសិកម្មពីការពង្រីកក្រុងដោយគ្មានការត្រួតពិនិត្យត្រឹមត្រូវ។ នៅពេលមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទាន់ពេលវេលា គេអាចបញ្ចៀសដីសាធារណៈពីការសាងសង់ ការតាំងទីលំនៅ និងការកាន់កាប់ដីខុសច្បាប់ដោយមានការចូលរួមពេញលេញពីប្រជាជនងាយរងគ្រោះក្នុងសង្គម។ ការបង្កើតរចនាសម្ព័ន្ធរដ្ឋបាលបែបស្មុគស្មាញនាពេលបច្ចុប្បន្នសំរាប់ការធ្វើផែនការប្រើ ប្រាស់ដីធ្លីគួរតែសំរួលដើម្បីឱ្យការគ្រប់គ្រងដីធ្លីមានប្រសិទ្ធភាព។

៤. ផែនការមេរយៈពេលវែងនេះគឺជាឯកសារមានជីវិត។ ឯកសារនេះគួរតែពិនិត្យកែលំអដើម្បីឱ្យឆ្លើយតបទៅនឹងកាលៈទេសៈប្រែប្រួល ជាពិសេសដោយខេត្តសៀមរាប អាជ្ញាធរអប្សរា គណៈកម្មការអភិវឌ្ឍន៍កម្ពុជា និងការិយាល័យនៃទីស្ដីការរដ្ឋមន្ត្រី។ គំរោងអាទិភាពដែលបានស្នើឡើងគួរធ្វើការពិនិត្យឱ្យបានល្អិតល្អន់ដើម្បីធ្វើការរៀបចំ និងអនុវត្តឱ្យទាន់ពេលវេលា។ ផ្ទុយផ្សំជាមួយនឹងកិច្ចខិតខំទាំងនេះ អាជ្ញាធរខេត្តគួរពង្រឹងមុខងាររបស់ខ្លួនដើម្បីពិនិត្យតាមដានការវិនិយោគ ការប្រើប្រាស់ដី គំរោងបរិស្ថានរបស់រដ្ឋាភិបាល និងពិនិត្យកែប្រែផែនការមេនេះ។

៥. គំរោងសាកល្បង ដែលមានឈ្មោះ " ការធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង" និង "ការតាំងពិព័រណ៍ផលិតផលអង្គរ ឆ្នាំ២០០៥" បានទទួលជោគជ័យ ដោយសារគំនិតផ្តួចផ្តើមដ៏រឹងមាំរបស់មូលដ្ឋាន និងការគាំទ្រពីថ្នាក់ជាតិយ៉ាងទូលំទូលាយ ។ គំរោងទាំងនោះគួរចាត់ទុកជាគំរោងគំរូសំរាប់បន្តសកម្មភាពលើកកំពស់បរិស្ថានក្រុង និងពង្រីកឱ្យបានច្រើននូវផលប្រយោជន៍សេដ្ឋកិច្ចនៅមូលដ្ឋាន និងសោភ័ណភាពនៅជនបទ ។ គំនិតផ្តួចផ្តើមនៅមូលដ្ឋានដែលអនុវត្តដោយអភិបាលខេត្តគួរតែទទួលបានការជ្រោមជ្រែងជាបន្តពីក្រសួងពាក់ព័ន្ធ ផ្នែកឯកជន និងប្រជាជននៅមូលដ្ឋាន ។

៦. ការកសាងសមត្ថភាពនៃអាជ្ញាធរនៅថ្នាក់មូលដ្ឋាន ជាពិសេសអាជ្ញាធរខេត្តគឺជាផ្នែកដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍សៀមរាបប្រកបដោយនិរន្តរភាព ។អាជ្ញាធរខេត្តគួរពង្រឹងមន្ត្រីធ្វើផែនការរបស់ខ្លួនជាបន្ទាន់នូវជំនាញបច្ចេកទេស ។ ខេត្តគួរលើកកំពស់ការចែករំលែកព័ត៌មានអំពីការអភិវឌ្ឍន៍រវាងមន្ទីរ និងអាជ្ញាធរផ្សេងៗនៅថ្នាក់ខេត្តតាមរយៈការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ខេត្ត ។ ជាលទ្ធផល ខេត្តនឹងអាចក្លាយជាស្ថាប័នមួយដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍ខេត្ត ឬគណៈកម្មការគ្រប់គ្រងខេត្ត ។ ខេត្តគួរមានកញ្ចប់ថវិកា ជាពិសេសសំរាប់ថែទាំសេវាកម្មសាធារណៈជាយុទ្ធសាស្ត្រផ្សេងៗ ដូចជា ផ្លូវថ្នល់ ការប្រមូលសំណល់ និងប្រព័ន្ធបង្ហូរទឹកភ្លៀង ។ ប្រភពហិរញ្ញវត្ថុដែលអាចទទួលបាន និងមានចំនួនច្រើនគឺបានមកពីចំណែកនៃថវិកាចូលទស្សនារមណីយដ្ឋានអង្គរ ។

៧. ខុសពីខេត្តផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ខេត្តសៀមរាបពឹងផ្អែកយ៉ាងខ្លាំងទៅលើវិស័យទេសចរណ៍ និងក្រុង ។ ដូចនេះ អាជ្ញាធរខេត្តសៀមរាបគួរពង្រឹងអំណាចក្នុងការធ្វើសេចក្តីសំរេចចិត្ត និងសមត្ថភាពបច្ចេកទេសសំរាប់ធ្វើផែនការត្រួតពិនិត្យ និងថែរក្សាបរិស្ថានក្រុង ។ អំណាចក្នុងការធ្វើសេចក្តីសំរេចរបស់ខេត្ត និងសមត្ថភាពបច្ចេកទេសគួរតែមានប្រសិទ្ធភាពដោយមានការគាំទ្រខាងបច្ចេកទេស និងច្បាប់ពីក្រសួង និងមន្ទីរពាក់ព័ន្ធ ព្រមទាំងមានការគាំទ្រពីអាជ្ញាធរអប្សរា ។

៨. រមណីយដ្ឋានអង្គរគឺជានិមិត្តរូបនៃអត្តសញ្ញាណជាតិ ជាបេតិកភណ្ឌវប្បធម៌ពិភពលោក និងជាប្រភពដ៏សំខាន់នៃរូបិយវត្ថុបរទេស ។ ដូចនេះ សៀមរាបគួរតែជាក្រុងគំរូលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងប្រទេសកម្ពុជា ។ សៀមរាមមិនត្រឹមតែមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពប៉ុណ្ណោះទេ តែថែមទាំងធ្វើការឆ្លុះបញ្ចាំងពីគតិបណ្ឌិតសម័យអង្គរលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ឆ្លុះបញ្ចាំងពីវប្បធម៌សម្បូរបែប និងការចូលរួមរបស់ប្រជាជន ក្នុងសកម្មភាពអភិវឌ្ឍន៍ក្នុងសតវត្សទី២១ ។ សៀមរាបមិនត្រឹមតែជាទីតាំងនៃរមណីយដ្ឋានរូបវន្តប៉ុណ្ណោះទេ តែថែមទាំងជាប្រភពព្រលឹងសកលដែលកំពុងត្រូវសាយភាយទៅកាន់កន្លែងផ្សេងៗទៀតក្នុងពិភពលោក ។ សៀមរាបក៏ជាកន្លែងទាក់ទាញខាងវប្បធម៌យ៉ាងខ្លាំងនៅតំបន់អាស៊ីអាគ្នេយ៍ ។ ដើម្បីធ្វើឱ្យសំរេចនូវគំនិតទាំងនេះគ្រប់ក្រសួង អាជ្ញាធរ និងក្រុមប្រឹក្សានៃរដ្ឋាភិបាលថ្នាក់ជាតិគួរចែករំលែកការយល់ដឹងរួម ដែលជាកត្តាសំខាន់ សំរាប់ជួយសៀមរាបទាំងហិរញ្ញវត្ថុ និងបច្ចេកទេស ជាពិសេសលើការកែលំអបរិស្ថាន និងក្រុង ។

jica

LIB